# នេមិរាជជាតក



នេះកាលព្រះបាទនេមិរាជយាងទតឋានសួគ៌

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**កុល ផេង**

**ព.ស. ២៥៦៣**

# នេមិរាជជាតកពិស្តារ

## អធិបតីក្នុងការរៀបរៀង
## បណ្ឌិត កុល ផេង

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## អ្នកបកប្រែពីអដ្ឋកថាភាសាបាលី

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## ក្រុមជំនុំពិនិត្យ

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោក* **លឹម លឿម**

*លោក* **ដុង សុភឿន**

*លោក* **ទិព្វ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គឹមឈន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហាន សុខេមន្ទ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាមឿន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សាវេន** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា ក្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុខ សុវណ្ណ** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ ភុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ឈាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមនុ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **ភុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មាចារ្យ* **ទ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មាចារ្យ* **ទ៉ាន់ ចាន់សារ៉េន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ ទ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ្ញ វិបុល** *សមាជិក*

*លោកគ្រូធម្មាចារ្យ* **ទ៉ាន់ ចាន់សារ៉េន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គឹមឈន់** *សមាជិក*

# សូមថ្វាយព្រះរាជកុសល
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

***បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងករិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្វសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***នេមិរាជជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

*កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុងហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី** *ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោសដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***នេមិរាជជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយ ព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះសម្មាសម្ពុទ្ធ*

គ្រប់ព្រះអង្គដែលបានគ្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុង អនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងលោក សូមជួយអភិបាលថែរក្សា **សម្តេចព្រះមហាក្សត្រ នរោត្តម សីហមុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ទ្រង់មានព្រះរាជ-សុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្ម យឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជ-ហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**ភុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តីជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "***នេមិរាជជាតកពិស្តារ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុង លោកសូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្តេច**

*សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវិរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**ភូល ផេខ**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## បុព្វកថា

រឿងនេមិរាជនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលី ដូច្នេះជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ម្យ៉ាងវិញទៀតប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក **ឈឹម ស៊ុម** កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយឃើញថា មានសេចក្តីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ឆ្លួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្មែរ ចាត់ចែង រៀបចំបកប្រែនិងរៀបរៀងនេមិរាជជាតកនេះ

ម្តងទៀតឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជាភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត ជោតញ្ញាណោ** ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យរាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវ-ភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសាដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្តាំផ្គង់ខ្វះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើនដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅនេមិរាជ

*ជាតកពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ត សូមឲ្យលោកអ្នកមានគុណទាំងនោះ បានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្តីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី១


កំណើតព្រះបាទនេមិរាជ........................................................១

ព្រះបាទមឃទេពចេញសាងផ្នួស..........................................២

នេមិកុមារ.....................................................................................៨

ស្ដេចសក្កៈដោះចម្ងល់ព្រះបាទនេមិរាជ................................១១

កំណាត់សម្គាល់ ....................................................................១៨

ពួកទេវតានឹកព្រះបាទនេមិរាជ............................................២៧

មាតលិទេវបុត្រទៅដឹកព្រះបាទនេមិរាជ..............................២៩


## ជំពូកទី២

## ស្ដីពីឋាននរក


ដំណើរទេស្សនកិច្ចនៅឋាននរក............................................៣៥

១- នរកស្ទឹងវេតរណី...........................................................៣៥

២- នរកសុនខ........................................................................៤១

៣- នរកដំបង់ដែក..................................................................៤៤

៤- នរករណ្ដៅរងើកភ្លើង.........................................................៤៥

៥- នរកខ្ទះទង់ដែង..................................................................៤៧

៦- នរកត្របែងក្បាល...............................................................៤៨

៧- នរកអង្កាម........................................................................៤៩

៨- នរកលំពែង.......................................................................៥១

៩- នរកចិញ្ច្រាំ.........................................................................៥៣

១០- នរកអន្ទង់លាមក..............................................................៥៤

១១- នរកអន្ទង់ខ្ទុះឈាម...........................................................៥៦

១២- នរកផ្ទៃសន្ទូច..................................................................៥៧

១៣- នរកភ្នំត្បាល់...................................................................៥៩

១៨- នរករណ្ដៅធំ....................................................................៦២

១៩- នរកខ្លស់ទាប..................................................................៦៤

សក្កទេវរាជបញ្ជូនទេវបុត្រឲ្យទៅតាមជាលើកទី១..................៦៦

## ជំពូកទី៣

## ដំណើរទស្សនកិច្ចនៃព្រះបាទនេមិរាជនៅឋានសួគ៌

វិមានទេពធីតាពីរណី..............................................................៦៨

វិមានទេវបុត្រសោណទិន្នៈ.....................................................៧១

វិមានឧបាសិកា........................................................................៧៤

វិមានឧបាសក...........................................................................៧៦

វិមានគហបតី...........................................................................៨០

វិមានគហបតីទី២...................................................................៨៣

វិមានកែវពៃទូរ្យ.........................................................................៨៥

វិមានមាស................................................................................៨៧

វិមានវេហាស៍........................................................................ ៨៨

ភ្នំសត្តបរិភណ្ឌ.................................................................... ៩១

ទេពនគរ.............................................................................. ៩៣

សុធម្មាទេវសភា.................................................................. ៩៥

ព្រះបាទនេមិរាជត្រឡប់មកមនុស្សលោកវិញ....................... ៩៩

ព្រះសាស្ដាប្រជុំជាតក..................................................... ១០៣

# ជំពូកទី១
## កំណើតព្រះបាទនេមិរាជ

### និទានខាងដើម

*កាលព្រះសាស្ដាគង់នៅក្នុងព្រៃស្វាយឈ្មោះ* **មឃទេព** *ជិតក្រុងមិថិលា ទ្រង់បានប្រារព្ធសិតបាតុកម្ម*[១] *ហើយបានសម្ដែងនូវធម្មទេសនាផ្ដើមពាក្យបាលីថា "អច្ឆេរំ វត លោកស្មឹ" ដូច្នេះជាដើម ។*

*មានសេចក្ដីពិស្ដារថា ក្នុងថ្ងៃមួយ ព្រះសាស្ដាត្រាច់ចារិកទៅកាន់ព្រៃស្វាយនោះ ជាមួយនឹងភិក្ខុទាំងឡាយជាច្រើនអង្គ នាវេលារសៀល ។ ទ្រង់បានទតឃើញតំបន់*[២] *មួយ ជាកន្លែងគួររីករាយ ព្រះ*

---

[១] *ការញញឹមរបស់ព្រះសម្មាសម្ពុទ្ធ ។*

[២] (ន.) *ទី; ប៉ែកដី; ប៉ែកព្រៃ ជាដើម : ក្នុងតំបន់មួយ, ដីមួយតំបន់; ព្រៃមួយតំបន់ ។ ទីស្ដីការរាជការមួយផ្នែកតូច មានសង្កាត់ប៉ុណ្ណោះ ៗ មានអ្នករាជការថ្នាក់លេខាធិការស្រុកម្នាក់ ឬនាយរាជតម្រួតម្នាក់ជាមេគ្រប់គ្រង ជាតំណាងអភិបាលស្រុក ក៏ហៅតំបន់ ដែរ : តំបន់អូររាំងឪ (ក្នុងស្រុកកោះសូទិន ខេត្រកំពង់ចាម), តំបន់ត្រាំខ្នារ (ក្នុងស្រុកបាទីខេត្រតាកែវ) ។ល។ មេតំបន់មួយ ៗ ហៅថា ចៅតំបន់ (កាលពីដើម តំបន់នេះ អាចឲ្យសរសេរជា ដំបន់ ក៏បាន ប៉ុន្តែឥឡូវនេះត្រូវលែងប្រើ, ត្រូវសរសេរ ដំបន់ចំពោះតែ វាយមួយដំបងត្រូវដំបន់យ៉ាងធ្ងន់ ឯណោះដោយឡែកទៅវិញ)។*

អង្គមានព្រះពុទ្ធបំណងនឹងសម្ដែងនូវបុព្វចរិយា[៣]របស់ព្រះអង្គ ហើយក៏ទ្រង់បង្ហាញនូវអាការញញឹមឲ្យប្រាកដឡើង ។ ព្រះអានន្ទត្ថេរឃើញព្រះអង្គញញឹមដូច្នោះ ក៏បានក្រាបទូលសួរអំពីមូលហេតុដែលនាំឲ្យទ្រង់ញញឹមនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ឆ្លើយតបថា ៖

"ម្នាលអានន្ទ ដើមឡើយ ភូមិភាគ[៤] នេះ ធ្លាប់ជាតំបន់គ្រប់គ្រងដោយតថាគតអ្នកលេងឈាន ក្នុងរជ្ជកាលព្រះបាទ **មឃទេព**"

កាលព្រះអានន្ទត្ថេរក្រាបទូលអារាធនា ព្រះអង្គក៏ប្រថាប់គង់លើអាសនៈដែលគេក្រាលថ្វាយ ហើយនាំអតីតនិទានមកសម្ដែងដូចតទៅនេះ ៖

**ព្រះបាទមឃទេពចេញសាងផ្នួស**

ក្នុងកាលយូរលង់ណាស់មកហើយ មានស្ដេចផែនដីមួយអង្គព្រះនាមថា **មឃទេព** ទ្រង់សោយរាជ្យក្នុងក្រុងមិថិលា[៥] ដែនវិទេហៈ ។

---

[៣] ន. (បា.; សំ. បូវ៌ចយា) ចរិយាដើម គឺការប្រព្រឹត្ត, សំណាង ឬមារយាទ, ទម្លាប់, សណ្ដាប់ធ្នាប់, ដែលបុគ្គលធ្លាប់បានប្រព្រឹត្តពីជាតិមុន ៗ មកជាប់ជាស្នាមតាមមកដល់ជាតិនេះ ។

[៤] (ភូ-មិភាគ) ប៉ែកផែនដី, ប៉ែកទីតំបន់ ។

ព្រះបាទមឃទេពនោះ ទ្រង់នៅជាកុមារភាព អស់កាល ៨៤.០០០ ឆ្នាំ, កាន់តំណែងឧបរាជ[៦] អស់កាល ៨៤.០០០ ឆ្នាំ, ទ្រង់សោយរាជ្យក៏អស់កាល ៨៤.០០០ ឆ្នាំដែរ ។ ក្នុងថ្ងៃមួយ ទ្រង់បានត្រាស់នឹងខ្មាន់ព្រះកេស[៧]ថា ៖

"ហៃខ្មាន់ព្រះកេសសម្លាញ់, បើលោកឃើញសក់ក្បាលរបស់យើងមានស្កូវនៅពេលណា សូមលោកជួយប្រាប់យើងនៅពេលនោះផង" ។

---

[៥] (ន.) (សំ.),(បា.) (--ល៉ា) ឈ្មោះក្រុងមួយរបស់ដែនវិទេហៈ (ប្រទេសឥណ្ឌា) ក្នុងសម័យបុរាណព្រេងនាយ, ឋិតនៅខាងទិសឦសាននៃដែនបាំង្គ័ល ឬបេង្គ័លសព្វថ្ងៃនេះ; មាននិយាយចេញឈ្មោះជាញឹកញយក្នុងគម្ពីរជាតកផ្នែកខាងពុទ្ធសាសនា : នគរមិថិលា ។

[៦] (ន.) (សំ.),(បា.) (អ៊ុប៉ៈរ៉ាច ឬ អុប៉ៈ--) ព្រះរាជាបន្ទាប់ គឺក្សត្រិយ៍ដែលមានរាជស័ក្តិរងបន្ទាប់ក្សត្រិយ៍ទ្រង់រាជ្យ : សម្ដេចព្រះឧបរាជ ឬសម្ដេចព្រះមហាឧបរាជ (តាមបវេណីក្នុងកម្ពុជរដ្ឋ, នាទីរបស់សម្ដេចព្រះមហាឧបរាជជាឋានៈសម្រាប់ត្រី ទាំងមន្ត្រីធំតូចសម្រាប់ព្រះអង្គ ក៏តាំងក្នុងឋានៈសម្រាប់ត្រីដែរ ។ មើលក្នុងពាក្យ សមណសក្តិទៀតផង) ។

[៧] អ្នកកាត់សក់កោរពុកមាត់ពុកចង្កាថ្វាយព្រះរាជា ។

ចំណោរកាលក្រោយមក ខ្មាន់ព្រះកេសឃើញសក់ស្កូវ ១ សរសៃ នៅលើព្រះសីសៈរបស់ព្រះរាជា ក៏បានក្រាបទូលព្រះរាជាឲ្យទ្រង់បាន ជ្រាបនូវអាការនោះ ។ ព្រះរាជាបានប្រើឲ្យដកស្កូវនោះដោយចន្ទាស[៨] មាស ដាក់លើបាតព្រះហស្តព្រះអង្គ ។ ស្តេចទ្រង់ទតសក់ស្កូវនោះ ក៏ យល់ច្បាស់អំពីសេចក្តីស្លាប់ ហាក់បីដូចខ្លួនព្រះអង្គត្រូវស្តេចមច្ចុរាជ មកជាប់លើព្រះនលាដ៍ ទ្រង់ក៏មានព្រះតម្រិះថា "ឥឡូវនេះ ដល់ពេល ដែលអាត្មាអញត្រូវចេញបួស" ហើយទ្រង់ប្រទាននូវស្រុកសួយមួយ ដល់នាយខ្មាន់ព្រះកេសនោះ ចាត់ព្រះរាជបម្រើឲ្យទៅហៅព្រះរាជ បុត្រឲ្យចូលគាល់ ព្រះអង្គមានព្រះរាជឱង្ការនឹងព្រះរាជបុត្រថា ៖

"ហៃបាសម្លាញ់បិតា ចូរបុត្រទទួលរាជ្យស្នងបិតា, បិតានឹង ចេញទៅសាងផ្នួស"

"តើមានរឿងអ្វីទៅ ព្រះសម្មតិទេព ?" រាជបុត្រទូលសួរ ។

"ឧត្តមង្គរុហា មយ្ហំ ឥមេ ជាតា វយោហរា
បាតុភូតា ទេវទូតា បព្វជ្ជាសមយោ មម"។

[៨] តម្បៀតធ្វើដោយដែកជាដើមសម្រាប់ចាប់, សម្រាប់ចាប់ផ្អោបតៀតគ្នា ។

"អវយវៈ[៩] យើងធំធាត់ឡើងស្រស់ថ្លាណាស់, ប៉ុន្តែអវយវៈទាំងនោះ ឱនថយទៅតាមវ័យទាំងអស់, ទេវទូត[១០]កំពុងតែប្រាកដនឹងភ្នែកយើងច្បាស់ក្រឡែត, ដូច្នេះ ឥឡូវនេះដល់ពេលយើងត្រូវចេញសាងផ្នួស" ស្ដេចទ្រង់តប ។

លុះប្រាប់ដូច្នេះហើយ ព្រះអង្គបានអភិសេក[១១]បុត្រច្បងនោះឲ្យឡើងគ្រងរាជ្យ ហើយទ្រង់ប្រទានឱវាទដល់បុត្រថា ៖

---

[៩] (ន.) (សំ.),(បា.) (អៈវ៉ៈយៈវៈ) (អវយវ) អង្គ, រូបអង្គ, រូបរាង, សព៌ាង្គ, រាងកាយ, ខ្លួនប្រាណ; ចំណែក; ប៉ែកឬចំណែកតូចធំនៃរូបកាយ : អវយវៈតូចធំសព៌ាង្គកាយមានដៃជើងជាដើម (ព. កា. ប្រើជា អពយព ឬ អព្យព ក៏បាន) ។ រុក្ខាវយវៈ (មើលក្នុងពាក្យ រុក្ខ) ។ សរីរាវយវៈ (មើលក្នុងពាក្យ សរីរៈ) ។

[១០] សច្ចធម៌ដែលមាននៅក្នុងធម្មជាតិ (ដី, ទឹក, ភ្លើង, ខ្យល់, កើត, ចាស់,ឈឺ, ស្លាប់) ។ មិនមែនទូតរបស់ទេវតា ។

[១១] (ន.) (បា.),(សំ.) (អៈភិសែក) (អភិបេក) ការស្រោចទឹកក្ចស់ទឹកស័ង្ខ (លើព្រះសិរ្ស៍លោកអ្នកមានបុញ្ញាភិនីហារ) សន្មតឲ្យឡើងពេញទីជាក្សត្រិយ៍ទ្រង់រាជ្យ (ម. ព. មុទ្ធាភិសេក ផង) ។ ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយពរថ្វាយជ័យចំពោះព្រះពុទ្ធរូបដែលកសាងថ្មី ក៏ហៅ អភិសេក ដែរ : *អភិសេកព្រះ* (ធ្វើតាមដំណើររឿងកាលដែលព្រះសក្យមុនីគោតម ទ្រង់បានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ, ក្នុងវេលាភ្លាម ៗនោះ, ពួកទេវតានាំគ្នាមកប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរទិព្វថ្វាយពរសព្ទ

"ហៃបាសម្លាញ់, បុត្រក៏អ៊ីចឹងដែរ កាលណាបើឃើញសក់ស្កូវបែបនេះ បុត្រក៏ត្រូវចេញសាងផ្នួសដូចបិតាកុំខានឲ្យសោះ" ។

ព្រះរាជាបានចេញចាកនគរ បួសជាឥសីចម្រើនព្រហ្មវិហារធម៌ ៤ អស់កាល ៨៤.០០០ ឆ្នាំទៀត ។ ក្រោយអស់ព្រះជន្ម ទ្រង់ក៏កើតនៅឯព្រហ្មលោកនាយ ។

ចំណែករាជបុត្ររបស់ស្តេចអង្គនោះ ក៏ចេញសាងផ្នួសដោយទំនងដូច្នោះដែរ លុះដល់ទីបំផុតជីវិត ក៏កើតនៅព្រហ្មលោកដូចគ្នា ។ រាជបុត្រដែលឡើងគ្រងរាជ្យត ៗ ទាំងអម្បាលមាណ កាលដែលបានឃើញសក់ស្កូវលើព្រះសីសៈ ក៏បានសាងផ្នួសនៅក្នុងព្រៃស្វាយនោះ ចម្រើនព្រហ្មវិហារធម៌[១២] ៤ រួចក៏កើតនៅព្រហ្មលោកត ៗ គ្នាយ៉ាងនេះ

---

សាធុការថា "ព្រះពុទ្ធឈ្នះមារហើយ ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ !" ។ ពាក្យ *អភិសេក* នេះខ្មែរប្រើជា កិ. ក៏មាន ។

[១២] ព្រហ្មចរិយ, --យៈ ឬ ព្រហ្មចារ្យ (ព្រះម្មៈចៈរ៉ិយ៉ៈ ឬ--ចា, ឬក៏ ត. ទ. ស្រ. ព្រំមៈ--) ន . (បា. ព្រហ្មចរិយ; សំ. ព្រហ្មចយ៌) បែបបទ ឬសណ្ដាប់ធ្នាប់របស់ព្រហ្មចារី ឬព្រហ្មចារិនី; ការប្រព្រឹត្តធម៌ដ៏ប្រសើរ ។ តាមន័យខាងពុទ្ធសាសនាថា ការឲ្យទាន, ការខ្វល់ខ្វាយ ឬខ្នះខ្នែងចំពោះអំពើជាកុសល, ការរក្សាសីល ៥, ការចម្រើនព្រហ្មវិហារ ៤ ការសម្ដែងធម៌ ឬណែនាំពន្យល់ឲ្យអ្នកដទៃកាន់អំពើសុចរិត, ការវៀរចាកមេថុន

គឺខ្វះតែ ២ អង្គប៉ុណ្ណោះ នឹងគ្រប់ ៨៤.០០០ ក្សត្រ ។ បណ្ដាក្សត្រទាំងនោះ មឃទេវរាជដែលកើតនៅព្រហ្មលោកដំបូងគេបង្អស់ ព្រះអង្គបានប្រមើលមើលនូវតំណវង្សរបស់ព្រះអង្គ ឃើញនូវចំនួនក្សត្រដែលបួសខ្វះតែ ២ អង្គទៀត នឹងគ្រប់ចំនួន ៨៤.០០០ ក្សត្រ, ទ្រង់មានព្រះហឫទ័យរីករាយ និងរំពឹងមើលថា "តើអំពីឥឡូវនេះទៅ លម្អាននៃការសាងផ្នួសរបស់ក្សត្រ នឹងនៅមានបន្តទៅទៀតឬអត់ទេ ?" លុះជ្រាបនូវដំណើរផ្នួសនឹងដាច់ខ្សែ លែងប្រព្រឹត្តទៅមុខទៀត ទ្រង់ព្រះចិន្តាថា "មានតែអាត្មាអញទេ ទើបអាចបន្តតំណវង្ស[១៣]ផ្នួសរបស់អញបាន"។ ត្រិះរិះដូច្នេះហើយ ស្ដេចទ្រង់ច្យុតចាកព្រហ្មលោកនាយនោះ មកចាប់បដិសន្ធិក្នុងផ្ទៃរបស់ព្រះអគ្គមហេសី នៃស្ដេចក្នុងក្រុងមិថិលា, ១០ ខែក្រោយមក បានប្រសូតចាកផ្ទៃនៃព្រះមាតា ។ ក្នុងថ្ងៃថ្វាយព្រះនាមរបស់រាជបុត្រ ព្រះរាជាបានអញ្ជើញព្រាហ្មណ៍ទាំងឡាយដែលស្ទាត់

---

ធម្ម, សេចក្ដីសន្ដោសចំពោះភរិយារបស់ខ្លួន, សេចក្ដីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការកុសល, ការរក្សាឧបោសថសីលតាមកាលកំណត់, អរិយមគ្គ, ព្រះពុទ្ធសាសនាទាំងមូល, អធ្យាស្រ័យ (ទាំង ១២ យ៉ាងនេះ) ហៅថា ព្រហ្មចរិយ ឬ ព្រហ្មចារ្យ (ហៅថា ព្រហ្មចរិយធម៌ ក៏បាន) ។

[១៣] ពូជ, ជំបួរ, ជួរ, ក្រសែ, របា, ត្រកូល, តំណត្រកូល, ជាតិ ។

ជំនាញខាងទាយនិមិត្តឲ្យមកចូលគាល់ ហើយទ្រង់ធ្វើការសាកសួរ ។ ព្រាហ្មណ៍ទាំងឡាយនោះ ពិនិត្យមើលលក្ខណៈរបស់រាជបុត្រសព្វគ្រប់ រួចក្រាបទូលដល់ព្រះរាជាថា ៖

"បពិត្រមហារាជ ព្រះកុមារនេះកើតមកនឹងបានជាអ្នកតវង្សផ្នួសរបស់ព្រះអង្គឡើងវិញ ពីព្រោះវង្សរបស់ព្រះអង្គ គឺជាវង្សផ្នួស, ក្រៅអំពីនេះ នឹងគ្មានបញ្ហាអ្វីទេ មហារាជ" ។

**នេមិកុមារ**

ក្រោយពេលសណ្ដាប់ទំនាយនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា "រាជកុមារនេះ កើតមកតវង្សរបស់យើងបីដូចដុំកង់រទេះ, ព្រោះដូច្នោះអញនឹងដាក់ឈ្មោះឲ្យរាជកុមារថា "**នេមិកុមារ**" ត្រិះរិះដូច្នេះហើយស្ដេចក៏ប្រកាសដាក់ព្រះនាមដល់រាជកុមារថា "**នេមិកុមារ**" តែម្ដងទៅ ។

នេមិកុមារ តែងត្រេកអរក្រៃលែង ក្នុងការឲ្យទានផង ក្នុងការរក្សាសីល ៥ ផង ក្នុងការធ្វើឧបោសថ[១៤]កម្មផង ចាប់តាំងពីគ្រាកុមារ

---

[១៤] (ន.) (បា.),(សំ.) (អ៊ុប៉ោសៈ-ថៈ ឬ--បោសត់; តាមទម្លាប់ថា-បោសុត) (ឧបោសធ) សីលសម្រាប់រក្សាជម្រះចិត្ត ។ ព. ពុ. សំដៅអដ្ឋង្គិកសីល (សីល៨) : សីលឧបោសថ, រក្សាឧបោសថ ។ ថ្ងៃសម្រាប់រក្សាឧបោសថសីល (ថ្ងៃសីល) : ថ្ងៃឧបោសថ ។

វ័យមកម៉្ទេះ ។ បន្ទាប់មក ព្រះបិតារបស់នេមិកុមារ ឃើញស្កូវលើព្រះសីសៈមានទំនងស្ដេចមុន ៗ ក៏ឲ្យស្រុកសួយដល់ខ្មាន់ព្រះកេស ប្រគល់រាជ្យដល់រាជបុត្រ ទ្រង់ចេញសាងផ្នួសអាស្រ័យនៅក្នុងព្រៃស្វាយ លុះដល់ទីបំផុតនៃជីវិត ទ្រង់បានទៅកើតនៅព្រហ្មលោក ។ ចំណែករាជបុត្រ ដែលសោយរាជ្យស្នងព្រះបិតានេះ មានព្រះនាមថា **ព្រះបាទនេមិរាជ** ទ្រង់បានត្រាស់បង្គាប់ឲ្យជាងសាងសង់នូវសាលាទាន ៥ កន្លែងគឺ ៖

- នៅក្បែរទ្វារនគរ ៤ កន្លែង គ្រប់ទិសទាំង ៤,
- នៅចំកណ្ដាលនគរ ១ កន្លែង

ហើយទ្រង់បានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ព្រោះតែទ្រង់មានព្រះអធ្យាស្រ័យក្នុងការធ្វើទាន ។ នៅក្នុងសាលាទាននីមួយ ៗ ព្រះបាទនេមិរាជបានចំណាយព្រះរាជទ្រព្យ ១០០.០០០ កហាបណៈ ៗ ធ្វើជាទានរៀងរាល់ថ្ងៃ សរុបក្នុងមួយថ្ងៃ ព្រះអង្គបានចំណាយព្រះរាជទ្រព្យ ៥០០.០០០ កហាបណៈ ។ សីល ៥ ទ្រង់តែងរក្សាជានិច្ច, ឧបោសថទ្រង់សមាទានរៀងរាល់ថ្ងៃបក្ស, ប្រជានុរាស្ត្រ ទ្រង់តែងតែណែនាំឲ្យចេះធ្វើបុណ្យទាំងឡាយ មានការឲ្យទានជាដើម និងទ្រង់តែងសម្ដែង

ធម៌ប្រាប់ផ្លូវសួគ៌ និងឲ្យប្រជានុរាស្ត្រចេះខ្លាចរអាដល់ភ័យក្នុងនរក ។ មនុស្សទាំងឡាយដែលបិតក្នុងឱវាទរបស់ព្រះអង្គ បាននាំគ្នាធ្វើបុណ្យទាំងឡាយមានទានជាដើម លុះច្យុតចាកអត្តភាពនោះ បានទៅកើតនៅទេវលោកនាយ យ៉ាងកកកុញ ត្រៀបត្រា តាន់តាប់ ដែលបណ្តាលឲ្យទេវលោកពេញពោរពាសដោយទេវបុត្រទេវធីតា, រីឯឋាននរកស្ទើរតែសូន្យទទេ គ្មានសត្វទៅកើត ។ គ្រានោះ ពពួកទេវតាទាំងឡាយក្នុងភពតាវត្តិង្ស[១៩] ប្រជុំគ្នាក្នុងសុធម្មាទេវសភាលើកឡើងថា ៖

"ឱហ្ន៎ ! អស្ចារ្យអ្វីម៉្លេះទេ នេមិរាជអាចារ្យរបស់យើង ! ពួកយើងរាល់គ្នាបានសោយទិព្វសម្បត្តិឥតព្រំដែននេះ ក៏ព្រោះអាស្រ័យព្រះបាទនេមិរាជអ្នកមានពុទ្ធញ្ញាណ" ។

លុះលើកឡើងដូច្នេះ មួយអង្គ ៗ ក៏ពណ៌នាគុណរបស់ព្រះមហាសត្តជាច្រើន ។ ការពណ៌នាសរសើរពីគុណរបស់ព្រះមហាសត្ត បានផ្សាយទៅគ្រប់ដណ្តប់មនុស្សលោក បីដូចប្រេងស្រោចលើផ្ទៃមហាសមុទ្រ គឺ

[១៩] (ន.) (បា.),(សំ.) (តាវត៌-តឹង) (តាវត្តឹស; ត្រយស្ត្រឹសតិ) ឈ្មោះឋានកាមាវចរសួគ៌ជាន់ទី ២ (ឋានត្រ័យត្រិង្ស) ។

មនុស្សនិងទេវតាទាំងឡាយតែងសរសើរថា អ្នកប្រាជ្ញទាំងឡាយដែលមានប្រាជ្ញាជាគ្រឿងពិចារណាកើតឡើងក្នុងលោក អស្ចារ្យអ្វីម្ល៉េះទេ ! ។

**ស្តេចសក្កៈដោះចម្ងល់ព្រះបាទនេមិរាជ**

គ្រាមួយ ស្តេចនេមិរាជបានសមាទានឧបោសថ ក្នុងថ្ងៃ ១៥ កើត ទ្រង់ដោះអាភរណៈ[១៦] ទាំងពួង ហើយផ្ទំលើក្រឡាព្រះបន្ទំ លង់លក់ក្នុងយាមពីរ, ដល់យាមចុងក្រោយ ទ្រង់បានតើនឡើងហើយប្រថាប់គង់ពែនភ្នែន មានពិចារណាថា ៖

"អញឲ្យទានច្រើន រាប់មិនអស់ ប្រមាណមិនបាន ដល់ពពួកមហាជន និងតែងរក្សាសីលខ្ជាប់ខ្ជួន តើការឲ្យទានមានផលច្រើនជាងផលនៃព្រហ្មចរិយៈ ឬផលនៃព្រហ្មចរិយៈមានច្រើនជាងផលនៃការឲ្យទាន" ។

[១៦] (ន.) (សំ.),(បា.) (--ភៈរៈណៈ) (អាភរណ) គ្រឿងប្រដាប់កាយ, អលង្ករណ៍, អលង្ការ : ស្អិតស្អាងរាងកាយដោយអាភរណៈដ៏រុងរឿង ។ ខ្មែរប្រើតាមសម័យនិយមហៅគ្រឿងឥស្សរិយយស ឬគ្រឿងតម្កើងកិត្តិយស (មេដាយ) ថា អាភរណៈ ដែរ : អាភរណៈអស្សឫទ្ធិ, អាភរណៈសេនា; មុនីសារាភរណៈ ឬ មុនីសារាភរណ៍ ។(ព. កា.) : អម្ពរស្អាតស្អំ មានអាភរណ៍ផ្សំ ថែមផងរូបប្រាណ សមនឹងយសសក្តិ អនគ្ឃថ្កើនថ្កាន អ្នកផងរាប់អាន បានពេញមុខមាត់ ។

ត្រិះរិះធ្ងល់ដូច្នេះហើយ ព្រះបាទនេមិរាជទ្រង់នៅតែពុំអាចកាត់បង់សេចក្ដីសង្ស័យរបស់ព្រះអង្គបាន ។ ក្នុងខណៈនោះ ភពរបស់សក្កទេវរាជកើតអាការៈក្ដៅធួលឡើង ទ្រង់រំពឹងមើលទៅឃើញស្ដេចនេមិរាជកំពុងមានក្ដីសង្ស័យដូច្នោះ ស្ដេចទ្រង់ព្រះមានបំណងជម្រះមន្ទិលសង្ស័យរបស់ស្ដេចនេមិរាជឲ្យដាច់ស្រឡះ ទ្រង់ក៏យាងមកតែមួយអង្គឯងយ៉ាងរហ័ស បណ្ដាលឲ្យនិវេសន៍[១៧] ទាំងមូលមានពន្លឺភ្លឺសាយសុះរួចទ្រង់ចូលទៅកាន់បន្ទប់ ផ្សាយឱភាស[១៨] កម្ចាត់បង់ងងឹត ឈរនៅឰដ៏អាកាស ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ។ ព្រះបាទនេមិរាជទ្រង់ព្រឺព្រះលោមាបានសួរថា ៖

"តើអ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កបុរិន្ទទៈ ? រស្មីបែបនេះខ្ញុំពុំដែលធ្លាប់ឃើញ ធ្លាប់ឮឡើយ ។ បពិត្រអ្នកដ៏ចម្រើន អ្នកចូរប្រាប់ឈ្មោះឲ្យខ្ញុំស្គាល់ផង" ។

---

[១៧] (ន.) (បា.) (និវេសន) ទីសម្រាប់នៅអាស្រ័យជានិច្ច ច្រើនប្រើជា (វ. ស.) : ព្រះនិវេសន៍ គឺព្រះរាជដំណាក់ ។

[១៨] ពន្លឺ ។

សក្កទេវរាជជ្រាបថា ព្រះបាទនេមិរាជភ័យស្ទុតព្រឺព្រះលោមាហើយ ទើបទ្រង់តបថា ៖

"ខ្ញុំជាព្រះឥន្ទជាធំជាងទេវតា មកកាន់សម្នាក់ព្រះអង្គ ។ បពិត្រព្រះអង្គជាធំជាងមនុស្ស សូមទ្រង់កុំភ័យព្រឺព្រះលោមាឡើយ ព្រះអង្គមានបំណងសួរប្រស្នាណានឹងទូលបង្គំ ? សូមទ្រង់សួរមកចុះ" ។

ព្រះបាទនេមិរាជបានព្រះឥន្ទ្រាធិរាជផ្តល់ឱកាសក៏ទ្រង់ត្រាស់សួរថា ៖

"បពិត្រទេវរាជជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទាននិងព្រហ្មចរិយៈ ពីរនេះណាមួយមានផលច្រើនជាង ?"

សក្កទេវរាជឆ្លើយតបថាផលនៃព្រហ្មចរិយៈច្រើនជាងផលនៃទាន រួចត្រាស់ជាបន្តថា ៖

"បុគ្គលកើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈឱនថយ កើតជាទេវតា ដោយព្រហ្មចរិយៈជាកណ្តាល បរិសុទ្ធស្អាត ដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។ ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ តែង

*ទៅកើតក្នុងពួកព្រហ្ម[១៩] ណា ស្ថានពួកព្រហ្មនោះ ជាទីដែលបុគ្គលអ្នកសូម មិនងាយនឹងបានឡើយ" ។*

---

[១៩] *ទេវតាដែលកើតក្នុងព្រហ្មលោកដោយអំណាចផលនៃឈានចិត្តមាន ២ ពួកគឺ ១-**រូបព្រហ្ម** ពួកព្រហ្មមានរូប ស្ថិតនៅក្នុងរូបភព ឬហៅថា រូបាវចរភូមិទាំង ១៦ ជាន់គឺ (ក) **ពួករូបព្រហ្មបដិសន្ធិដោយបឋមឈានចិត្ត មាន ៣ ថ្នាក់គឺ** (១) **ព្រហ្មបារិសជ្ជា** ពួកព្រហ្មដែលជាបរិវាររបស់មហាព្រហ្ម; (២) **ព្រហ្មបុរោហិតា** ពួកព្រហ្មជាបុរោហិតរបស់មហាព្រហ្ម; (៣) **មហាព្រហ្មា** ពួកស្ដេចមហាព្រហ្ម ។ **ខ-ពួករូបព្រហ្មដែលបដិសន្ធិដោយទុតិយជ្ឈានចិត្តមាន ៣ ថ្នាក់គឺ** (៤) **បរិត្តាភា** ពួកព្រហ្មមានពន្លឺតិច; (៥) **អប្បមាណាភា** ពួកព្រហ្មមានពន្លឺប្រមាណមិនបាន; (៦) **អាភស្សរា** ពួកព្រហ្មមានពន្លឺផ្សាយចែងចាំងទៅ ។ **គ-ពួករូបព្រហ្មដែលបដិសន្ធិដោយតតិយជ្ឈានចិត្ត មាន ៣ ថ្នាក់គឺ** (៧) **បរិត្តសុភា** ពួកព្រហ្មមានពន្លឺភ្លឺល្អស្អាតប្រមាណតិច; (៨) **អប្បមាណសុភា** ពួកព្រហ្មមានពន្លឺល្អស្អាតប្រមាណមិនបាន; (៩) **សុភកិណ្ហា** ពួកព្រហ្មមានពន្លឺល្អស្អាតច្បាស់ទែង ។ **ឃ-ពួករូបព្រហ្មដែលបដិសន្ធិដោយចតុត្ថជ្ឈានចិត្ត មាន ៧ ថ្នាក់គឺ** (១០) **វេហប្ផលា** ពួកព្រហ្មមានផលបុណ្យច្រើនក្រៃ; (១១) **អសញ្ញីសត្តា** ពួកសត្វមិនមានសញ្ញា ។ (១២) **អវិហា** ពួកព្រហ្មដែលមិនឃ្លាតចាកសម្បត្តិរបស់ខ្លួន ដោយឆាប់រហ័ស គឺពួកព្រហ្មដែលតាំងនៅបានយូរ; (១៣) **អតប្បា** ពួកព្រហ្មដែលមិនធ្វើសេចក្ដីក្ដៅក្រហាយដល់នរណា ៗ ឬដែលមិនកើតសេចក្ដីក្ដៅក្រហាយជាមួយនឹងនរណា ៗ; (១៤) **សុទស្សា** ពួកព្រហ្មដែលស្រស់ស្អាតគួរពិតពិលរមិលមើល; (១៥) **សុទស្សី** ពួកព្រហ្មដែលសម្លឹងឃើញច្បាស់ល្អ ឬអ្នកមើលឃើញច្បាស់លាស់; (១៦) **អកនិដ្ឋា** ពួកព្រហ្មដែលមិនមានភាពអន់ថយ ឬតូចជាងអ្នក, អ្នកខ្ពង់ខ្ពស់បំផុត ។ (ចាប់តាំងអំពី*

លុះបំភ្លឺពីការប្រព្រឹត្តដោយព្រហ្មចរិយៈដូច្នេះហើយ ទ្រង់បង្ហាញព្រះរាជាទាំងឡាយក្នុងអតីតកាល ដែលពួកទ្រង់ឲ្យទានជាច្រើនហើយមិនអាចកន្លងនូវកាមាវចរភូមិបាន មានឈ្មោះដូចតទៅនេះ ៖

"បពិត្រមហារាជ មានព្រះរាជាមួយអង្គព្រះនាមទុទីបៈក្នុងក្រុងពារាណសី ទ្រង់ធ្វើទានហើយ ក្រោយអស់ព្រះជន្មបានកើតក្នុង-កាមាវចរភូមិ ។ មានព្រះរាជា ៨ អង្គទៀត គឺព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអត្ថកៈ ១ ព្រះបាទអស្សកៈ ១ ព្រះបាទបថុទ្ធនៈ ១ និងមានស្តេចដទៃច្រើនអង្គ រួមទាំងពួកព្រាហ្មណ៍ជាច្រើននាក់ទៀត ទោះជាបានបូជាយញ្ញច្រើននិងឲ្យទានជាអនេក-

---

លេខ ១២-១៣-១៤-១៥-១៦ ទាំង ៥ នេះ ហៅថា **សុទ្ធាវាសព្រហ្ម ឬសុទ្ធាវាសភូមិ** ក៏បាន "ពួកព្រហ្មដែលរស់នៅដោយសេចក្តីបរិសុទ្ធ ឬទីកន្លែងនៅរបស់អ្នកមានសេចក្តីបរិសុទ្ធ គឺទីកំណើតរបស់ព្រះអនាគាមិបុគ្គល") ។ ២-**អរូបព្រហ្ម** ពួកព្រហ្មឥតរូប ស្ថិតនៅក្នុងអរូបភព ឬហៅថា អរូបាវចរភូមិទាំង ៤ ជាន់គឺ (១) **អាកាសានញ្ចាយតនភូមិ** ភូមិជាទីចូលដល់ភាវៈនៃអាកាសមិនមានទីបំផុត; (២) **វិញ្ញាណញ្ចាយតនភូមិ** ភូមិជាទីចូលដល់នូវភាវៈនៃវិញ្ញាណមិនមានទីបំផុត; (៣) **អាកិញ្ចញ្ញាយតនភូមិ** ភូមិជាទីចូលដល់នូវភាវៈមិនមានអ្វី ៗ ; (៤) **នេវសញ្ញានាសញ្ញាយតនភូមិ** ភូមិជាទីចូលដល់នូវភាវៈមានសញ្ញាក៏មិនមែន ភាវៈមិនមានសញ្ញាក៏មិនមែន ។

*ប្បការយ៉ាងណាក៏ដោយ ក៏មិនរួចផុតអំពីអត្តភាពជាប្រេតពោល គឺកាមាវចរភូមិឡើយ" ។*

**កំណត់សម្គាល់**

*ត្រង់នេះ សក្កទេវរាជប្រើពាក្យហៅ កាមាវចរទេវតា ថា* **ប្រេត** *ព្រោះនៅមានទុក្ខលំបាក ដោយសេចក្តីប្រាថ្នារហូត និងព្រោះហេតុជាទីតាំងនៃកិលេស មានរូបជាដើម ។*

*សមដូចពុទ្ធតម្រាស់ថែងទុកថា ៖*

*"ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង រមែងមិនត្រេកអរ (ត្រេកអរតែក្នុងការនៅច្រឡូកច្រឡំដោយពួក) ជនទាំងឡាយណា មិនមានបីតិ ដែលកើតអំពីវិវេក[២០]ទេ ជនទាំងឡាយនោះ ទុកជាមានភោគៈស្មើដោយព្រះឥន្ទ្រក៏ដោយចុះ*

---

[២០] (ន.) (សំ.),(បា.) *សេចក្តីស្ងាត់; ការស្ងាត់ចាកអារម្មណ៍សៅហ្មង; ការពិចារណាឃើញសេចក្តីពិត ។ គុ. ស្ងាត់ ។ វិវេកដ្ឋាន ឬ--ស្ថាន ឋានស្ងាត់ ។ វិវេកភាព* (--ក:-ភាប) *ភាវៈស្ងាត់ ។ វិវេការម្មណ៍* (បា. < *វិវេក* + *អារម្មណ*) *អារម្មណ៍ស្ងាត់* (ចាកសេចក្តីសៅហ្មង) ។ (ព. ពុ.) : *កាយវិវេក* (--យ៉:--) *សេចក្តីស្ងាត់កាយ; ចិត្តវិវេក* (ចិត-ត:--) *សេចក្តីស្ងាត់ចិត្ត; ឧបធិវិវេក* (អ៊ុ-ប៉:-ធិ--) *សេចក្តីស្ងាត់កិលេស ។*

ក៏ឈ្មោះថាជាបុគ្គលកម្សត់ មានសេចក្ដីសុខ ព្រោះកិរិយា

អាស្រ័យនូវបុគ្គលដទៃដោយពិត" ។

លុះសម្ដែងអំពីផលព្រហ្មចរិយៈថាមានផលច្រើនជាងផលនៃទាន យ៉ាងនេះហើយ សក្កទេវរាជបានបង្ហាញពួកតាបសអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ រួចហើយទៅកើតនៅព្រហ្មលោក ឆ្ងងផុតកពប្រេត ដូចមានមានឈ្មោះតទៅនេះ ៖

"ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោមយាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះកាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គទៀតគឺ ឥសីឈ្មោះអង្គិរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកន្តិ ១ ទាំង ១១ រូបនោះជាអនាគារិយបុគ្គល[២១] មានតបធម៌ បានឆ្លងផុតពីកាមាវចរភូមិដោយពិត" ។

[២១] បុគ្គលមិនមានការគ្រប់គ្រងផ្ទះ ។

លុះពណ៌នាអំពីការប្រព្រឹត្តព្រហ្មចរិយធម៌ ថាមានផលច្រើនជាងផលនៃទានតាមរយៈនៃការបានឮយ៉ាងនេះរួចហើយ សក្កទេវរាជបាននាំមកនូវរឿងដែលឃើញដោយផ្ទាល់ទៀតថា ៖

"បពិត្រមហារាជ ក្នុងកាលដ៏យូរលង់ណាស់មកហើយ នៅព្រៃហិមពាន្ត មានទន្លេមួយ ឈ្មោះថា **សីទា** ហូរកាត់តាមចន្លោះសុវណ្ណបព៌តទាំងពីរ ទឹកជ្រៅណាស់ សូម្បីតែសំពៅក៏លំបាកឆ្លងផុតទៅបាន ។ ព្រោះហេតុអ្វី ? ព្រោះថា ទន្លេសីទានោះមានទឹកល្អិតសុខុមជាពន់ ពេកណាស់ ដោយហោចទៅ សូម្បីតែរោមកន្ទុយក្ងោកដែលធ្លាក់នៅលើទន្លេនោះ ក៏មិនអាច តាំងនៅបាន រមែងទៀងតែលិចចុះទៅបាតក្រោម ដោយសារតែទឹកទន្លេសុខុមពន់ពេក ។ ដោយហេតុនោះឯង ទើបទន្លេនោះ ហៅថា **សីទា** ។ នៅតាមសងខាងទន្លេសីទា មានកញ្ចនបព៌ត (ភ្នំមាស) ជាច្រើននៅប្រ៉ប្រនឹងច្រាំង ភ្លឺរុងរឿងចិញ្ចែងចិញ្ចាច ដែលមានពណ៌មើលទៅហាក់បីដូចជាភ្លើងអគ្គីឆេះដើមបបុស ។ រីឯដើមក្រស្នាសោត ក៏ដុះឡោមព័ទ្ធជុំវិញឆ្នេរទន្លេ ច្រើនស្អេកស្កះជះក្លិនគន្ធពិដោរឈ្ងុយឈ្ងប់ ។ សូម្បីតែភ្នំទាំងឡាយដទៃ នៅតំបន់នោះ សោតសឹងតែមានព្រៃក្រាស់ ដុះលាស់ជុំវិញចន្លោះភ្នំទាំងនោះ ដេរដាសដោយរុក្ខជាតិ ទ្រទ្រង់ផ្លែផ្កា ។ ក្នុងទឹកដី

ជាភូមិភាគដ៏គួរឲ្យរីករាយយ៉ាងនេះ មានឥសី ១០.០០០ អង្គនៅស្នាក់អាស្រ័យ ។ ឥសីទាំងអស់នោះ សុទ្ធសឹងតែជាអ្នកបានអភិញ្ញាសមាបត្តិ ពុំសេសសល់អង្គណាជាអ្នកខ្វះ គុណធម៌ឡើយ ។ ដល់វេលាភិក្ខាចារ បណ្តាឥសីទាំងនោះ មានឥសីពួកខ្លះនិមន្តទៅឧត្តរកុរុទ្វីប, ពួកខ្លះទៅនាំមកនូវផ្លែព្រីងនៅឯមហាជម្ពូទ្វីប, ពួកខ្លះទៅនាំមកនូវផលាផលដ៏មានរស ជាតិផ្អែមត្រជាក់នៅឯព្រៃហិមពាន្ត មកឆាន់ជាអាហារញ៉ាំងជីវិតអាត្មាឲ្យប្រព្រឹត្តទៅ , ពួកខ្លះក៏ទៅកាន់នគរផ្សេង ៗ ក្នុងទឹកដីជម្ពូទ្វីប ។ ពុំមានឥសីអង្គណាមួយ ត្រូវសេតណ្ហាគ្រប់ សង្កត់ដល់សន្តានចិត្តលោកតិចតួចឡើយ លោករស់នៅដោយសេចក្តីសុខក្នុងឈាន ។ នៅគ្រានោះ មានតាបសមួយរូប ហោះតាមអាកាសវេហាស៍ យាត្រាឆ្ពោះទៅកាន់ក្រុងពារាណសី ស្លៀកដណ្តប់សំពត់យ៉ាងរៀបរយ ស្អាតបាត ចុះត្រាច់ចរបិណ្ឌបាត ដើរសង្វាតរហូតទៅដល់ទ្វារគេហដ្ឋានរបស់បុរោហិត ។ បុរោហិតមានសេចក្តីជ្រះថ្លាចំពោះអាការស្ងប់រំងាប់របស់តាបស បាននិមន្តលោកឲ្យចូល ខាងក្នុងនិវេសន៍ អង្គាសភោជន ផ្គត់ផ្គង់អស់ ២ ទៅ ៣ ថ្ងៃ លុះមកើតសេចក្តីស្និទ្ធស្នាលចំពោះគ្នានឹងគ្នាហើយ ក៏បានសាកសួរលោកថា "បពិត្រលោកម្ចាស់ដ៏ចម្រើន

តើលោកម្ចាស់ ស្នាក់នៅឯណា ព្រះគុណ?" ក្រោយពីតាបស ប្រាប់ថាលោកស្នាក់នៅទីឯណោះដូច្នេះ ហើយ បុរោហិតសួរ ទៀតថា "ចុះលោកម្ចាស់ស្នាក់នៅទីនោះតែមួយអង្គឯង ឬក៏ មានតាបស ដទៃទៀតដែរ?" តាបសតបថា "ថាម៉េចលោកមាន អាយុ នៅតំបន់នោះ មានឥសីច្រើនរូប ដល់ទៅ ១០.០០០ អង្គ សុទ្ធសឹងតែបានអភិញ្ញាសមាបត្តិគ្រប់អង្គ ។ បុរោហិតបានស្តាប់ នូវ គុណរបស់តាបសទាំងឡាយនោះ កើតចិត្តនឹកភ្នកទៅរក ផ្នួស ចង់បួសជាឥសីដែរ ទើបគាត់ ជម្រាបប្រសាសន៍តាបសថា "បពិត្រលោកម្ចាស់ សូមមេត្តានាំខ្ញុំព្រះករុណាទៅទីនោះ បំបួស ខ្ញុំព្រះករុណាផង ទានប្រោស" ។ តាបសតបថា "អ្នកមានអាយុ លោកជាមន្ត្រីមានយសសក្តិ របស់ស្តេចផែនដី មន្ត្រី ៗ នោះ អាត្មាភាពមិនអាចឲ្យបួសបានទេ" ។ បុរោហិតថា "បពិត្រលោក ម្ចាស់ បើដូច្នោះ ចាំខ្ញុំព្រះករុណាទៅក្រាបទូលលាព្រះមហា ក្សត្រនៅថ្ងៃនេះ ដល់ថ្ងៃ ស្អែកសូមលោកម្ចាស់និមន្តមកទៀតកុំ ខាន" ។ តាបសក៏ទទួលការនិមន្តរបស់បុរោហិត ។

បុរោហិតនោះ បន្ទាប់ពីបានបរិភោគអាហារពេលព្រឹករួច គាត់បានចូលទៅគាល់ព្រះរាជាក្រាបទូលថា "បពិត្រសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ មានបំណងចង់បួស ក្រាបទូល" ។ ព្រះរាជា

សួរថា "អ្នកនឹងចេញទៅបួស ព្រោះហេតុអ្វី ?" បុរោហិតពិតទូលថា "បានជាចង់បួស ព្រោះទូលបង្គំបានឃើញទោសក្នុងកាមទាំងឡាយ និងឃើញអានិសង្សក្នុងនេក្ខម្ម" ។ ព្រះរាជាអនុញ្ញាតថា "បើដូច្នោះ ចូរអ្នកបួសចុះ លុះបួសរួចហើយ ម្តេចម្តា អញ្ជើញមកជួបយើងផងណា" ។ បុរោហិតទទួលព្រះរាជឱង្ការត្រឡប់ទៅកាន់គេហដ្ឋានខ្លួនវិញ ប្រៀនប្រដៅកូននិងប្រពន្ធ ប្រគល់ឲ្យទ្រព្យសម្បត្តិសព្វគ្រប់ រួចប្រមូលយកបរិក្ខារសម្រាប់អ្នកបួសដើម្បីខ្លួន នៅអង្គុយរង់ចាំមើលផ្លូវតាបសនិមន្តមក ។ ចំណែកតាបសហោះហើរតាមអាកាសដូចសត្វដង ចូលទៅខាងក្នុងនគរ រួចបានចូលទៅកាន់លំនៅឋានរបស់បុរោហិត។ បុរោហិតអង្គាសចង្ហាន់តាបសដោយសេចក្តីគោរព ហើយពិតទូលថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាត្រូវ ធ្វើដូចម្តេច ?" តាបសក៏នាំបុរោហិតនោះទៅខាងក្រៅនគរ រួចក៏ចាប់ដៃបុរោហិតនាំទៅព្រៃហិមពាន្តមួយរំពេច ដោយអានុភាពឫទ្ធិរបស់ខ្លួន បំបួសបុរោហិតជាឥសីហើយ ដល់ថ្ងៃស្អែកឡើង ឲ្យតាបសបុរោហិតនោះស្នាក់នៅក្នុងកន្ទែង ឯខ្លួនលោកទៅស្វះស្វែងរកចង្ហាន់មកជូន និងប្រាប់ឲ្យភាវនាកសិណបរិកម្ម ។ ដោយរយៈពេលតែ ២ ទៅ ៣ ថ្ងៃប៉ុណ្ណោះ តាបសបុរោហិត

នោះ ក៏ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ហើយក៏ចេះហោះហើរត្រាច់ចរស្វែងរកចង្ហាន់ឆាន់បានដោយខ្លួនឯង ។ ចំណេរកាលក្រោយមក តាបសបុរោហិតនឹកឃើញថា "អាត្មាអញបានឲ្យសេចក្ដីប្ដេជ្ញាដល់ព្រះរាជាថានឹងចូលទៅជួបទ្រង់ អញនឹងខានទៅគាល់ព្រះអង្គមិនបានទេ" ក៏ថ្វាយ បង្គំលាតាបសទាំងឡាយ ហោះមកកាន់ក្រុងពារាណសី ត្រាច់រកភិក្ខារៀងរាបទៅដល់ទ្វារ ព្រះរាជវាំង ។ ព្រះរាជាទតឃើញតាបសក៏ចំណាំបានជាក់ជាមន្ត្រីដើមរបស់ព្រះអង្គ ក៏បាន និមន្តឲ្យចូលទៅខាងក្នុងព្រះរាជនិវេសន៍ ធ្វើសក្ការបូជា ហើយក្រាបទូលសួរតាបសថា "បពិត្រលោកម្ចាស់ តើលោកម្ចាស់ស្នាក់នៅឯណា?" តាបសពោលថា "អាត្មាភាពស្នាក់នៅ ក្បែរឆ្នេរទន្លេសីទាដែលឋិតនៅចន្លោះភ្នំកញ្ចនបព៌ត តំបន់ព្រៃហិមពាន្ត ទិសភាគខាងជើង មហាបពិត្រ" ។ ព្រះរាជាសួរថា "បពិត្រលោកម្ចាស់ តើលោកម្ចាស់នៅទីនោះតែមួយអង្គឯង ឬមានតាបសផ្សេង ទៀតដែរ?" តាបសទូលថា "មានព្រះរាជឱង្ការដូច្នោះធ្វើអ្វីទៅ មហាបពិត្រ នៅទីនោះមាន ឥសីដល់ទៅ ១០.០០០ អង្គ សោតសឹងតែជាអ្នកបានអភិញ្ញានិងសមាបត្តិគ្រប់អង្គ ឥតសេស សល់អង្គណាឡើយ ។ ក្រោយពីទ្រង់ព្រះសណ្ដាប់នូវគុណរបស់តាបស

ទាំងឡាយនោះហើយ ព្រះរាជាមានព្រះរាជហឫទ័យចង់ថ្វាយ ចង្ហាន់ដល់តាបសទាំងអស់នោះ ទើបបាន ក្រាបទូលតាបស បុរោហិតថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមានបំណងចង់ ថ្វាយចង្ហាន់ ដល់ឥសីទាំងឡាយនោះ តើខ្ញុំព្រះករុណាត្រូវធ្វើ ដូចម្ដេច ?" តាបសទូលពិតថា "បពិត្រមហារាជ ឥសីទាំងឡាយ នោះ មិនជាប់ជំពាក់នឹងរសដែលត្រូវដឹងដោយអណ្ដាតទេ មិន អាចនិមន្តលោកមកទីនេះបានទេ មហាបពិត្រ" ។ ព្រះរាជាតប ថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាសូមពឹងពាក់ពំនាក់ អាស្រ័យលោកម្ចាស់ដើម្បីបានប្រគេនចង្ហាន់ដល់តាបសទាំង ឡាយនោះ ដូច្នេះសូមលោកម្ចាស់ជួយប្រាប់ឧបាយដល់ខ្ញុំព្រះ ករុណាផង ទានប្រោស" ។ តាបសតបថា "មហារាជ បើដូច្នោះ ថាបើព្រះអង្គសព្វព្រះរាជហឫទ័យថ្វាយទានដល់តាបស ទាំងឡាយនោះ សូមព្រះអង្គយាងចេញពីទីនេះទៅរស់នៅក្បែរ ទន្លេសីទា ថ្វាយទានដល់ ពួកលោកចុះ មហាបពិត្រ" ។ ព្រះរាជាទទួលសេចក្ដីណែនាំរបស់តាបស បានបញ្ជាឲ្យដឹក ឧបករណ៍គ្រប់បែបយ៉ាង ហើយយាងចេញទៅមួយអន្លើដោយ ចតុរង្គសេនា ដរាបដល់ព្រំប្រទល់ដែនរដ្ឋសីមារបស់ព្រះអង្គ ។

គ្រានោះ តាបសបាននាំព្រះរាជាអង្គនោះ មួយអន្លើដោយសេនា ទៅទៀបឆ្នេរទន្លេសីទា ដោយអានុភាពរបស់ខ្លួន ឲ្យព្រះអង្គបោះបន្ទាយនៅក្បែរឆ្នេរទន្លេ រួចបានហោះទៅកាន់លំនៅឋានរបស់ខ្លួនតាមអាកាស ដល់ថ្ងៃស្អែកឡើង លោកបាននិមន្តមកវិញ ។ គ្រានោះ ព្រះរាជាបាននិមន្តតាបសឲ្យឆាន់ដោយសេចក្ដីគោរព ហើយបានពិតទូលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តានាំយកឥសីទាំង ១០.០០០ អង្គ មកទីនេះកុំខាន" ។ តាបសយល់ព្រមតាមសេចក្ដីនិមន្ត ហើយបាននិមន្តទៅវិញ ដល់ថ្ងៃបន្ទាប់ ក្នុងវេលាភិក្ខាចារ លោកបានពិតទូលដល់ឥសីទាំងឡាយនោះថា "បពិត្រអ្នកនិរទុក្ខទាំងឡាយ ព្រះរាជាក្រុងពារាណសី បានយាងមកដើម្បីថ្វាយចង្ហាន់ដល់លោកទាំងឡាយ ស្ដេចកំពុងគង់នៅក្បែរឆ្នេរទន្លេគង្គា និមន្តលោកម្ចាស់ដើម្បីឆាន់ក្នុងថ្ងៃស្អែក, ដើម្បីសេចក្ដីអនុគ្រោះដល់ព្រះរាជា សូមលោកម្ចាស់ទាំងឡាយ និមន្តទៅបន្ទាយរបស់ព្រះអង្គដើម្បីទទួលចង្ហាន់" ។ តាបសទាំងឡាយនោះ បានយល់ព្រម បានធ្វើដំណើរតាមអាកាសទៅចុះក្នុងទីមិនឆ្ងាយអំពីបន្ទាយ ។ ព្រះរាជាទតឃើញតាបសទាំងឡាយនោះហើយ បានយាងទៅធ្វើបដិសណ្ឋារកិច្ចទទួលនិមន្តចូលក្នុងបន្ទាយ ឲ្យគង់លើអាសនៈ

ដែលក្រាលបម្រុង ប្រគេនចង្ហាន់ប្រណីត ៗ ដល់ឥសីគណៈឲ្យឆ្អែតស្កប់ស្កល់ មានសេចក្ដីជ្រះថ្លាចំពោះឥរិយាបថរបស់តាបសទាំងឡាយនោះពេក ក៏បាននិមន្តពួកលោកដើម្បីឆាន់ក្នុងថ្ងៃស្អែកជាបន្ត ។ ព្រះរាជាបានថ្វាយចង្ហាន់ជារបៀបយ៉ាងនេះ ដល់តាបស ១០.០០០ អង្គ អស់កាល ១០.០០០ ឆ្នាំ ។ កាលកំពុងថ្វាយទាន ព្រះរាជាបានឲ្យគេរៀបចំកសាងរាជធានីនៅតំបន់នោះ និងបញ្ជាឲ្យគេធ្វើស្រែចម្ការ ។ បពិត្រមហារាជព្រះរាជាក្នុងគ្រានោះ មិនគឺអ្នកដទៃណាឡើយ គឺជាទូលបង្គំនេះឯងដែលជាបុគ្គលឆ្នើមលើសគេដោយសារការឲ្យទាន ពិតណាស់ ដោយការឲ្យទាន ទូលបង្គំនេះឯងទៅជាបុគ្គលប្រសើរបំផុត ទាស់ត្រង់ថាឲ្យមហាទានម៉្លឹងហើយមិនអាចឆ្លងបេតលោកនេះកើតនៅព្រហ្មលោកនាយបាន ។ ចំណែកឯតាបសទាំងឡាយទាំងពួងនោះ សោយចង្ហាន់ដែលទូលបង្គំប្រគេនហើយ ឈានកន្លងនូវកាមាវចរលោកបាន ហើយកើតនៅឯព្រហ្មលោក ។ សាច់រឿងនេះឯងដែលបណ្ឌិតត្រូវជ្រាបថា "ការនៅក្នុងព្រហ្មចរិយៈ មានផលប្រសើរលើសលុបជាងផលនៃទាន" ។

ព្រះឥន្ទ្រាធិរាជ លុះប្រកាសភាពប្រសើរលើសលុបរបស់ខ្លួន ដោយការឲ្យទានហើយ ក៏បានប្រកាសនូវគុណរបស់ឥសីទាំងឡាយនោះជាបន្តថា ឥសីទាំងឡាយ ជាអ្នកមានសេចក្តីសង្រួមក្នុងសីល មានការទូន្មាននូវឥន្ទ្រិយ ដោយគុណទាំងឡាយនោះ ពួកលោកប្រព្រឹត្តសមាទាននូវវ័តដ៏ខ្ពង់ខ្ពស់ជាប់មិនដាច់ គឺលោកនិមន្តទៅទីណាមិនប្រទូកប្រទាំ ដោយគណៈ ត្រាច់ទៅតែម្នាក់ឯង មានចិត្តតាំងមាំក្នុងឧបចារសមាធិ ឬអប្បនាសមាធិ ។ ទូលបង្គំជាខ្ញុំបានទំនុកបម្រុងតាបសទាំងឡាយនោះ ដែលជាអ្នកមានតបៈបែបនេះ ។ បពិត្រមហារាជ បណ្តាតាបសទាំង ១០.០០០ អង្គនោះ តាបសរូបណាក៏ជាអ្នកទៀងត្រង់ ព្រោះពុំមានអាការៈគ្រាំគ្រងដោយកាយជាដើម ទូលបង្គំជាខ្ញុំពុំរើសអើងថា តាបសនោះមានជាតិថោកទាប ឬ តាបសនោះមានជាតិខ្ពង់ខ្ពស់ ដូច្នេះឡើយ មានតែសេចក្តីជ្រះថ្លាចំពោះគុណរបស់តាបសទាំងឡាយនោះ និងតែងនមស្ការតាបសទាំងអស់នោះសព្វ ៗ វេលា ពុំដែលខកខានអ្វីទេ ។ ព្រោះហេតុអ្វី ? សូមជ្រាបថា សត្វទាំងឡាយទាំងពួងគ្រប់វណ្ណៈទាំងអស់ មានកម្មជាផៅពង្ស មានកម្មជាទីរលឹក ។ វណ្ណៈទាំងពួងអ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរកជាខាងក្រោម ឯវណ្ណៈទាំងអស់ដែលបានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងដល់នូវភាពបរិសុទ្ធ ។

លុះសក្កទេវរាជពោលដូច្នេះហើយ លោកក៏ផ្តល់ឱវាទដល់ស្តេចនេមិរាជថា ៖

"បពិត្រមហារាជ ពិតមែនតែព្រហ្មចរិយៈនេះមានផលច្រើនជាងទាន ប៉ុន្តែគុណធម៌ទាំងពីរនេះ ស្រេចលើតែវិតក្កៈ[២២]របស់មហាបុរសទេ ។ ហេតុនោះ ព្រះអង្គកុំប្រហែសធ្វេសក្នុងកុសលទាំងពីរនោះ សូមទ្រង់ឲ្យទានផង រក្សាសីលផងចុះ" ។

លុះប្រទានដំបូន្មានចំពោះព្រះបាទនេមិរាជជាធំក្នុងដែនវិទេហៈរួចហើយ សក្កទេវរាជទ្រង់ត្រឡប់ទៅលំនៅព្រះអង្គនៅឯឋានសួគ៌វិញ ។

**ពួកទេវតានឹកព្រះបាទនេមិរាជ**

គ្រានោះ ពពួកទេវតាទាំងឡាយក្រាបទូលសួរសក្កទេវរាជថា ៖

"បពិត្រមហារាជ ព្រះអង្គបាត់ទៅឯណា ម្តេចមិនឃើញ ?"

សក្កទេវរាជប្រាប់ថា ៖

"ហៃអស់លោក ! ព្រះបាទនេមិរាជក្នុងក្រុងមិថិលាកើតក្តីមន្ទិលសង្ស័យ ។ ខ្ញុំទៅឆ្លើយប្រស្នារបស់ព្រះអង្គ ពន្យល់ទ្រង់ឲ្យអស់មន្ទិលសង្ស័យ ហើយទើបតែមកវិញអម្បាញ់មិញនេះឯង"

---

[២២] (ន.) (បា.),(សំ.) (--ត័ក-កៈ ឬ --តក់) (វិតក៌) សេចក្តីត្រិះរិះ, ជញ្ជឹង, រំពឹងគិត ។

សក្កទេវរាជ ត្រាស់ជាបន្តថា ៖

"ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នករាល់គ្នាទាំងប៉ុន្មានដែលបាន មកប្រជុំគ្នាក្នុងទីនេះ ចូរចាំស្តាប់នូវគុណខ្ពស់និងទាប ដ៏មានប្រមាណច្រើននេះ របស់មនុស្សទាំងឡាយអ្នកប្រកបដោយធម៌ ។ ដូចជាព្រះបាទនេមិរាជអង្គនេះ ជាបណ្ឌិតជាអ្នកត្រូវការដោយកុសល ជាព្រះរាជាទូន្មាននូវសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ ៗ គ្នា ។ កាលព្រះរាជាអង្គនោះកំពុងឲ្យនូវទាន សេចក្តីត្រិះរិះកើតឡើងថាទាននិងព្រហ្មចរិយៈ ២ នេះ តើណាមួយមានផលច្រើនជាងហ្ន៎ ?"

សក្កទេវរាជអង្គនោះ មិនបញ្ឈប់ការពោលត្រឹមប៉ុណ្ណោះទេ ព្រះអង្គពោលពណ៌នាសរសើរនូវគុណរបស់ព្រះបាទនេមិរាជជាច្រើន ។ លុះឮដូច្នោះ ពពួកទេវតាទាំងឡាយ មានបំណងចង់ជួបព្រះភក្ត្រស្តេចនេមិរាជក្រុងមិថិលា ក៏បានធ្វើសំណូមពរដល់សក្កទេវរាជថា ៖

"ព្រះបាទនេមិរាជនោះ ជាគ្រូរបស់ពួកទូលព្រះបង្គំជាខ្ញុំរាល់គ្នា, ទិព្វសម្បត្តិដែលពួកទូលព្រះបង្គំជាខ្ញុំបាននេះ ក៏ព្រោះអាស្រ័យព្រះបាទនេមិរាជជួយផ្តល់ដំបូន្មាន ហើយពួកយើងបានឋិតក្នុង

ដំបូន្មានរបស់ព្រះអង្គ ។ ពួកទូលបង្គំចង់ជួបព្រះភក្ត្រស្តេចអង្គនោះណាស់ ។ បពិត្រមហារាជ សូមព្រះអង្គមេត្តាចាត់ទេវបុត្រអង្គណាទៅអញ្ជើញព្រះបាទនេមិរាជឲ្យបានយាងមកឋាននយើងនេះ" ។

## មាតលិទេវបុត្រទៅដឹកព្រះបាទនេមិរាជ

សក្កទេវរាជ យល់ព្រមតាមសេចក្តីស្នើសុំរបស់ពួកទេវតាទាំងឡាយ ហើយទ្រង់ចាត់ឲ្យហៅមាតលិចូលមកគាល់ រួចបង្គាប់ថា ៖

"ម្នាលមាតលិសម្លាញ់ មើលរៀបចំរថវេជយន្តបរន្តោះទៅក្រុងមិថិលា ហើយអញ្ជើញស្តេចនេមិរាជឲ្យឡើងជិះ រួចនាំទ្រង់មកឋាននយើងនេះកុំបីខាន" ។

មាតលិទេវបុត្រ បានទទួលព្រះរាជបញ្ជាទឹមរថចេញដំណើរមកកាន់មនុស្សលោក ។ អំឡុងពេលដែលសក្កទេវរាជចរចាជាមួយនឹងពួកទេវតា និងបង្គាប់មាតលិទេវបុត្រ និងឲ្យរៀបចំទឹមរថ ប្រសិនបើគណនាពេលរបស់មនុស្សយើងវិញ គឺរយៈពេល ១ ខែគត់ ។ គាប់ចួនថ្ងៃនោះឈានចូលដល់ថ្ងៃពេញបូណ៌មី ព្រះបាទនេមិរាជបានសមាទាន

ឧបោសថសីលទ្រង់បើកសីហបញ្ជរ[២៣]ទិសខាងកើត ប្រថាប់គង់ក្នុងព្រះរាជមន្ទីរពិចារណាសីល ដែលមានពួកអាមាត្យនាហ្មឺនមន្ត្រីចោមរោមជាមួយ ។ រំពេចនោះ រថមួយដែលជារបស់មាតលិទេវបុត្រ បានលេចធ្លោដំណាលគ្នានឹងមណ្ឌលព្រះចន្ទ ដែលរះខ្ពស់ឡើង ៗ អំពីលោកធាតុខាងកើត ។ មនុស្សម្នាដែលបរិភោគអាហារល្ងាចហើយថ្មី ៗ កំពុងនាំគ្នាអង្គុយនិយាយកម្សាន្តនៅជិតទ្វារផ្ទះ ក៏លាន់មាត់ថា "ថ្ងៃនេះមានព្រះចន្ទពីរដួងរះ" ។ កាលមនុស្សទាំងនោះ កំពុងតែស្រែកហ៊ោព្នសូរក្រេវ[២៤]ៗ យ៉ាងនោះ រថក៏កាន់តែលេចដល់ភ្នែកមនុស្សធំធ្លោឡើង ៗ ។ ទើបមហាជនពោលថា "មួយនេះមិនមែនជាព្រះចន្ទទេ, ជារថទេតើ" ។ កាលរថវេជយន្ត ដែលទឹមសេះសិន្ធព[២៥] ១.០០០ និងមានមាតលិទេវបុត្រ ជាអ្នកបើកបរប្រាកដកាន់តែច្បាស់ឡើង ៗ , មនុស្សម្នាត្រិះរិះថា "តើយានទិព្វនេះមកយកនរណា ?" ស្រាប់តែម្នាក់ ៗ សប្បាយត្រេកអរ

---

[២៣] (ន.) (សំ.),(បា.) គម្រោង, រាងជ្រៅ, ទ្រង់ទ្រាយ; បង្អួចដែលមានទ្រង់ទ្រាយជារង្វង់;...។ សីហបញ្ជរ បង្អួចដែលមានរង្វង់ស្រដៀងនឹងជំហរនៃសត្វសីហៈ ។

[២៤] (ឧ.) សូរស្រែក, សូរហ៊ោព្នស្រួច : ស្រែកហ៊ោព្នក្រេវ ៗ ។

[២៥] សេះដែលកើតក្នុងដែនសិន្ធវៈ, សេះដែលមានពូជពីដែនសិន្ធវៈ ។

ថា "មិនយកអ្នកដទៃណា ក្រៅតែពីស្តេចប្រកបដោយធម៌របស់យើងទេ ប្រាកដជាសក្កទេវរាជបញ្ជូនរថវេជយន្តមក ព្រោះថារថនេះសក្តិសម ដល់ស្តេចរបស់យើងណាស់" ថាដូច្នេះហើយ ម្នាក់ ៗ លាន់មាត់ស្ញើចគ្រប់គ្នាថា ៖

"អព្ភុតោ វត លោកស្មិំ ឧប្បជ្ជិ លោមហំសនោ;
ទិព្វោ រថោ បាតុរហុ វេទេហស្ស យសស្សិនោ" ។

"ឱហ្ន៎ យើងមិនធ្លាប់ព្រឺរោមក្បាក់ផ្អើល មិនធ្លាប់នឹកថាក្នុងលោកមានរថទិព្វកើតប្រាកដដល់ព្រះបាទវិទេហៈមានយសដូច្នេះសោះ" ។

កាលដែលមហាជនកំពុងតែពោលយ៉ាងនេះ ស្រាប់តែមាតលិទេវបុត្រអ្នកមានឫទ្ធិខ្លាំងជាទេវសារថី មកដោយល្បឿនយ៉ាងលឿនដូចខ្យល់ ហើយបំបែររថបញ្ច្រាស់ តម្រង់ផ្នែកខាងក្រោយ ទៅចំធរណីសីហបញ្ជរ រៀបព្រះទីនាំងជាទីគង់ប្រថាប់ស្រេចហើយ បានអញ្ជើញព្រះបាទនេមិរាជឲ្យឡើងគង់ ដោយពាក្យដូច្នេះ ៖

"ឯហិមំ រថមារុយ្ហ រាជសេដ្ឋ ទិសម្បតិ

ទេវា ទស្សនកាមា តេ, តាវតឹសា សឥន្ទកា
សមោនា ហិ តេ ទេវា      សុធម្មាយំ សមច្ឆរេ" ។

"បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិសទាំងឡាយ សូមព្រះអង្គ ទ្រង់យាងមក សូមស្ដេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយ នៅឋានតាវត្តិង្សព្រមទាំងព្រះឥន្ទ្រចង់ឃើញព្រះអង្គ ទេវតាទាំងឡាយ នឹកព្រះអង្គណាស់ ឥឡូវនេះកំពុងនៅប្រជុំក្នុងសុធម្មទេវសភា" ។

ព្រះបាទនេមិរាជ ទ្រង់ព្រះសណ្ដាប់ដូច្នោះ ទ្រង់ព្រះចិន្ដាថា "ទេវលោកអញមិនដែលបានឃើញម្ដងណាទេ អញនឹងទៅឃើញឋាននោះ ទាន់ពេលដែលមាតលិទេវបុត្រធ្វើសេចក្ដីសង្គ្រោះដល់អាត្មាអញ, អាត្មាអញនឹងទៅ" ទ្រង់ព្រះចិន្ដាដូច្នេះហើយ ព្រះបាទនេមិរាជកោះហៅអ្នកក្រុងនិងមហាជនទូទៅឲ្យមកជួបជុំគ្នា ហើយស្ដេចទ្រង់ផ្ដែផ្ដាំថា ៖

"អហំ ឆចិរស្សេវ អាគមិស្សាមិ,    តុម្ហេ អប្បមត្តា ទានាទីនិ បុញ្ញានិ ករោថ"

"ហៃអ្នកទាំងឡាយ មិនយូរប៉ុន្មានទេ ខ្ញុំនឹងវិលមកវិញ, សូមអ្នកទាំងឡាយកុំប្រហែសធ្វេស ចូរធ្វើបុណ្យទាំងឡាយ មានទានជាដើម" ។

មានព្រះរាជឱង្ការដូច្នេះហើយទ្រង់ម្នីម្នាក្រោកចាកអាសនៈយាងស្តោះទៅឡើងរថ ។ កាលព្រះបាទនេមិរាជឡើងប្រថាប់លើរថទិព្វស្រួលបួលហើយ មាតលិទេវបុត្រទូលសួរថា ៖

"អភិរុឡ្ហំ រថំ ទិព្វំ មាតលិ ឯតទព្រវិ;
កេន តំ នេមិ មគ្គេន រាជសេដ្ឋ ទិសម្បតិ;
យេន វា បាបកម្មន្តា បុញ្ញកម្មា ច យេ នរា" ។

"បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិសទាំងឡាយ តើទូលព្រះបង្គំជាខ្ញុំគួរនាំព្រះអង្គយាងទៅតាមផ្លូវណាមុន ទៅតាមផ្លូវសត្វអ្នកមានបាបកម្មមុន ឬទៅតាមផ្លូវសត្វអ្នកមានបុញ្ញកម្មមុន ?"

"អញមិនធ្លាប់ឃើញឋានទាំងពីរទេ អញនឹងមើលឋានទាំងពីរ" ត្រិះរិះដូច្នេះហើយ ក៏ប្រាប់មាតលិទេវបុត្រថា ៖

"ឧភយេនេវ មំ នេហិ មាតលិ ទេវសារថិ;
យេន វា បាបកម្មន្តា បុញ្ញកម្មា ច យេ នរា" ។

"ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំង ២ គឺ ផ្លូវសត្វមានបាបកម្មផង ផ្លូវសត្វមានបុញ្ញកម្មផង" ។

លំដាប់នោះ មាតលិទេវបុត្រគិតថា ៖

"អាត្មាអញមិនអាចបង្ហាញឋានទាំងពីរឲ្យស្តេចទតព្រមគ្នា តែម្តងបានទេ, អញនឹងសួរព្រះអង្គថាទ្រង់ទតឋានណាមុន"

គិតដូច្នេះហើយ មាតលិក៏បានទូលសួរទៀតថា ៖

"កេន តំ បឋមំ នេមិ រាជសេដ្ឋ ទិសម្បតិ;
យេន វា ទាបកម្មន្តា បុញ្ញកម្មា ច យេ នរា" ។

"បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិសទាំងឡាយ ទូលបង្គំជាខ្ញុំត្រូវនាំព្រះអង្គយាងទៅតាមផ្លូវណាមុន ? ទៅតាមផ្លូវសត្វមានបាបកម្មមុន ? ឬទៅតាមផ្លូវសត្វមានបុញ្ញកម្មមុន ?"

# ជំពូកទី២
## ស្ដីពីឋាននរក

### ដំណើរទស្សនកិច្ចនៅឋាននរក

គ្រានោះ ព្រះបាទនេមិរាជទ្រង់ត្រិះរិះថា "អញមុខតែបានទៅឋានទេវលោកពិតពុំខានទេ, ដូច្នេះអញនឹងមើលឋាននរកមុនសិនចុះ" ។ គិតរួច ទ្រង់ប្រាប់មាតលិទេវបុត្រនោះភ្លាមថា ៖

"និរយេ តាវ បស្សាមិ អាវាសេ បាបកម្មិនំ
ឋានានិ លុទ្ទកម្មានំ ទុស្សីលានញ្ច យា គតិ" ។

"ខ្ញុំចង់ឃើញឋាននរក ជាទីនៅនៃសត្វមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញឋានរបស់សត្វអ្នកមានកម្មលាមកនិងគតិនៃសត្វទ្រុស្ដ[២៦]សីលទាំងឡាយជាមុន" ។

### ១- នរកស្ទឹងវេតរណី

លំដាប់នោះ មាតលិទេវបុត្របានឮព្រះរាជឱង្ការរបស់ព្រះរាជា ក៏បររថឆ្ពោះមុខទៅឋាននរក បង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនាការ[២៧]

[២៦] (កិ.) (សំ.) (ទ្រុស) (ទុស្ដ) ប្រទូស្ដ, ធ្វើអាក្រក់ : មនុស្សទ្រុស្ដមិត្រ ។

មុនគេ នូវស្ទឹងមួយឈ្មោះថា វេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកផ្សាប្រៃ ពុះព្រួចខ្ជោល[២៨] ៗ ឡើង ក្តៅដូចអណ្តាតភ្លើង ដែលតាំងឡើងដោយឧតុ ព្រោះកម្មជាបច្ច័យ[២៩] ។ ក្នុងនរកនោះ នាយនិរយបាល[៣០] ទាំងឡាយ ម្នាក់ ៗ សុទ្ធតែមានដៃកាន់អាវុធ គឺដាវ លំពែង ច្បូក ស្នា និងព្រនង់[៣១] ជាដើម នាំគ្នាវាយផង ចាក់ផង សំពងផង នូវពពួកសត្វនរកទាំងនោះ ។ កាលសត្វនរកទាំងឡាយអត់ទ្រាំនឹងការឈឺផ្សាទុក្ខលំបាកនោះពុំបាន ក៏នាំគ្នាលោតទៅក្នុងស្ទឹងវេតរណី ។ នៅ

---

[២៧] ទស្សនាការ (ទ័ស-ស: ន៉ាកា) ន. (បា.; សំ. ទស៌ន + អាការ) អាការនៃការឃើញ, លក្ខណៈនៃការឃើញ ។ ខ្មែរយើងប្រើជា (វ. ស.) កិ. ក៏មាន : ទ្រង់ទស្សនាការ គឺទ្រង់ទតព្រះនេត្រ, ទ្រង់ទតឃើញ ។ ដំណើរត្រួតមើលកិច្ចការផ្សេង ៗ តាមកម្មវិធីដែលបានកំណត់ទុក : លោកអភិបាលខេត្ត ធ្វើទស្សនាការក្នុងស្រុក-ក្នុងសង្កាត់ ។ ប្រើជា ទស្សនាចរ ឬ ទស្សនាចរណ៍ ក៏មាន ។

[២៨] (កិ.) អំពីសណ្ឋានដែលផុសកល ៗ ឡើង : ទឹកពុះខ្ជោល ។ គុ. សម្តីខ្ជោល គឺសម្តីដែលចេះតែមានចេញមកឥតកោតក្រែង ។

[២៩] វិមានទេវតា ឬអ្វីដែលបៀតបៀនសត្វនរកខ្លះ កើតឡើងអំពីឧតុ គឺភាពក្តៅត្រជាក់នៃអាកាសធាតុ ដែលតាំងឡើងដោយបុញ្ញកម្ម ឬបាបកម្មរបស់សត្វជាបច្ច័យ ។

[៣០] (ន.) (បា.) អ្នកត្រួតត្រាសត្វនរក, យមបាលនៅឋាននរក ។

[៣១] (ន.) ដំបងយ៉ាងធំមានសណ្ឋានមូល : សំពងផ្តៃមួយព្រនង់ ។

ពីលើស្ទឹងនោះ ដេរដាសដោយផាង់ត្នោតសុទ្ធតែបន្ទាប៉ុន ៗ ស្ន ។ ធាង់ត្នោតនោះ បានឆេះអស់ជាច្រើនពាន់ឆ្នាំមកហើយ ម៉្លោះហើយ វាក្ដៅឯង់សន្ធោសន្ធៅ ។ ពួកសត្វនរកដែលលោតទៅប៉ះធាង់ត្នោត ក៏ដាច់ជាកំណាត់ ៗ តូចធំ នៅលើបន្ទាត្នោតដែលមុតដូចមុខកាំបិតកោរនោះឯង ។ នៅពីក្រោមសត្វនរកនោះ សឹងមានដែកសូល[៣២]ក្រហមក្លឹរន្ទាលប៉ុន ៗ ដើមត្នោត ផុសមកឈររកឹងច្រូងប្រាង ។ សត្វនរកដែលជាប់នៅធាង់ត្នោតអស់វេលាដ៏យូរហើយក៏តែងតែរបូតពីធាង់ត្នោតមក ធ្លាក់ចំលើចុងដែកសូលនៅខាងក្រោមឯណោះមួយសាទៀត ។ ពួកគេមានខ្លួនមុតឈឺសុសសាច់ ឆេះនៅលើដែកសូលនោះអស់កាលជាយូរអង្វែង ពួកគេហាក់បីដូចត្រីដែលគេដោតត្រណោត[៣៣]ពីក្បាលដល់

---

[៣២] (ន.) (បា.),(សំ.) (សូ) (សូល; គូល) ឈើឬដែកមូលវែងស្រួចខាងចុង; ឈើអណ្ដោត ។ ឈើសូល ឬ ឈើសូល៍ ឈើសម្រាប់រុករុញប្រមូលសពដែលធ្វើឈាបនកិច្ចកណ្ដាលវាល ក្នុងវេលាត្រូវភ្លើងឆេះដាច់ជាកំណាត់ ៗ ដើម្បីឲ្យឆាប់សុស (ច្រើនហៅឈើសូល៍ដាង) ។ ឡើងឈើសូល ឡើងឈើអណ្ដោត (បែបធ្វើទោសប្រហារជីវិតមួយយ៉ាងក្នុងបុរាណសម័យ; បា. ហៅ សូលារោបនកម្ម "ការឡើងឈើសូល") ។

[៣៣] (ន.) វល្លិ, ចម្រៀកផ្ដៅ, ដើមរពាក់ឬខ្សែជាដើម សម្រាប់ដោតអ្វី ៗ ដែលគួរដោតបាន : *ត្រណោតត្រី, ត្រីមួយត្រណោត* ។ កាសមួយត្រណោត គឺកាសចំនួន ១០

កន្ទុយ អាំងលើរងើកភ្លើង ។ ទាំងដែកសូលទាំងសត្វនរកឃើញពណ៌ក្រហមឆ្អៅ ភ្លឺប្រាលរន្ទាលដូចគ្នា ។ នៅពីក្រោមដែកសូលទាំងនោះ សុទ្ធសឹងតែស្នឹកឈូកដែក មុខមុតប្រហែលគ្នានឹងកាំបិតកោរ ហើយពណ៌ក្រហមប្រាលនៅប៉ប្រ៉ះលើផ្ទៃទឹក ។ សត្វនរកទាំងឡាយនោះកាលដែលរបូតខ្លួនពីដែកសូល ក៏ធ្លាក់ខ្លួនមកចំពីលើស្នឹកឈូកដែក ទទួលរងនូវទុក្ខវេទនាឈឺខ្លោចផ្សា អស់កាលជាយូរអង្វែង ។ បន្ទាប់មកទើបពួកគេធ្លាក់ទៅក្នុងទឹកក្រុត[៣៨], ទឹកក្រុតនោះ ក៏ឆេះសន្ធោសន្ធៅពណ៌ក្រហមប្រាល, សត្វនរកដែលធ្លាក់នោះ ក៏ឆេះសន្ធោសន្ធៅឡើងពណ៌ក្រហមប្រាលដូចគ្នា, ផ្សែងក៏ហុយឡើង ថែមទាំងឈ្ងៀមក្លិន

---

តៀន, ក្នុងមួយតៀនមាន ៦០ កាស, មួយត្រណោតត្រូវជា ៦ រយកាស, ដប់ត្រណោតហៅថា មួយបាច់ មាន ៦ ពាន់កាស (មានប្រើតែក្នុងសម័យចាយកាស) ។ ហៅ ហ្វ្រង់ចាស់ (ancien franc) ប្រទេសបារាំងថា ត្រណោតដែរ ហៅដោយធៀបនឹងកាសមួយត្រណោត; ក្នុងសម័យនោះមានសម្ដីថា ត្រណោតខ្មែរ, ត្រណោតបារាំង ។ ជាប់មួយត្រណោត ឬ ជាប់ទោសមួយត្រណោត (ព. ប្រ.) គឺជាប់ទោសទាំងមួយពួកឬទាំងមួយក្រុមរួមក្នុងពន្ធនាគារជាមួយគ្នា ។ ចាប់បានមួយត្រណោត (ព. ប្រ.) គឺចាប់ចោរបានទាំងមួយពួក ហើយដាក់ឃ្នាងឬដាក់ខ្នោះដៃចងភ្ជាប់គ្នាបណ្ដើរទៅកាន់ទីឃុំឃាំង ។

[៣៨] ទឹកដែលមានសារធាតុកាត់ផ្សាឲ្យរលួយស្បែកសាច់ ។

អសោច[៣៩] ផងដែរ ។ ចំណែកនៅបាតស្ទឹងខាងក្រោមទឹកនោះវិញ ស៊ីង ពោរពាសដោយកាំបិតកោរ មានមុខមុតស្រួចរលែម ។ ពពួកសត្វនរក បានគិតថា "ចុះនៅខាងក្រោមវិញយ៉ាងម៉េចដែរ" ហើយក៏នាំគ្នាមុជចុះ ក្នុងទឹក ប៉ះនឹងមុខកាំបិតកោរ ក៏ដាច់ជាកំណាត់តូចធំនៅលើមុខកាំបិត កោរនោះឯង ។ សត្វនរកទាំងឡាយ មិនអាចអត់ទ្រាំនឹងក្តីឈឺចាប់ទុក្ខ លំបាកដ៏មហាធំធេងនោះបាន ក៏នាំគ្នាស្រែកស្ទុះរត់ប្រសេចប្រសាច មានសំឡេងគួរឲ្យខ្លាចពន់ពេកណាស់ ។ ចួនកាល ពួកគេនាំគ្នាហែល បណ្តោយខ្សែទឹក ចួនកាលហែលច្រាសខ្សែទឹក ។ នៅពេលដែលពួក គេបានឈរលើច្រាំង នាយនិរយបាលទាំងឡាយ ក៏បានលើកព្រួញ លំពែងច្បូកជាដើម បាញ់ចាក់បុកពួកគេដូចជាត្រី ។ ពួកសត្វនរក

---

[៣៩] (គុ.) (បា.),(សំ.) (អៈសោច) (អសុចិ, ខ្មែរប្រើ ឧ > ឱ គឺ សុ > សោ; អគុចិ ឬជា អគោច ក៏មាន "មិនស្អាត") ដែលមិនស្អាត, មិនបរិសុទ្ធ; សោគ្រោក; កខ្វក់; អាក្រក់; ស្អុយ អាក្រក់គួរខ្ពើម, គួរឆ្អើម : ក្លិនអសោច ។ អសោចកេរ្តិ៍ឈ្មោះ ស្អុយកេរ្តិ៍ឈ្មោះ ។ កេរ្តិ៍ អសោច កេរ្តិ៍ឈ្មោះអាក្រក់ ។ មនុស្សអសោច មនុស្សដែលមានឈ្មោះអាក្រក់ក្រៃ ពេក ។

ដល់នូវទុក្ខវេទនា[៣៦] ស្រែកទួញថ្ងូរគួរឲ្យរន្ធត់ពេកក្រៃ ។ គ្រានោះ នាយនិរយបាលទាំងឡាយ ស្ទូចពួកសត្វនរក ដោយសន្ទូចដែកក្រហមឆ្អៅ ទាញមកដាក់ឲ្យដេកលើផែនដីដែកដ៏ភ្លឺរន្ទាលក្រហមច្រាលហើយពួកគេបង្អកដុំដែកដ៏ក្តៅគគុក[៣៧] ទៅក្នុងមាត់របស់ពួកសត្វនរកទាំងនោះ ។

ព្រះបាទនេមិរាជទ្រង់ទតឃើញសត្វនរកទាំងឡាយដែលកំពុងទទួលមហាទុក្ខបៀតបៀនក្នុងស្ទឹងវេតរណី ដែលឆ្លងឡើងបានដោយកម្រក្រៃលែងដូច្នេះ ទ្រង់ភ័យតក់ស្លុត មានព្រះហឫទ័យញ័របំប្រ៉ប់ត្រាស់នឹងមាតលិទេវបុត្រថា ៖

"ម្នាលទេវបុត្រ ខ្ញុំភ័យស្លុតណាស់ពេលឃើញសត្វធ្លាក់ទៅក្នុងស្ទឹងវេតរណី ខ្ញុំសូមសួរអ្នក តើសត្វទាំងឡាយនេះធ្លាក់ទៅក្នុង

---

[៣៦] ទុក្ខវេទនា (ទុក-ខៈវេទៈនា) ន. (បា.) ដំណើរដឹងនូវសេចក្តីព្រួយ, លំបាក; ដំណើររងអារម្មណ៍ ឬទទួលអារម្មណ៍ជាទុក្ខ, សេចក្តីសោយទុក្ខ ។ ហៅត្រឹមតែ វេទនា ប៉ុណ្ណោះ ក៏គង់សំដៅសេចក្តីថា ទទួលរងអារម្មណ៍ជាទុក្ខដែរ : *រងវេទនា*។ ខ្មែរយើងប្រើជា កិ. ក៏មាន : *វេទនាណាស់ !, វេទនាអ្វីម្ល៉េះទេ ! ឬ វេទនាអ្វីម្ល៉េះហ្ន៎ !*។

[៣៧] (គុ.) ដែលក្តៅធំ ។ (កិ.វិ.) ដែលហូរ, ដែលបក់, ដែលទៅមកបន្តគ្នាឥតអាក់ ឧ. ទឹកហូរគគុក, មនុស្សដើរគគុក ។

ស្ទឹងវេតរណី ព្រោះពួកគេបានធ្វើបាបកម្មអ្វី ?" មាតលិទេវបុត្រ បានព្យាករនូវផលនៃបាបកម្មតាមដែលខ្លួនបានដឹង ទូលព្រះបាទនេមិរាជថា ៖

"ពួកសត្វណាមានកម្លាំងខ្លាំងតែមានធម៌ដ៏លាមក បៀតបៀន ប្រទេចផ្ដាសាពួកសត្វដែលមានកម្លាំងខ្សោយ ក្នុងជីវលោក[៣៨] ពួកសត្វដែលមានកម្មដ៏លាមកនោះ រមែងទទួលរងនូវបាប ពួកសត្វទាំងនោះឯង តែងធ្លាក់ទៅកាន់ស្ទឹងវេតរណី" ។

## ២- នរកសុនខ

មាតលិសារថីបានព្យាករបញ្ហាថ្វាយព្រះបាទនេមិរាជយ៉ាងនេះ, កាលដែលស្ដេចនេមិរាជ កំពុងតែទ្រង់ទតនរកវេតរណី, ស្រាប់តែមាតលិទេវសារថី បររថផុតពីកន្លែងនោះបន្ដោះទៅខាងមុខទៀត ហើយបង្ហាញឲ្យទ្រង់ទស្សនាការនូវឋាននរកមួយទៀត ដែលមានហ្វូងក្អែព្រៃ សម្បុរក្រហមនិងពពាល ហ្វូងសត្វត្មាត[៣៩] និងហ្វូងសត្វក្អែក ដែលគួរឲ្យ

---

[៣៨] លោកដែលកំពុងរស់នៅ ។

[៣៩] (ន.) ឈ្មោះសត្វស្លាបធំ បរិភោគសាកអសុកជាអាហារ; មានពីរប្រភេទគឺត្មាតភ្លើង មាឌធំមាំក្បាលក្រហមដូចភ្លើង, ត្មាតផេះ មាឌតូចជាងត្មាតភ្លើងសម្បុរប្រផេះ ។

ខ្លាចកំពុងតែដេញខាំពួកសត្វនរកស៊ី តាមដែលវាបានប្រទះឃើញ ។ ហ្វូងសុនខនោះ មានសម្បុរ ៥ គឺ សម្បុរពពាលក៏មាន សម្បុរស ខ្មៅ លឿង ក្រហម ក៏មាន ។ ពួកសុនខទាំងនោះ មានខ្លួនធំប៉ុន ៗ ដំរី រត់ដេញតាមពពួកសត្វនរក បីដូចសត្វម្រឹគនៅលើប្រឹថពីដែកដ៏ក្រហមឆ្អិនឆ្អៅ ត្របាក់ខ្លួនប្រាណសត្វនរកជ្រុះសាច់មកទាំងដុំ ៗ ប៉ុន ៗ ផ្ទាំងដី ៣ គាវុត[៤០] ធ្លាក់មកលើប្រឹថពីដែកដ៏សន្ធោសន្ធៅ ។ កាលដែលពួកសត្វនរកនោះកំពុងតែស្រែកឮសូរខ្លាំងក្តែង[៤១] ៗ ហ្វូងសុនខក៏នាំគ្នាលោតយកជើងមុខពីរ សង្គ្រុបពីលើទ្រូងសត្វនរក ហើយខាំជញ្ជែងអង្កៀម[៤២]ស៊ីសាច់អស់នៅសល់តែឆ្អឹងប៉ុណ្ណោះ ។ គ្រានោះ មានត្មាត

---

[៤០] (ន.) (បា.),(សំ.) (គវ្យូតិ) មាត្រាវាស់ ឬវង្វាស់ ចំនួនពីរពាន់ព្យាម គឺមួយរយសិន (ប្រើតែពីក្នុងសម័យបុរាណ) ។ ម. ព. លិក្ខា ឬ លិក្សា ទៀតផង ។

[៤១] (កិ. វិ.) (ដើង ដ) ដែលឮខ្លាំងក្របាត់ ដោយស្រែក ឬ យំ : ស្រែកក្តែង ៗ, យំក្តែង ៗ, ជង្ហោយក្តែង ៗ ។

[៤២] (កិ.) ខាំឬកកេរមិនដកមាត់ ដើម្បីឲ្យទក់, ឲ្យរេច, ឲ្យដាច់ : សុនខអង្កៀមព្រ័ត្រ, ឆ្មាអង្កៀមត្រីផ្ទៀត ។ បៀមបៅខាំជញ្ជក់ញាំ ៗ : កូនបៅអង្កៀមដោះ ។ ព. ប្រ. ខំប្រឹងមិនលែង, ខំទទូចធ្វើទាល់តែសម្រេចប្រយោជន៍ : ធ្វើការអង្កៀមមិនព្រមលែង ។ អង្កៀមចំណោះ ប្រឹងសម្តីរៀនទាល់តែចេះ ។ល។

មួយហ្វូងចំពុះដែកប៉ុនរទេះដឹកទំនិញធំ ៗ មកចឹកបំបែកឆ្អឹងទាំងឡាយរបស់ពពួកសត្វនរក ដោយចំពុះដែលស្រួចដូចលំពែង ហើយចឹកជញ្ជែង[៤៣]ស៊ីខួរក្នុងឆ្អឹង ។ បន្ទាប់មក មានហ្វូងក្អែកមួយក្រុម ចំពុះសុទ្ធតែដែកដូចគ្នា ពួកវាមានរូបគួរឲ្យតក់ស្លុតរន្ធត់ស្រយុតចិត្តយ៉ាងក្រៃលែង ថាបើវាប្រទះអ្វី ៗ ហើយ តែងតែខាំស៊ីមិនលើកលែងឡើយ ។ សូម្បីសត្វនរកទាំងនេះ ក៏ត្រូវពួកវាខាំស៊ីដែរ ។

ព្រះបាទនេមិរាជសួរថា ៖

"ម្នាលទេវបុត្រ ខ្ញុំភ័យស្លុតណាស់ ពេលឃើញហ្វូងក្អែកជញ្ជែងស៊ីសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះ ដើមឡើយ បានធ្វើបាបកម្មដូចម្ដេច ?"

មាតលិទេវសារថី ទូលព្រះរាជាថា ៖

"ពួកគេជាអ្នកកំណាញ់ស្វិត មិនត្រឹមតែមិនចេះឲ្យអ្វីដល់អ្នកដទៃដោយខ្លួនឯងប៉ុណ្ណឹងទេ ថែមទាំងហាមឃាត់ទាំងអ្នកដទៃដែលកំពុងឲ្យទាន ចែករំលែកតាមកម្លាំងសទ្ធាទៀតផង ។ មិនតែប៉ុណ្ណោះ ពួកគេបានជេរប្រទេចផ្ដាសាសមណព្រាហ្មណ៍ ដែល

[៤៣] (កិ.) (ជញ់-ជែង) ចឹក, ខាំ, ហែក ប្រជែងគ្នា : *ត្មាតជញ្ជែងគម្រង់គោ។*

ជាអ្នកមាន បាបបន្សាត់បង់ហើយផង ។ សត្វអ្នកមានអំពើលាមក ទាំងនោះ ទទួលរងនូវផលបាបកម្មយ៉ាងនេះ ទើបត្រូវហ្វូងក្អែក ចឹកជញ្ជែងស៊ី” ។

**៣- នរកដំបងដែក**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តទៅខាងមុខ ទៀត ហើយបង្ហាញឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ជាដែកសុទ្ធ នៅឋាននរកនេះ ផែនដីគឺជាដែកដូចគ្នានឹងនរកមុន ៗ ដែរ មានកម្រាស់ ៩ យោជន៍ ឆេះភ្លឺសន្ធោសន្ធៅ ឯសត្វនរកដែលដើរជាន់លើផែនដីដែក នេះ ក៏មានខ្លួនប្រាណឆេះសន្ធោសន្ធៅក្រហមឆ្អៅដូចរងើកភ្លើងដែរ ។ ពួកនាយនិរយបាលទាំងឡាយ ដេញប្រកិត[៤៤]តាមសត្វនរកវាយ បំបាក់អវយវៈទាំងឡាយមានជង្គង់ជាដើមដោយដំបងដែកដ៏ក្រហម ឆ្អៅប៉ុន ៗ ដើមត្នោត ហើយសំពងថែមដោយដំបងនោះឲ្យខ្ទេចខ្ទីជា ផង់ល្អិតហ្មត់ដូចម្សៅ ។

នេ. “តើពួកសត្វនរក ដែលមានសរីរៈឆេះសន្ធោសន្ធៅ ដើរលើ

[៤៤] (កិ. វិ.) ដែលកិតជាប់គ្នា : ដេញប្រកិត ។ គុ. ដែលជិតស្ទើរនឹងដល់គ្នា : ផ្ទះប្រកិតគ្នា ។

ផែនដីដែក ថែមទាំងមាននាយនិរយបាលសំពង់ដោយដំបង
ដែកទាំងឡាយដែលភ្លើងឆេះ ហើយដួលដេកនៅនេះ ព្រោះ
ពួកគេបានធ្វើបាបកម្មដូចម្ដេច ?”

មា. “ពួកគេ ដើមឡើយ មានបាបធម៌ពេញបន្ទុកក្នុងខ្លួន បៀតបៀន
ប្រទេចផ្ដាសាបុរសស្ត្រីអ្នកប្រកបព្រមដោយសីលាចារវត្ត[៤៥] ឥត
បាបធម៌ ក្នុងជីវលោក ។ ជនអ្នកមានកម្មលាមកទាំងនោះទទួល
រងបាប ទើបកើតជាសត្វនរកត្រូវនាយនិរយបាលបៀតបៀន
ដោយដំបង ហើយដួលដេកនៅនឹងកន្លែងដូច្នេះ” ។

**៤- នរករណ្ដៅរងើកភ្លើង**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្ដត្ដោះទៅខាងមុខ
ទៀត ហើយបង្ហាញទ្រង់ឲ្យទស្សនានូវរណ្ដៅនរកមួយទៀត ។ ក្នុង
ឋាននរកនេះ មានសត្វនរកមួយក្រុមដែលត្រូវពួកនាយនិរយបាល
ឡោមព័ទ្ធកៀរប្រមែប្រមូល ដេញដំវាយសំពង់ដោយព្រនង់ដែកសន្ធោ
សន្ធៅ ឲ្យធ្លាក់ទៅកាន់រណ្ដៅរងើកភ្លើង មើលទៅដូចហ្វូងគោមិនចូល
ក្រោល ។ នាកាលសត្វនរកទាំងនោះធ្លាក់លិចចុះក្នុងរណ្ដៅភ្លើងនោះ

[៤៥] ការប្រតិបត្តិក្នុងសីលនិងមារយាទ ។

ត្រឹមចង្កេះ ពួកនាយនិរយបាលយកកញ្ច្រែងដែកពេញដោយរងើក ភ្លើងធំ ៗ មកចាក់រោយរាយពីលើថែមទៀត ។ កាលបើដូច្នេះ ពពួក សត្វនរកទាំងនោះ ទ្រាំនឹងរងើកភ្លើងទាំងនោះមិនបានក៏ស្រែកយំ ឯ ខ្លួនប្រាណដែលត្រូវភ្លើងឆេះសព្វក្នុងរណ្ដៅ ក៏រើមិនរួច បានត្រឹមតែ ស្រែកថ្ងូរ ។ ន័យមួយទៀតថែងថា សត្វនរកទាំងនោះថ្ងូរបណ្ដើរ រោយ រាយបណ្ដើរ នូវរងើកភ្លើងដាក់ពីលើក្បាលខ្លួនឯង ដោយអំណាច កម្លាំងនៃកម្ម ។

នេ. "តើពួកសត្វនរកដែលមានខ្លួនឆេះសព្វជុំវិញ កំពុងយំថ្ងូរនៅ ក្នុងរណ្ដៅរងើកភ្លើងនេះ ព្រោះពួកគេបានធ្វើបាបដូចម្ដេច ?"

មា. "ពួកសត្វនរកនេះ ដើមឡើយ បានចាយវាយប្រើប្រាស់ទ្រព្យធន របស់ប្រជាជន តាមអំពើចិត្តខ្លួន ដែលពួកគេខំប្រមូលមកឲ្យទុក ដាក់ដើម្បីនឹងធ្វើទាន ឬដើម្បីនឹងរៀបពិធីបូជា ឬក៏ដើម្បីនឹងសាង សង់កុដិ វិហារ វត្តអារាមជាដើម ។ កាលណាឱកាសផ្ដល់ឲ្យ, ពួក គេស៊ីចុកតាមចិត្តចង់នូវទ្រព្យធននោះ ដោយជូនសំណូកខ្លះ ៗ ដល់មេក្រុម រួចមកអះអាងសាក្សីកោងថា "ចំណាយប៉ុណ្ណេះទៅ កន្លែងឯណោះ, ចំណាយប៉ុណ្ណោះនៅទីនេះទីនោះជាដើម" ។

ពួកគេបំបិទបំបាំងនូវបំណុលដែលខ្លួនប្រើប្រាស់ជំពាក់នោះ ធ្វើឲ្យវិនាសខូចបង់អាសាឥតការទៅ រកមុខអ្នកជំពាក់មិនឃើញ ។ ជនទាំងឡាយអ្នកមានកម្មដ៏លាមកនេះ រមែងទទួលរងបាប ទើបពួកគេធ្លាក់ទៅនរករណ្ដៅរងើកភ្លើង ហើយស្រែកយំថ្ងូរដូច្នេះ" ។

**៥- នរកខ្ទះទង់ដែង**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តដំណើរទៅខាងមុខទៀត បង្ហាញឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀតជាខ្ទះទង់ដែង ។ នៅឋាននរកនេះ មានខ្ទះមួយទំហំប៉ុនភ្នំ សឹងពេញព្រៀបដោយទឹកទង់ដែងរលាយកូរ ពពុះបែកប៉ប៉ាំងៗ ។ ពួកនាយនិរយបាលមានមាឌគួរខ្លាច ចាប់ពពួកសត្វនរកបំបះជើងឡើងលើ ក្បាលចុះក្រោម បោះទម្លាក់ទៅក្នុងខ្ទះទង់ដែងនោះ ។

នេ. "ម្នាលទេពបម្រើ ខ្ញុំភ័យស្លុតណាស់ពេលបានឃើញខ្ទះទង់ដែងដ៏ធំមានភ្លើងឆេះសន្ធោសន្ធៅ រន្ទាលច្រាលឆ្អៅ ប្រាកដជាក់ស្ដែង ។ ពួកសត្វទាំងនោះ មានក្បាលសំយុងចុះទៅខ្ទះដ៏ពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះធ្វើបាបដូចម្ដេច ?"

មា. "ពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សប្រព្រឹត្តបាបកម្មជេរ

ប្រទេច ផ្កាសា បៀតបៀននូវសមណៈ ឬព្រាហ្មណ៍អ្នកបរិបូរ ដោយគុណសីលាចារវត្ត ។ ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ រមែងទទួលរងនូវបាប ទើបពួកគេមានក្បាលសំយុងចុះទៅក្នុងខ្ទះដ៏ពេញដោយទឹកទង់ដែងដូច្នេះ" ។

**៦- នរកត្រូវបែងក្បាល**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តឆ្ពោះទៅខាងមុខ បង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ។ នៅឋាននរកនេះ នាយនិរយបាលទាំងឡាយ ចងត្របែង[៤៦]ក្បាលសត្វនរកឲ្យមានមុខចុះក្រោម ដោយខ្សែទង់ដែងដ៏សន្ធោសន្ធៅ ហើយចងរុំកដោយខ្សែទង់ដែងដ៏សន្ធោសន្ធៅដូចគ្នា រួចបង្អោនរាងកាយសត្វនរកដែលមានប្រវែង ៣ គាវុត ឲ្យឱនខ្លួនចុះហើយរង្កៀកដកកនោះចេញ រុលត្បុលដំបងដែកដ៏ក្រហមប្រាលឆ្អៅចូលទៅក្នុងដងខ្លួន ចាប់គ្រវាត់បោះទៅក្នុងទឹកទង់ដែងមួយ ដែលកំពុងតែឆេះរន្ទាលប្រាលឆ្អៅហើយ ពួកនាយនិរយបាលទាំងនោះ នាំគ្នាសើចសប្បាយក្អាកក្អាយ ។

---

[៤៦] (កិ.) ចងហើយរឹតដោយមេកំព្រាឬកូនកំព្រា : ត្របែងទឹម, ត្របែងក្បួន។

កាលដែលកសត្វនរកនោះ គ្រាន់តែត្រូវបានដកចេញពីដង៏ខ្លួនភ្លាម ស្រាប់តែកព្រមទាំងក្បាលថ្មីកើតឡើងម្តងទៀត ។

នេ. "ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញពួកនាយនិរយបាល ត្របែងកនៃសត្វនរក ហើយកាប់ពន្ធះបោះទៅក្នុងទឹកក្តៅ ។ តើពួកសត្វដែលមានក្បាលដាច់ដេកនៅនេះ បានធ្វើបាបកម្មដូចម្តេច ?"

មា. ពួកសត្វនរកនេះ ដើមឡើយ កាលពួកគេនៅក្នុងជីវលោក មានបាបធម៌ពេញបន្ទុក តែងបៀតបៀននូវសត្វស្លាប បានប្រកបមុខរបរចាប់សត្វស្លាប ដកស្លាបចង៏រឹតកសម្លាប់ ទុកស៊ីដោយខ្លួនឯងខ្លះលក់ឲ្យគេខ្លះ ។ ពួកជនអ្នកមានកម្មលាមកនេះ រមែងទទួលរង់នូវបាប ទើបដេកដាច់ក្បាលនៅឋាននរកនេះ ។

**៧- នរកអន្លាម**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តឆ្ពោះទៅខាងមុខ បង្ហាញស្តេចនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ។ នៅឋាននរកនេះ ឮថាមានស្ទឹងមួយ មានទឹកគ្រប់គ្រាន់ តែងហូរទៅ មិនដាច់ គួរឲ្យផឹក ប្រកបដោយកំពង់ដ៏ស្រស់ស្អាតជាច្រើន តាមពិតទៅ គឺជា

តំបន់រមណីយដ្ឋានមួយ នាឋាននរកនោះ ។ សត្វនរកទាំងឡាយ កាលណាក្តៅដោយកម្តៅអគ្គី ពុំអាចទ្រាំទ្រនឹងសម្រេកបាន ផ្តងដើមដៃរត់កាត់ប្រឹថពីដែកដ៏ក្រហមឆ្អៅតម្រង់មុខឆ្ពោះទៅស្ទឹងនោះ ។ រំពេចនោះឯង ភ្លើងក៏ឆេះរាលតាមឆ្នេរស្ទឹង, ទឹកដែលគួរផឹក ក្លាយទៅជាអង្កាមក្រហមឆ្អៅជារងើកភ្លើងទៅវិញ ។ ពពួកសត្វនរក ស្រេកទឹកពេក ពុំអាចអត់ទ្រាំបាន ក៏ឱនប្រាណបរិភោគអង្កាម ដែលកំពុងច្រាលឆ្អៅនោះឯង ។ អង្កាមដែលចូលទៅក្នុងពោះ បានដុតរាងកាយទាំងមូលរបស់ពពួក សត្វនរក ហើយធ្លាយចេញមកតាមរន្ធគូទខាងក្រោម ។ ពពួកសត្វនរក ធន់នឹងទុក្ខលំបាកនោះពុំបាន ក៏នាំគ្នាផ្តងដើមដៃកន្ទក់កន្ទេញ ។

នេ. "ម្នាលទេពបម្រើ ខ្ញុំភ័យស្លុតណាស់ពេលឃើញស្ទឹងនេះ មានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អរាបទាបហូរទៅ សត្វដែលមានសេចក្តីស្រេកឃ្លានតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាម ។ តើសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញព្រោះពួកគេបានធ្វើនូវបាបដូចម្តេច ?"

មា. "ពពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សមានទង្វើមិនបរិសុទ្ធ លាយគ្រាប់ធញ្ញជាតិដែលបរិសុទ្ធ ៧ ប្រការ មានស្រូវជាដើម ជាមួយនឹងស្មឹក ឈើ អង្កាម ដីខ្សាច់ ឬដីស្អិតជាដើម ហើយលក់ទៅឲ្យអ្នកទិញ យកប្រាក់កម្រៃពីគេ ដោយអះអាងថា ខ្លួនលក់ស្រូវបរិសុទ្ធ ។ តាមពិត ខ្លួនឯងជាមនុស្សមានការងារមិនស្អាត គឺកាយកម្ម វចីកម្ម និងមនោកម្មរបស់ខ្លួន ប្រឡាក់ប្រឡូសសៅហ្មង ។ ជនទាំងឡាយណា ធ្វើឲ្យធញ្ញជាតិមិនបរិសុទ្ធ ដោយលាយអង្កាមជាដើមលក់ឲ្យអ្នកទិញ ទើបទឹកដែលជនទាំងឡាយនោះផឹកដោយក្តីស្រេកឃ្លាន ក្លាយជាអង្កាមដូច្នេះ ។

## ៨- នរកលំពែង

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តដំណើរទៅខាងមុខទៀត បង្ហាញស្តេចនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ។ នៅឋាននរកនេះ នាយនិរយបាលទាំងឡាយ សាហាវឃោរឃៅខ្លាំងណាស់ នាំគ្នាចោមរោម បុកទម្លុះរាងកាយទាំងសងខាងរបស់ពួកសត្វនរក ដោយប្រើអាវុធនានា មានលំពែង ព្រួញជាដើម ។ រាងកាយរបស់សត្វនរក ប្រាកដដូចជាស្មឹកឈើចាស់ធ្លុះជាប្រហោងតូចធំ ។

នេ. "ម្នាលទេពបម្រើ សេចក្តីភ័យខ្លាចមានដល់ខ្ញុំ ព្រោះឃើញនូវនាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក ដែលកំពុងកន្ទក់កន្ទេញដោយព្រួញទាំងឡាយក៏មាន ដោយលំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយក៏មាន។ តើពួកសត្វដែលនាយនិរយបាលបៀតបៀនដោយលំពែងដេកនៅដូច្នេះ បានធ្វើបាបកម្មដូចម្តេច ?"

មា. "ពពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សប្រកបមុខរបរចិញ្ចឹមជីវិតមិនល្អ លួចរបស់របរអ្នកដទៃ ទាំងទ្រព្យមានវិញ្ញាណ ទាំងទ្រព្យឥតវិញ្ញាណ លួចយកស្រូវ ទ្រព្យ ប្រាក់ មាស ទាំងសត្វចិញ្ចឹម ពពែ ចៀម និងក្របី ដែលគេមិនបានឲ្យ ដោយប្រើវិធីកាត់ទីតជាដើមផង ដោយប្រើវិធីបោកបញ្ឆោតផង ហើយធ្វើនូវការចិញ្ចឹមជីវិត ។ ជនអ្នកមានកម្មដ៏លាមកទាំងនោះ រង់នូវបាបទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលបៀតបៀនដោយលំពែងជាដើម ដេកនៅដូច្នេះ" ។

## ៩- នរកចិញ្រ្ចាំ

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តឆ្ពោះទៅខាងមុខ បង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ។ នៅឋាននរកនេះ ពពួកសត្វនរក ត្រូវនាយនិរយបាលទាំងឡាយចងក ដោយខ្សែលោហៈដ៏ក្រហមធំ ៗ ទាញប្រានផ្តួលទៅលើផែនដីដែក ហើយ វាយដំដោយអាវុធនានា ។ មួយពួកទៀត ត្រូវនាយនិរយបាល កាត់ជាកំណាត់តូចធំ ។ មួយពួកផ្សេងទៀត ត្រូវនាយនិរយបាល ដាក់ឲ្យដេកលើផែនក្តារដែកដ៏សន្ធោសន្ធៅ ហើយចិញ្រ្ចាំដោយកាំបិតប៉័ងតោ[៤៧] ខ្ទេចខ្ទីសាច់ឆ្អឹងចូលគ្នាជាដុំសាច់ ហាក់ដូចសាច់ឬប្រហុកដែលត្រូវគេចិញ្រ្ចាំខ្ទេចដូច្នោះឯង ។

នេ. "ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញសត្វនរកមួយពួក ត្រូវនាយនិរយបាលចងកអូស ពួកខ្លះត្រូវនាយនិរយបាល ចិញ្រ្ចាំ ពួកដទៃទៀត ត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទីដួលដេក

---

[៤៧] (ន.) (ចិ.) កាំបិតមួយបែបសម្រាប់ចិញ្រ្ចាំសាច់ឬហាន់វត្ថុផ្សេង ៗ (ខ្លះនិយាយ ថា ប៉័នតោ)។

នៅដូច្នេះ ។ តើជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទីដួលដេកនៅនេះ បានធ្វើនូវបាបដូចម្តេច ?"

មា. "ពពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សប្រកបមុខរបរសម្លាប់ត្រី សម្លាប់ជ្រូក សម្លាប់គោ សម្លាប់សត្វចិញ្ចឹម គឺក្របីពពែនិងចៀម ហើយដាក់លើរានលក់ នៅក្នុងផ្សារ ។ ជនទាំងឡាយដែលប្រកបមុខរបរអាក្រក់ទាំងនោះ ទទួលរងបាប បានជាត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដេកនៅដូច្នេះ" ។

**១០- នរកអន្លង់លាមក**

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តឆ្ពោះទៅខាងមុខបង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ធ្វើទស្សនាការនូវឋាននរកមួយទៀត ។ នៅឋាននរកនេះ ពពួកសត្វនរកម្នាក់ ៗ សុទ្ធតែត្រូវសេចក្តីឃ្លានដុតកម្តៅពោះ ស្មើរតែដាច់ពោះវៀនតូចពោះវៀនធំ កាលអត់ទ្រាំនឹងសេចក្តីឃ្លាននោះមិនបាន ពួកគេក៏ស្រវេស្រវាកាយអាចម៍ស៊ីទាំងដុំ ៗ ដែល អាចម៍នោះបិតនៅរហូតកប្ប ក្លិនឈ្ងៀម ជុំផ្សាយ ស្អុយអាក្រក់ហុយ ផ្សេងយ៉ាងសន្ធោសន្ធៅ ។

នេ. "ម្នាលទេពបម្រើ ខ្ញុំភ័យខ្លាចណាស់ពេលឃើញអន្លង់នេះពេញពោរដោយមូត្រនិងករីសៈ[៤៨] មានក្លិនអាក្រក់មិនស្អាតតែងស្អុយផ្សាយទៅ ពួកជនអ្នកមានសេចក្តីស្រេកឃ្លាន ស៊ីនូវមូត្រនិងករីសៈនេះ ។ តើពួកជនអ្នកបរិភោគនូវមូត្រនិងករីសៈនេះបានធ្វើនូវបាបកម្មដូចម្តេច ?"

មា. "ពពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សបង្ករឿងដល់អ្នកដទៃដទៃផង បៀតបៀនធ្វើបាបដល់មិត្តសម្លាញ់អ្នកមានបេះដូងស្មោះស្មគ្រផង ជាអ្នកដែលប្រទូស្តចំពោះមិត្តផង ។ ដែលហៅថាប្រទូសមិត្ត គឺបានដល់ពពួកមនុស្សណា ដែលស៊ីចុក អង្គុយដេកលើគ្រែនៅផ្ទះគេ ហើយថ្ងៃមធំហ៊ានលួចរបស់របរមាសនិងប្រាក់របស់គេ ឬឆបោកគេថែមទៀត ។ ពួកជនទាំងឡាយ អ្នកមានអំពើលាមកនោះ រងផលបាប ទើបស៊ីអាចម៍ដ៏មានសភាពបែបនេះ" ។

---

[៤៨] លាមក, អាចម៍ ។

## ១១- នរកអន្លង់ខ្ទុះឈាម

មាតលិទេវសារថី បររថផុតពីកន្លែងនោះបន្តឆ្ពោះទៅខាងមុខ បង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកមួយទៀត ។ នៅឋាននរកនេះ សត្វនរកទាំងឡាយ ត្រូវកម្តៅបៀតបៀនឲ្យឈឺផ្សាក្រហល់ក្រហាយ អន្ទះអន្ទែង ស្វែងរកអ្វីបរិភោគបំបាត់សេចក្តីស្រេកឃ្លាន ទើបប្រទះខ្ទុះឈាម ក៏នាំគ្នាកាយចុក ៗ តែម្តង ។

នេ. "ម្នាលទេពបម្រើ ខ្ញុំភ័យស្លុតណាស់ ពេលបានឃើញអន្លង់នេះពេញពោរដោយឈាមនិងខ្ទុះ មានក្លិនអាក្រក់ មិនស្អាត តែងស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកម្តៅបៀតបៀនកំពុងផឹកឈាម និងខ្ទុះជាអាហារនេះ តើបានធ្វើបាបកម្មដូចម្តេច ?"

មា. "សត្វនរកទាំងនេះ ដើមឡើយជាមនុស្សត្រូវបារាជិក[៤៩] ក្នុងភាពជាគ្រហស្ថ គឺសម្លាប់ព្រះអរហន្ត បានដល់ម្តាយឪពុកដែលចាស់

---

[៤៩] (ន.) (បា.) (ប៉ារ៉ា--) ឈ្មោះអាបត្តិពួកមួយមានទោសធ្ងន់បំផុត សម្រាប់ភិក្ខុ ឬភិក្ខុនីក្នុងព្រះពុទ្ធសាសនា (ព. វ. ពុ.) ។ សូម្បីគ្រហស្ថដែលសម្លាប់ព្រះអរហន្ត ឬម្តាយឪពុក ក៏ឈ្មោះថាត្រូវបារាជិកដែរ ព្រោះជៀសមិនផុតពីនរក បន្ទាប់ពីអស់ជីវិតទៅ ។

ជរា ដែលពួកគាត់បានធ្វើកិច្ចដែលគេធ្វើបានដោយកម្រចំពោះ

កូនប្រុសស្រី ជាព្រះអរហន្ត គឺអ្នកសមគួរដល់ការបូជាដោយ

វិសេស អំពីកូនប្រុសស្រី និងរាប់ទាំងអ្នកដែលបៀតបៀននូវពួក

សាវករបស់ព្រះពុទ្ធផង ។ ពួកជនអ្នកមានអំពើលាមកនោះ

ទទួលរងបាប ទើបមានឈាមនិងខ្ទុះជាអាហារដូច្នេះ” ។

**១២- នរកផ្លែសន្ទូច**

ក្នុងឋាននរកមួយទៀត មានឈ្មោះថា“ឧស្សទនរក” នាយនិរយ

បាលទាំងឡាយ ថ្ពក់អណ្តាតសត្វនរកទាំងឡាយ ដោយផ្លែសន្ទូចដែក

ដ៏ក្រហមឆ្អៅប៉ុនដើមត្នោត ទាញមកផ្តួលសត្វនរកទាំងនោះលើប្រឹថពី

ហើយចាក់សាប់ដោយកង្វេររាប់រយ ដូចចាក់សាប់ស្បែកគោឧសភៈ ។

ពពួកសត្វនរកនោះ ឈឺបម្រះនឿលដូចត្រីបោះលើគោក កាលមិន

អាចធន់ទ្រាំនឹងសេចក្តីទុក្ខនោះបាន ក៏នាំគ្នាស្រែកយំខ្សឹកខ្សួលហៀរ

ទឹករឡាក់ ។ ក្រោយពេលមាតលិទេវសារថី បររថបង្ហាញ ឲ្យទ្រង់

ទស្សនានៅឋាននេះហើយ

នេ. “អ្នកចូរមើលពួកសត្វនរកនេះ មានអណ្តាតមុតដោយសន្ទូច បី

ដូចស្បែកដែលគេខ្វារដោយកង្វេរ ពួកគេញាប់ញ័រដូចត្រីបោះ

ទៅលើគោក ព្រោះហេតុអ្វីហ្ន៎ បានជាសត្វនរកទាំងនេះ យំបង្ហៀរទឹកមាត់ ? ម្នាលទេពបម្រើ ខ្ញុំឃើញដូច្នេះ ខ្ញុំខ្លាចណាស់ តើពួកជនដែលដេកស៊ីសន្ធូចនៅទីនេះ ព្រោះបានធ្វើបាបដូចម្ដេច ?"

មា. "ពួកសត្វនៅក្នុងឋាននរកនេះ ដើមឡើយ គឺជាមនុស្សត្រូវបានគេតែងតាំងក្នុងតំណែងវាយតម្លៃទំនិញ ។ កាលបើបានសំណូកខ្លះ ៗ ក៏បញ្ចុះតម្លៃរបស់របរ ទាំងទ្រព្យមានវិញ្ញាណ មានដំរីសេះជាដើម ឬទ្រព្យឥតវិញ្ញាណមានមាសប្រាក់ជាដើម ។ ពួកគេបញ្ចុះទំនិញដល់អ្នកទិញទាំងឡាយមានថ្លៃថោក ឲ្យគេទិញថ្លៃ ៥០ កាលបើទំនិញនោះថ្លៃ ១០០ ហើយយក ៥០ នោះបែងចែកជាមួយនឹងអ្នកទិញនោះឯង ។ មួយក្រុមទៀតបិតនៅក្នុងតំណែងតុលាការ បានធ្វើអំពើកោង[៥០]មិនយុត្តិធម៌ជាដើម ព្រោះល្មោភទ្រព្យសម្បត្តិ ។ កាលកំពុងធ្វើនូវអំពើអយុត្តិធម៌នោះ បានប្រើវិធីបិទបាំងអំពើនោះដោយវាចាផ្អែមល្ហែម ឧបមាដូចជាអ្នកស្ទូច

---

[៥០] (គុ.) វៀចចំកោងឡើង : ឈើកោង ។ បើជាពាក្យប្រៀប មនុស្សកោង គឺមនុស្សព្រហើន ។

*កាលនឹងសម្លាប់ត្រីដែលហែលតាមទឹក គេយកនុយមកបិទត្រង់ ផ្លៀងសន្ទូចហើយស្ទូចត្រីនោះមកសម្លាប់បានដូច្នោះ ។ ជាធម្មតា ទីពឹង មិនមានដល់អ្នកដែលធ្វើអំពើអយុត្តិធម៌ អំពើកោងនោះទេ ថ្វីបើពួកគេសម្គាល់ថា គ្មាននរណាម្នាក់ដឹងពីទង្វើរបស់ខ្លួនដែល បិទបាំងក៏ដោយ ។ អំពើកោងខ្លួនគេ រួបរឹតខ្លួនគេហ្នឹងឯង ។ ដោយសារតែអំពើនោះ គេនឹងពុំបាននូវទីពឹងទៅថ្ងៃមុខឡើយ ។ ពួកជនអ្នកមានអំពើលាមកនោះ ទទួលរងបាបទើបបានជាពួក គេដេកស៊ីផ្ទៃសន្ទូចដូច្នេះ" ។*

**១៣- នរកត្នោតស្ងួតស្ងាល់**

*នៅឋាននរកនេះ ពួកសត្វនរកសុទ្ធសឹងតែជានារី ៗ មានរាង កាយបែកសុស[៥១]ជុំវិញខ្លួន ជាកំណើតថោកទាប មានរូបប្លែក គួរខ្ពើម*

---

[៥១] (កិ.) (សុស; គុម "ស្ងួត, ក្រៀម; ជ្រប់, សញ្ចប់សញ្ចឹង; ក្រៀមក្រំ; ស្រពោនស្រពាប់; ទ្រមឹងទ្រមើយ") ឆេះទៅជាផេះ; ឆេះផុយ ។ កិ. វិ. ឬ គុ. ដែលឆេះទៅជាផេះ; ដែល ឆេះផុយ : ឆេះសុស; កំបោរថ្មសុស ។
(កិ. វិ.), (គុ.) សព្វ; ដាស, ដាសពាស, ពាសពេញ ឬពេញពាស; រខុញ; សព្វអន្ទើ, សព្វសាច់ : ដើរសុសដី, ឮសុសសព្វ ។ មុខអុតស៊ីសុស មុខមានស្នាមអុតរខុញឬដាស ពាស ។ សុសបរទ (ព. ប្រ.) សុសដូចជាបរទេស៊ីគ្មានសល់សាច់, សុសសព្វឥតសល់:

រអើម ខ្លួនអត់ស្បែក មានតែខ្ទុះនិងឈាម ដូចគោអត់ក្បាល ក្នុងគារឃាតដ្ឋាន។ នារីទាំងនោះ ឈរស្ទុះជាប់ខ្លួនត្រឹមចង្កេះបីដូចគេកប់ នៅលើប្រឹថពីដែក ដែលកំពុងតែឆេះសន្ធោសន្ធៅជានិច្ចកាល ហើយនារីទាំងនោះ ត្រូវភ្នំជាច្រើនកិនសង្កត់ ។ បានឮថា នៅពេលស្រ្តីទាំងនោះផុងខ្លួនជាប់ដីត្រឹមចង្កេះយ៉ាងនេះ ភ្នំដែកក្រហមឆ្អៅ ផុសលេចចេញនៅឰដ៏ទិសខាងកើតលាន់សំឡេងហាក់បីដូចរន្ទះបាញ់រមៀលមកកិនខ្លួនពួកនារីនរកឲ្យខ្ទេចខ្ទីដូចផេះ ។ នាកាលភ្នំនោះ ហួសទៅឈប់នៅប៉ែកខាងលិច រាងកាយរបស់ពពួកនារី ៗ ទាំងនោះ ក៏កើតប្រាកដលេចឆ្លោឡើងថ្មីមួយទៀត ។ ពួកនារី ៗ ទាំងនោះកាលមិនអាចអត់សង្កត់នូវទុក្ខលំបាកនោះបាន ក៏ស្រែកកន្ទក់កន្ទេញ ។ ក្នុងទិសផ្សេង ៗ ក៏មានភ្នំភ្លើងលេចចេញមកកិនពួកនារីនរកទាំងនោះ ដោយទំនងដូចភ្នំភ្លើងក្នុងទិសខាងកើតដែរ ។ មិនតែប៉ុណ្ណោះទេ ភ្នំពីរផុសដំណាលគ្នារំលៀកៀបនារីនរកបីដូចឃ្នាបអំពៅរឹតឈាមឲ្យហូរចេញពីខ្លួនប្រាណលាន់

---

ដើរសុសបរទេ, កណ្ដៀរស៊ីសុសបរទេ ។ សុសសព្វ សព្វអន្ទើ : ដើរសុសសព្វ ។ សុសសាច់ សព្វសាច់, មិនសល់សាច់ : ឈឺសុសសាច់, ដំបៅសុសសាច់ ។ សុសសាយ ឬ សាយសុស សាយសព្វអន្ទើ, លេចឮសព្វអន្ទើ : ឮសុសសាយ (ម. ព. សុស ១ កិ. ផង) ។

សំឡេងព្ធរ ។ ក្នុងពេលខ្លះ មានភ្នំ ៣ ផុសឡើងតែងតែវិលក្បៀប ។ គ្រាខ្លះ មានភ្នំដល់ទៅ ៤ តែងផុសឡើងវិលកៀបខ្លួនរបស់ពួកនារីនរក នោះ ។ ក្រោយពេលមាតលិទេវសារថីបររថបង្ហាញទ្រង់ឲ្យទស្សនាការ នៅឋាននេះហើយ

នេ. "ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ ពាសពេញដោយឈាមនិងខ្ទុះ មានខ្លួនដាច់រយះរយាយ បីដូចគោដែលគេពន្លះស្បែកក្នុងទីសម្លាប់ ពួកនាងផ្គងដើមដៃទាំងគូយំកន្ទក់កន្ទេញ ពួកស្ត្រីទាំងនោះ មានខ្លួនលិចចុះក្នុងផែនដីស្មើចង្កេះ មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំតែងរមៀលកិនសព្វ ៗ កាល ។ ម្នាលទេពបម្រើ ខ្ញុំឃើញដូច្នេះ ខ្ញុំភ័យស្ទុតណាស់ ។ តើពួកស្ត្រីដែលលិចចុះក្នុងផែនដីស្មើចង្កេះ មានភ្លើងឆេះសន្ធោសន្ធៅ ត្រូវភ្នំរមៀលកិនសព្វ ៗ កាល នេះ បានធ្វើនូវបាបកម្មដូចម្ដេច ?"

មា. "ពួកនារីនរកនោះ កាលដើមឡើយ ជាកុលធីតា នៅពំនាក់អាស្រ័យក្នុងត្រកូល បានធ្វើនូវអំពើអសប្បុរសយ៉ាងគឃ្លើន

មានជាតិជាស្រីអ្នករឹងរូស[៩២] ជាស្រីអ្នកលេង លះបង់ប្ដីខ្លួនឯង ត្រាច់ទៅរកបុរសដទៃ ញុំាងប្រុសដទៃឲ្យត្រេកត្រអាល ព្រោះហេតុតែល្មោភក្នុងកាម និងហេតុតែវក់ល្បែង ញុំាងចិត្តខ្លួនឲ្យស្រើបស្រាលជាមួយនឹងប្រុសឈ្មោលផ្សេង ៗ ក្រៅអំពីប្ដីខ្លួនក្នុងកាលរស់នៅក្នុងជីវលោក ។ ពួកស្ត្រីមានអំពើមិនបរិសុទ្ធនេះ រងបាប ទើបមានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនដាច់រយះរយាយខ្លួនប្រាណ នៅឋាននរកនេះ" ។

## ១៤- នរករណ្ដៅធំ

ឋាននរកនេះ មានរាងជារណ្ដៅធំ ពោរពេញដោយរងើកភ្លើងដ៏ក្រហមច្រាលឆ្អៅ ។ សត្វនរកទាំងឡាយ នៅឋាននរកនេះ ត្រូវនាយនិរយបាលដែលមានដៃកាន់អាវុធនានា ចាក់និងសំពងដូចហ្វូងគោដែលមិនព្រមចូលក្រោល ។  ពេលណា សត្វនរករត់ចូលទៅជិតនរករណ្ដៅធំនោះ ពេលនោះឯង នាយនិរយបាលទាំងឡាយ ចាប់ពួកគេ

---

[៩២] (គុ.) រឹងគគ្រឹសគគ្រួស, រឹងមិនព្រមចុះរុះ, មិនព្រមទន់តាម : មនុស្សរឹងរូស, សម្ដីរឹងរូស, ចិត្តរឹងរូស ។ កាព្យថា : មនុស្សរឹងរូស ច្រើនតែប្រទូស្ត ប្រទាំងឱវាទ នៅក្នុងទីណា ច្រើនតែវាតអាទ៍ ត្រាតែរវាត ឃ្លាតចាកទីនោះ ។

ត្រវាត់ជើងឡើងលើ សំយុងក្បាលចុះក្រោម បោះមួយពេញទំហឹង ទម្លាក់ទៅក្នុងនរករណ្ដៅធំនោះ ។ ពួកសត្វនរកនេះ ដើមឡើយ ជាមនុស្ស លួចទ្រព្យដ៏ល្អ គឺប្រពន្ធជាទីស្រឡាញ់ អំពីប្តីរបស់គេ នាឋានមនុស្ស ។ ក្រោយពេលមាតលិទេវសារថី បររថបង្ហាញទ្រង់ឲ្យទស្សនានៅឋាននេះហើយ

នេ. "ព្រោះហេតុអ្វី បានជាសត្វនរកមួយពួកទៀតនេះត្រូវនាយនិរយបាលចាប់ជើង ឲ្យមានក្បាលសំយុងចុះ ហើយបោះចូលទៅក្នុងរណ្ដៅ ។ ម្នាលទេពបម្រើ ខ្ញុំឃើញអ៊ីចឹង ខ្ញុំខ្លាចណាស់ តើពួកសត្វទាំងនេះ បានធ្វើបាបកម្មដូចម្ដេច ?"

មា. "ពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សលួចទ្រព្យដ៏ល្អ គឺប្រពន្ធជាទីស្រឡាញ់អំពីប្តីរបស់គេ នាឋានមនុស្ស ។ ជនអ្នកមានអំពើអសប្បុរស ប្រព្រឹត្តកន្លងនូវប្រពន្ធទាំងឡាយនៃជនដទៃដូច្នោះ នោះឈ្មោះថាជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា ។ សត្វទាំងឡាយនោះនៅក្នុងរណ្ដៅអស់កាលជាច្រើនឆ្នាំ ព្រោះថា ទីពឹងទាំងឡាយរបស់អ្នកធ្វើបាបមិនមាន ។ ពួកគេត្រូវអំពើបាបរបស់ខ្លួនរួបរឹត ។ ពួកសត្វអ្នកមានអំពើលាមកនោះ ទទួលរងនូវបាប ទើបបានជា

មានក្បាលសំយុងចុះ ត្រូវនាយនិរយបាលបោះចូលទៅក្នុង
រណ្ដៅ" ។

**១៥- នរកខ្ពស់ទាប**

ក្រោយអំពីរៀបរាប់យ៉ាងនេះ មាតលិទេវសារថីបររថវិលងពីឋាននរកនោះឆ្ពោះទៅមុខ បង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនានូវឋាននរកនៅខាងមុខទៀត ជាកន្លែងពួកអ្នកមិច្ឆាទិដ្ឋិ[៤៣] ។ នៅឋាននរកនេះ ពពួកសត្វនរក មានរាងកាយខ្ពស់ខ្លះ ទាបខ្លះ តូចខ្លះ ធំខ្លះ ហើយមានជីវិតរស់នៅយ៉ាងត្រដាបត្រដួស ។

នេ. "ម្នាលទេពបម្រើ ខ្ញុំភ័យខ្លាចណាស់ ព្រោះឃើញពួកសត្វទាំងឡាយនេះ ខ្ពស់និងទាបផ្សេងគ្នា ជាអ្នកត្រដាបត្រដួស មានរូបគួរខ្លាចពន់ពេក ។ តើពួកជនដែលមានសេចក្ដីទុក្ខវេទនាក្លៀវក្លាខ្លោចផ្សាក្ដៅក្រហាយក្រៃលែងនេះ បានធ្វើបាបដូចម្ដេច ?"។

មា. "ពួកសត្វនរកនេះ ដើមឡើយ ជាមនុស្សមានទិដ្ឋិដ៏លាមកពន់

---

[៤៣] មិច្ឆាទិដ្ឋិ (--ទិតឋិ) ន. (បា.; សំ. មិថ្យាទ្ឫិ្ឋ) សេចក្ដីយល់ឃើញខុស គឺដំណើរយល់ខុសអំពីសេចក្ដីពិត ដូចយ៉ាងយល់ឃើញថា មាតាបិតាគ្មានគុណ, សត្វទាំងអស់ស្លាប់ហើយលែងកើតទៀតជាដើម ។ ព. ផ្ទ. សម្មាទិដ្ឋិ ។

ពេក ។ ពួកគេយល់ខុសក្នុងរឿង ១០ យ៉ាង មានយល់ថា "ទានដែលគេបានឲ្យហើយ មិនមានផល" ជាដើម[៥៤] ថែមទាំងហ៊ានធ្វើបាបកម្មនានា ព្រោះអាស្រ័យមិច្ឆាទិដ្ឋិដ៏ស្អិត ។ ជនទាំងឡាយក្នុងជីវលោកនេះ មានទិដ្ឋិលាមកក្រៃលែង តែងធ្វើអំពើដ៏ស្អិទ

---

៥៤

ពួកគេយល់ខុសចាកគន្លងធម៌ ដែលមាន ១០ យ៉ាងនោះ គឺ ៖

១- នត្ថិ ទិន្នំ យល់ថា ទានដែលបុគ្គលឲ្យ មិនមានផល
២- នត្ថិ យិដ្ឋំ យល់ថា របស់ដែលបុគ្គលបូជាមិនមានផល
៣- នត្ថិ ហុតំ យល់ថា សក្ការៈដែលបុគ្គលធ្វើមិនមានផល
៤- នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ យល់ថាផលវិបាករបស់កម្មដែលសត្វធ្វើ ល្អ និង អាក្រក់មិនមាន
៥- នត្ថិ អយំ លោកោ យល់ថា លោកនេះមិនមាន
៦- នត្ថិ បរោ លោកោ យល់ថា លោកខាងមុខមិនមាន
៧- នត្ថិ មាតា យល់ថា មាតាមិនមានគុណ
៨- នត្ថិ បិតា យល់ថា បិតាមិនមានគុណ
៩- នត្ថិ សត្តា ឧបបាតិកា យល់ថា សត្វជាឧបបាតិកមិនមាន
១០- នត្ថិ លោកេ សមណព្រាហ្មណា យល់ថា ពួកសមណៈ និងព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងគ្នាប្រតិបត្តិធម៌ ហើយពោលថា បានធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ មិនមាន ។

ព្រោះមោហៈគ្រប់សង្កត់ ទាំងបបួលអ្នកដទៃឲ្យយល់ក្នុងទិដ្ឋិទាំង ឡាយនោះផង ទើបពួកគេរងនូវបាប សោយទុក្ខវេទនាដ៏ក្តៀវ ក្លាខ្លោចផ្សាក្តៅក្រហាយយ៉ាងក្រៃលែងដូច្នេះ" ។

**សក្កទេវរាជបញ្ជូនទេវបុត្រឲ្យទៅតាមជាលើកទី១**

កាលដែលមាតលិទេវសារថី ក្រាបទូលដោះស្រាយចម្ងល់ថ្វាយ ព្រះបាទនេមិរាជ អំពីឋាននរកជាទីផុតពពួកសត្វអ្នកមិច្ឆាទិដ្ឋិ ដោយ ប្រការមានប្រមាណប៉ុណ្ណោះ ពពួកទេវតានៅឰដ៏ឋានទេវលោកនាយ កំពុងនាំគ្នាជួបជុំក្នុងសុធម្មាទេវសភា ទន្ទឹងរង់ចាំមើលផ្លូវយាងមក របស់ព្រះបាទនេមិរាជនៅឡើយ ។ ចំណែកសក្កទេវរាជរំពឹងមើលថា "តើមាតលិ ទៅយូរព្រោះហេតុអ្វី?" ដូច្នេះ ទ្រង់បានជ្រាបនូវស្ថាន ការណ៍នោះថា "មាតលិ ហេតុតែចង់បង្ហាញខ្លួនថាជាទូតដ៏វិសេស ឥឡូវគេកំពុងតែបររថ នាំព្រះបាទនេមិរាជបង្ហាញទ្រង់ទស្សនាឋាន នរក និងកំពុងតែរៀបរាប់ថា ឆេះនៅឋាននេះមកពីបាបកម្មនោះ, ឆេះនៅឋាននោះ មកពីបាបកម្មនេះ ជន្មាយុរបស់ព្រះបាទនេមិរាជ នៅឋានមនុស្សមានរយៈ ពេលខ្លីណាស់ ទោះអស់ព្រះជន្មហ្នឹងផង ក៏ការទស្សនាឋាននរករបស់ ព្រះបាទនេមិរាជ ពុំដល់ទីបញ្ចប់ដែរ"

លុះព្រះមានតម្រិះដូច្នេះហើយ សក្កទេវរាជ បានបញ្ជូនទេវបុត្រមួយអង្គដែលមានសន្ទុះខ្លាំង ឲ្យទៅតាមមាតលិថា "ទេវតាឯងចូរទៅតាមមាតលិប្រាប់គេ ថាឲ្យនាំព្រះបាទ នេមិរាជមកកាន់ទេវលោកឲ្យឆាប់" ។ ទេវបុត្រនោះ ទទួលព្រះរាជបញ្ជាហើយ បានហោះផ្លោះបោះពួយខ្លួនដោយសន្ទុះលឿនក្រៃ មកជួបមាតលិ ហើយប្រាប់នូវដំណឹងនោះ ។ មាតលិឮពាក្យនោះ គិតថា "មិនអាច យឺតយូរបានទេ" ហើយក៏ស្រូតបង្ហាញស្តេចនេមិរាជឲ្យទ្រង់ទស្សនា នូវនរកជាច្រើនក្នុងទិសទាំង ៤ ដោយពេលតែមួយព្រមគ្នា ហើយបានក្រាបទូលចំពោះទ្រង់ថា ៖

"បពិត្រមហារាជ លំនៅរបស់សត្វទាំងឡាយអ្នកមានបាបកម្មនេះ គឺព្រះអង្គបានទតយល់ច្បាស់ជាក់ក្នុងព្រះហឫទ័យហើយ, ទាំងគតិរបស់ពួកអ្នកទ្រុស្តសីល ក៏ព្រះអង្គបានជ្រាបច្បាស់ហើយដែរ បពិត្រមហារាជ ឥឡូវនេះ សូមព្រះអង្គយាងទៅធ្វើទស្សនកិច្ចនៅឋានទេវរាជ ទតមើលទិព្វសម្បត្តិទេវតាម្តងចុះ ក្រាបទូល" ។

និរយកណ្ឌចប់តែប៉ុណ្ណេះ ។

# ជំពូកទី៣
# ដំណើរទស្សនកិច្ចនៃព្រះបាទនេមិរាជនៅឋានសួគ៌

## វិមានទេពធីតាពីរណី

*លុះពោលយ៉ាងនេះហើយ មាតលិបានបររថឆ្ពោះមុខទៅកាន់ទេវលោក កាលកំពុងស្ថិតនៅក្នុងដំណើរទៅកាន់ទេវលោកនោះ ព្រះបាទនេមិរាជ បានចោលព្រះនេត្រាមើលបណ្ដើរទៅក្នុងលម្ហអាកាស ក៏បានប្រទះភ្នែកនឹងវិមានមួយឋិតនៅឰដ៏អាកាស ត្រូវជាកម្មសិទ្ធិរបស់ទេវធីតាមួយអង្គ ឈ្មោះ* ***ពីរណី*** *។ វិមាននេះ ប្រដាប់ដោយអាភរណៈទាំងពួង មានកម្រងផ្កាជាដើម កម្ពស់ ១២ យោជន៍*[៥៥] *វិចិត្រដោយកែវមណីទាំងអស់ មានកំពូល ៥ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង មានឧទ្យាន និងស្រះបោក្ខរណី*[៥៦] *មានដើមកប្បព្រឹក្សដុះដង្ហែជាជួរជុំវិញវិមាន ។ ពេលនោះ ពីរណីទេវធីតាម្ចាស់វិមាន កំពុងអង្គុយនៅលើគ្រែសយនា ខាងក្នុងកូដាគារនាវិមាននោះ សម្ដែងឲ្យឃើញនូវទេវឫទ្ធិ*

---

[៥៥] *ទ្វាទសយោជនិកំ ។*

[៥៦] (ន.) (បា.),(សំ.) (*បោក-ខ:រ៉:ណី*) (*បុក្ខរិនិឬបុក្ខរិណី*) *ស្រះមានឈូក* (*ស្រះឈូក*)។

មានប្រការផ្សេង ៗ មានស្រីអប្សរជាបរិវារ ១.០០០ អង្គ ។ ព្រះនាងបើក សីហបញ្ជរកែវមណីចោលភ្នែកគយគន់មើលទេសភាពខាងក្រៅ គាប់ ចួនព្រះបាទនេមិរាជងាកព្រះនេត្រទៅ ក៏ឃើញមុខគ្នា ។ ព្រះបាទ នេមិរាជទ្រង់សួរមាតលិថា ៖

"វិមាននេះ មានកំពូល ៩ ដែលយើងឃើញប្រាកដ មាននាង នារី មានអានុភាពធំ ប្រដាប់ដោយកម្រងផ្កា សម្ដែងនូវទេវ ឫទ្ធិមានប្រការផ្សេង ៗ នៅកណ្ដាលដំណេកក្នុងវិមាននោះ ។ ម្នាលទេពបម្រើ ខ្ញុំឃើញដូច្នេះ ខ្ញុំសែនរីករាយណាស់ តើនារី ដែលរីករាយក្នុងវិមានក្នុងឋានសួគ៌នេះ បានធ្វើកុសលកម្មដូច ម្ដេច ?"

មាតលិទេវសារថី កាលត្រូវព្រះបាទនេមិសួរដូច្នេះ ក៏ព្យាករនូវផលនៃ បុញ្ញកម្មទាំងឡាយ តាមដែលខ្លួនដឹងទូលព្រះរាជាអង្គនោះ ដែលទ្រង់ មិនដឹងឲ្យជ្រាបថា ៖

"ទេពធីតាពីរណីនេះ ដើមឡើយ ជាខ្ញុំបម្រើគេ (ទាសី) ។ នាង កើតនៅក្នុងផ្ទៃពោះរបស់ទាសីម្នាក់ដែលត្រូវជាខ្ញុំបម្រើនៅក្នុងផ្ទះ របស់ព្រាហ្មណ៍ម្នាក់ នាសម័យកាលព្រះទសពល កស្សប ។

ព្រាហ្មណ៍ម្ចាស់ផ្ទះនោះ ត្រៀមធ្វើការបរិច្ចាគស្លាកភត្ត ៨ ចំពោះសង្ឃ ។ កាលដែលគាត់ទៅផ្ទះ គាត់បានប្រាប់ព្រាហ្មណីប្រពន្ធថា "តាំងអំពីថ្ងៃស្អែកទៅ អូនត្រូវជួយចាត់ចែងស្លាកភត្ត ៨ ដែលមួយ ៗ ថ្ងៃមួយកហាបណៈ ៗ សម្រាប់ប្រគេនភិក្ខុមួយអង្គ ៗ " ។ ប្រពន្ធគាត់ជំទាស់ថា "ខ្ញុំមិនអាចជួយបានទេ បង ! ដ្បិតថា ភិក្ខុជាអ្នកលេង" ។ មិនតែប៉ុណ្ណោះ សូម្បីកូនស្រីរបស់គាត់ ក៏បានបដិសេធដូចម្តាយដែរ ។ ទើបគាត់មកសាកសួរទាសីថា "តើអាចជួយយើងបានទេ នាង ?" ទាសីនោះយល់ព្រមដោយនិយាយថា "នាងខ្ញុំនឹងជួយ ចៅហ្វាយ" ហើយនាងជួយចាត់ចែងបបរ បង្អែម និងភត្ត ជាដើមដោយគោរព ។ កាលដែលអតិថិភិក្ខុបានស្លាកនិមន្តមកដល់ នាងទាសីដឹងហើយ តែងទៅនិមន្តឲ្យគង់លើអាសនៈដែលក្រាលត្រៀមស្រេច ។ អាសនៈនោះធ្វើលាបដោយអាចម៍គោស្រស់ តុបតែងដោយផ្កា ។ ទាសីនោះតែងសប្បាយរីករាយជានិច្ចកាល ដូចម្តាយសប្បាយពេលជួបកូនម្តង ក្រោយពីបែកកូនយូរ ។ នាងតែងអង្គាសដោយគោរព និងបានប្រគេនរបស់ផ្ទាល់ខ្លួនបន្តិចបន្តួចខ្លះ ៗ ផងតាមលទ្ធភាព ។ មិនតែប៉ុណ្ណោះ

នាងជាអ្នកមានសីលសម្រួមល្អផង ចេះចែករំលែកផង ។ ដោយសារសីលនិងចាគៈ[៥៧]នោះ ទើបនាងកើតជាទេពធីតារីករាយ ក្នុងវិមាននេះ" ។

**វិមានទេវបុត្រសោណទិន្នៈ**

លុះក្រាបទូលស្ដេចយ៉ាងនេះហើយ មាតលិបានបររថឆ្ពោះទៅមុខបង្ហាញឲ្យទ្រង់ទស្សនា នូវវិមានមាស ៧ របស់ទេវបុត្រមួយអង្គ ឈ្មោះសោណទិន្ន ។ វិមានទាំង ៧ របស់សោណទិន្នទេវបុត្រ នៅឋានសួគ៌នេះ មើលទៅឃើញដង្ហែគ្នាជាជួរតាមលំដាប់មានរបៀបរៀបរយ មានពន្លឺរុងរឿង ផ្សាយចេញនូវឱភាស ដូចពន្លឺព្រះអាទិត្យដ៏ស្រស់ខ្ចី ហើយមានតែសោណទិន្នទេវបុត្រមួយប៉ុណ្ណោះគង់នៅ ។ ក្រោយពេលឃើញវិមាននិងសិរីសម្បត្តិរបស់សោណទិន្នទេវបុត្រនោះហើយ ព្រះបាទនេមិរាជត្រាស់សួរនូវបុព្វកម្មរបស់សោណទិន្នទេវបុត្រនោះថា ៖

"វិមានមាសទាំង ៧ ដែលបុញ្ញកម្មតាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រដ៏ទ្រង់ឫទ្ធិច្រើន ប្រដាប់ដោយអាភរណៈគ្រប់បែប ទាំងមានពួកនាងទេពធីតាចោម

[៥៧] ការលះឲ្យ, ការចំណាយធនធានដើម្បីជាសាធារណប្រយោជន៍ ។

ពោម ដើរប្រទក្សិណដោយជុំវិញ ក្នុងវិមានទាំង ៧ នោះ ។
ម្នាលទេពបម្រើ ខ្ញុំឃើញអ៊ីចឹង ខ្ញុំមានសេចក្ដីត្រេកអរណាស់
តើទេវបុត្រនេះ បានធ្វើនូវកុសលដូចម្ដេច ទើបដល់នូវឋានសួគ៌
ហើយរីករាយក្នុងវិមានដូច្នេះ ?"

មាតលិទេវសារថី កាលត្រូវព្រះបាទនេមិសួរដូច្នេះ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជាអង្គនោះ ដែលទ្រង់មិនជ្រាប ឲ្យទ្រង់បានជ្រាបថា ៖

"ទេវបុត្រនេះ ដើមឡើយ ជាគហបតីម្ចាស់នៃទាន មានឈ្មោះល្បីក្នុងមនុស្សលោកថា សោណទិន្ន គាត់រស់នៅក្នុងនិគមមួយនាដែនកាសី ក្នុងសម័យកាលព្រះទសពល កស្សប ។ គាត់បានកសាងកុដិនៅឯវត្តចំនួន ៧ ខ្នងឧទ្ទិសចំពោះបព្វជិត ហើយគាត់តែងបម្រើភិក្ខុទាំងឡាយអ្នកមានចិត្តត្រង់ដែលគង់នៅក្នុងអាវាសនោះ ដោយប្រគេនចីវរសម្រាប់ស្លៀកដណ្ដប់ផង កត្តាហារផងសេនាសនៈផង គ្រឿងប្រទីបផង ថ្នាំព្យាបាលជំងឺផង ដោយសេចក្ដីជ្រះថ្លាគោរពផ្ចិតផ្ចង់ និងតែងរក្សាសីល ៥ ចាំសីល ៨ ផងដែរ គឺគាត់រក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤

ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខ[៥៨]ផង ។ គាត់ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួម

[៥៨] ឧបោសថ ដែលឧបាសកឧបាសិកាគួររក្សាមាន ៣ គឺ បកតិឧបោសថ ១, បដិជាគរឧបោសថ ១, បាដិហារិយឧបោសថ ១ ។ បកតិឧបោសថ ក្នុង ១ ខែមាន ៨ ថ្ងៃ គឺថ្ងៃបញ្ចមី, អដ្ឋមី, ចាតុទ្ទសី, បណ្ណរសី ខាងខ្នើត ៤ ថ្ងៃ ខាងរនោច ៤ ថ្ងៃ ត្រូវជា ៨ ថ្ងៃ ។ បដិជាគរឧបោសថ កំណត់យកថ្ងៃអមខាងដើមនិងខាងចុង នៃថ្ងៃបកតិឧបោសថ ហៅថា បដិជាគរឧបោសថ ។ បាដិហារិយឧបោសថនោះ ក្នុងអដ្ឋកថាមនោរថបូរណី គម្ពីរអង្គុត្តរនិកាយចែងថា ឧបោសថដែលបុគ្គលត្រូវរក្សាជាប់ជានិច្ចអស់ ៣ ខែខាងក្នុងវស្សា គឺកំណត់ពីត្រឹមថ្ងៃចូលវស្សាទៅដល់ថ្ងៃបវារណាចេញវស្សា ហៅថា បាដិហារិយាឧបោសថ ។ ម្យ៉ាងទៀត បើបុគ្គលមិនអាចនឹងរក្សាអស់កំណត់កាល ៣ ខែខាងក្នុងវស្សានោះបានទេ ត្រូវរក្សាឲ្យបានជាប់ជានិច្ចអស់ ១ ខែក្នុងចន្លោះនៃបវារណាទាំងពីរ គឺកំណត់ពីត្រឹមថ្ងៃ ១ រោច ខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មី ខែកត្តិក កាលបើបុគ្គលមិនអាចនឹងរក្សាអស់កំណត់ ១ ខែក្នុងចន្លោះនៃបវារណាទាំងពីរនោះបានទេ ត្រូវរក្សាជាប់ជានិច្ចអស់កាលត្រឹមកន្លះខែ ចាប់ដើមតាំងអំពីថ្ងៃបឋមបវារណាមក គឺកំណត់ពីត្រឹមថ្ងៃ ១ រោចទៅដល់ថ្ងៃ ១៤ រោចខែអស្សុជ ក៏បានហៅថា បាដិហារិយឧបោសថដែរ ។ ក្នុងអដ្ឋកថាបរមត្ថជោតិកា គម្ពីរខុទ្ទកនិកាយ សុត្តនិបាត លោកវិនិច្ឆ័យត្រង់ពាក្យថា បាដិហារិយឧបោសថនេះ មានកំណត់កាល ៥ ខែ គឺខែអាសាឍពេញ ១ ខែ, ខាងក្នុងវស្សា ៣ ខែ, ខែកត្តិកពេញ ១ ខែ, ទាំង ៥ ខែនេះ លោកហៅថា កាលជាទីរក្សានូវបាដិហារិយឧបោសថ ។ មានអាចារ្យដទៃទៀតពោលថា មានត្រឹមតែ ៣ ខែគឺ ខែអាសាឍ, កត្តិក, ផល្គុន, ទាំង ៣ ខែនេះហៅថា កាលជាទី

នូវឥន្ទ្រិយ ជាអ្នកចែកទាន ។ លុះគាត់ច្យុតចាកអត្តភាពពីឋាន មនុស្សលោក គាត់បានមកកើតជាទេវបុត្រនៅឋានសួគ៌នេះ មាន ទឹកមុខរីករាយស្រស់ស្រាយ" ។

**វិមានឧបាសិកា**

ក្រោយពេលប្រាប់អំពីកម្ម ដែលសោណទិន្នបានធ្វើយ៉ាងនេះ ហើយ នាយសារថីបានបររថឆ្ពោះទៅមុខទៀតបង្ហាញឲ្យព្រះបាទនេមិ រាជទ្រង់ទស្សនានូវវិមានកែវផ្លេក ដែលមានសណ្ឋានជាប្រាសាទ កម្ពស់ ២៥ យោជន៍ ជញ្ជាំងសុទ្ធតែកែវផ្លេកទាំងអស់ សសរស្តម្ភ[៥៩]រាប់ រយ សោតសឹងតែជាវិការៈនៃកែវ ៧ ប្រការ កំពូលអាគាររាប់រយ សុទ្ធ

---

រក្សានូវបាដិហារិយឧបោសថ ។ មានអាចារ្យមួយពួកទៀតពោលថា ថ្ងៃសែសគូ គឺថ្ងៃ ១៣ កើត ១៣ រោច, ថ្ងៃ ១ កើត ១ រោច ថ្ងៃ ៧ កើត ៧ រោច ៩ កើត ៩ រោច គ្រប់ បក្សទាំងអស់ (ទាំងជុណ្ហបក្ស "ខាងខ្នើត" ទាំងកាឡបក្ស "ខាងរនោច") ដោយ អំណាចថ្ងៃខាងដើមនិងខាងចុងនៃថ្ងៃឧបោសថ ហៅថា កាលជាទីរក្សានូវបាដិហារិ-យឧបោសថ ។ ពាក្យដែលបានពោលមកទាំងប៉ុន្មានអន្លើនោះ បើបុគ្គលពេញចិត្ត ពាក្យណាគប្បីកាន់យកតាមពាក្យនោះចុះ ប៉ុន្តែបុគ្គលអ្នកចង់បានបុណ្យ គួរតែធ្វើឲ្យ បានសព្វគ្រប់ តាមន័យនោះ ៗ ។

[៥៩] សសរដែលគេបណ្តុះភ្ជាប់លើថ្នឹមទាបត្រង់ល្វែងបាំងសាចវិហារឬសាលា, សសរ មាំមួន, សសររឹងប៉ឹង ។

តែមានក្បូរក្បាច់រចនាល្អវិចិត្រ ខ្ពស់ត្រដែតត្រដឹមស្កឹមស្កៃ ទាំងមានព្យួរចង្រ្កង់ជារបៀបកម្រងផ្កាណែងណោង[៦០] នៅជុំវិញឲ្យយោង មានជោតទង់មាស និងទង់ប្រាក់ នៅលើកំពូលអាគារ បក់រវិចទៅតាមខ្យល់យ៉ាងរវិច ។ នៅតាមទីធ្លាមានឧទ្យាន និងព្រៃព្រឹក្សាសឹងលម្អដោយបុប្ផានានា ដែលមានពណ៌វិចិត្រផ្សេង ៗ សម្រាប់កម្សាន្ត ។ មានស្រះស្រង់បោក្ខរណី ទឹកថ្លាត្បង[៦១] គួរជាទីរីករាយនៃចិត្ត ។ វិមាននេះដេរដាស ដោយស្រីអប្សរ ជាច្រើន ដែលពូកែខាងរាំច្រៀង ដេញដំប្រគុំកូត ជាដើម យ៉ាងប៉ិនប្រសប់ ស្ដាប់ទៅឮតែរបាំនិងចម្រៀងដ៏ពីរោះរណ្ដំ ។ ទតព្រះនេត្រឃើញដូច្នោះ ព្រះបាទនេមិរាជត្រាស់សួរអំពីបុព្វកម្ម របស់ស្រីអប្សរទាំងនោះថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតនេះ រុងរឿងដោយជញ្ជាំងកែវផ្ទេក កំពូលខ្ពស់ស្កឹមស្កៃ សម្បូរទឹកនិងភោជន ឮសូរតែរបាំនិងចម្រៀងដ៏ពីរោះរបស់ទេពអប្សរអ្នកពូកែលេង ។ ម្នាលទេពបម្រើ ខ្ញុំឃើញអ៊ីចឹង ខ្ញុំសែនត្រេកអរអ្វីម៉្លេះទេ តើនារីទាំងនេះ

[៦០] រណោងពេញពាស, រតែងរតោង ។

[៦១] ថ្លាឈ្វេង, ថ្លាយង់, ថ្លាឆ្វង់ ។

បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ហើយរីករាយក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី កាលត្រូវព្រះបាទនេមិរាជសួរដូច្នេះក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជាអង្គនោះដែលទ្រង់មិនជ្រាប ឲ្យបានជ្រាបថា ៖

"ពួកទេពអប្សរទាំងនោះ ដើមឡើយ សុទ្ធតែជាឧបាសិកាក្នុងក្រុងពារាណសី ក្នុងសម័យកាលព្រះពុទ្ធ កស្សប ។ ពួកនាង ជាឧបាសិកា មានសីល ត្រេកអរក្នុងទាន មានចិត្តជ្រះថ្លាជានិច្ចប្រកាន់ខ្ជាប់នូវសច្ចធម៌ មិនប្រហែសធ្វេសក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ។ ពួកនាងបានចងគ្នាជាពួកធ្វើបុណ្យទាំងឡាយមានប្រការផ្សេង ៗ ហើយក៏បានមកកើតនៅឋានសួគ៌សោយនូវទិព្វសម្បត្តិ រីករាយក្នុងវិមានបែបនេះ" ។

**វិមានឧបាសក**

បន្ទាប់មក មាតលិទេវសារថីទាញបង្ហៀរសេះឲ្យរត់ឆ្ពោះទៅមុខហើយបង្ហាញព្រះបាទនេមិរាជឲ្យទ្រង់ទស្សនា នូវវិមានកែវមណីគួរជាទីរីករាយនៃចិត្តមួយទៀត ។ វិមានមួយនេះ ជញ្ជាំងជុំវិញសុទ្ធតែជា

វិការៈនៃកែវពៃទូរ្យ[៦២] មានភូមិភាគបែងចែកល្អ គួរជាទីរីករាយនៃចិត្ត តាំងនៅស៊ប់លើភូមិភាគដ៏ស្មើ មើលទៅខ្ពស់ត្រដែតបីដូចជាកំពូលកែវមណី ទាំងមានឱភាសផ្សាយចៀលច្បាស់ ភ្លឺស្វាងស្វៃផង ។ ខាងក្នុងមានព្ទសូរសំឡេងស្គរនិងសម្ភោរ, របាំនិងចម្រៀង និងការប្រគំតន្ត្រីជាទិព្វផ្សេង ៗ ទៀត ប្រព្រឹត្តទៅយ៉ាងពីរោះរណ្តំ លាន់ព្ទរងំ សូរភ្លេងល្វេងល្វើយ[៦៣] គួរចាប់ចិត្ត ។ វិមាននេះដេរដាសដោយពួកទេវបុត្រជាច្រើន ។ ទតឃើញដូច្នោះ ព្រះបាទនេមិរាជ បានត្រាស់សួរអំពីបុព្វកម្មរបស់ទេវបុត្រនោះថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតនេះ រុងរឿងដោយជញ្ជាំងកែវពៃទូរ្យ ប្រកបដោយភូមិភាគចែកវាស់ដោយចំណែក ។ ខាងក្នុងវិមានមានសូរសំឡេងទិព្វលាន់ព្ទគឺស្គរ សម្ភោរ[៦៤] របាំចម្រៀង និងការ

---

[៦២] ពេជ្រភ្នែកឆ្មា ។

[៦៣] ដែលមានសូរលាន់រងំ, ឬដែលផ្សាយក្លិនក្រអូបល្វើយ ៗ គួរឲ្យស្រណោះ គួរឲ្យចាប់ចិត្ត ។

[៦៤] (ន.) (ស.) (តះពោន អ. ថ. តៈផូន ឬ តៈភោន) ឈ្មោះគ្រឿងភ្លេងពិណពាទ្យមួយប្រភេទរាងមូលជ្រលម ខាងដើមធំជាងខាងចុង ដាសស្បែកទាំងពីរខាងមានចម្រៀកស្បែករឹតព័ទ្ធស្រោបតួ, ដាក់ផ្តេកភ្ជាប់លើជើងទ្រពីក្រោម, កាលណារៀបនឹងទះលេង

ប្រគំ[៦៥] គួរស្តាប់ ជាទីរីករាយនៃចិត្ត ។ សំឡេងដែលប្រព្រឹត្តទៅពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ឥឡូវទើបតែបានដឹង ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរណាស់ ព្រោះបានមកឃើញដូច្នេះ ។ តើពួកទេវបុត្រទាំងនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ហើយ រីករាយ ក្នុងវិមានបែបនេះ ?" ។

មាតលិទេវសារថី កាលដែលព្រះបាទនេមិរាជសួរហើយ ក៏ព្យាករផលនៃបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជាអង្គនោះដែលទ្រង់មិនជ្រាបឲ្យជ្រាបថា ៖

"ពួកទេវបុត្រនោះ កាលនៅជាមនុស្ស គឺជាឧបាសក មានប្រក្រតីរស់នៅក្នុងក្រុងពារាណសី ក្នុងសម័យព្រះពុទ្ធនាម **កស្សប** ។ ពួកគេបានចង់គ្នាជាពួកក្រុម កសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន ប្រតិបត្តិព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់

---

ភ្លេងត្រូវកិនបាយលាយផេះបិទចំកណ្តាលស្បែកដាស ដើម្បីឲ្យលាន់សូរធំតូចក្រអួន, ប្រើទះនឹងបាតដៃទាំងពីរខាង : ស្គរធំជាគូទទួលចង្វាក់សម្ពោរ ។

[៦៥] លេងភ្លេងរងំគួរឲ្យស្រណោះ

ដោយគោរពព្រមទាំងបានថ្វាយ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យ[៦៦] ចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រង់ ដោយទឹកចិត្តជ្រះថ្លា ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេបានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថិទី១៤ ផង តិថិទី១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយាបក្ខផង ជាអ្នកសង្រួមក្នុងសីលទាំងឡាយ សព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ[៦៧] និងជាអ្នកចែក

---

[៦៦] បច្ច័យ មាន ៤ គឺ ៖

| | |
|---|---|
| ១- ចីវរប្បច្ច័យ | គ្រឿងស្លៀកដណ្ដប់; |
| ២- បិណ្ឌបាតប្បច្ច័យ | គ្រឿងបរិភោគ; |
| ៣- សេនាសនប្បច្ច័យ | គ្រឿងដេកអង្គុយ; |
| ៤- គិលានភេសជ្ជប្បច្ច័យ | ថ្នាំកែរោគផ្សេង ៗ ។ |

[៦៧] (សំ.),(បា.) (អិន-ទ្រី) ភាវៈជាធំ, ឥស្សរភាព; អានុភាព, អំណាច; គុណានុភាពឬគុណសម្បត្តិរបស់ព្រះឥន្ទ្រឬដែលជាប់ទាក់ទងអំពីព្រះឥន្ទ្រកម; រូបកាយ; កម្លាំង, កម្លាំងកាយ; សេចក្ដីដឹង, ប្រាជ្ញា; អារម្មណ៍; មុខការ, នាទី; អាយតនៈខាងក្នុង, ប្រសាទឬប្រសាទរូប : សង្រួមឥន្ទ្រិយ ប្រុងប្រយ័ត្នអាយតនៈខាងក្នុងមានភ្នែកជាដើម ។ ឥន្ទ្រិយ សព្ទនេះមានន័យច្រើនយ៉ាងណាស់, ព. ពុ. ប្រាប់ថាអ្វីដែលជាធំតាមមុខតាមនាទីរបស់ខ្លួនឬដែលមានបែបភាពផ្សេងដោយឡែកហៅថា ឥន្ទ្រិយ, ដូចជា

ទាន ។ ពួកគេធ្វើបុណ្យទាំងឡាយដូច្នេះហើយ ទើបបានមកសោយទិព្វសម្បត្តិនៅឋានសួគ៌ រីករាយក្នុងវិមានបែបនេះ” ។

## វិមានគហបតី

មាតលិ លុះក្រាបទូលព្រះបាទនេមិរាជ ឲ្យស្តេចទ្រង់ជ្រាបអំពីបុព្វកម្ម ដែលពួកទេវបុត្រនោះបានធ្វើ ដោយប្រការដូច្នេះហើយ ក៏បានបរវេជយន្តរថឆ្ពោះទៅមុខ បង្ហាញឲ្យព្រះបាទនេមិរាជទតវិមានកែវផ្ទេកមួយផ្សេងទៀត ។ វិមាននោះ ប្រដាប់ដោយកំពូលជាច្រើនអនេក នៅតាមបរិវេណមានព្រៃព្រឹក្សាដ៏ស្រស់ខ្ចី ជារបស់សួគ៌ ដុះជា

---

*ភ្នែក ហៅ ចក្ខុន្ទ្រិយ; ត្រចៀក ហៅ សោតិន្ទ្រិយ; ច្រមុះ ហៅ ឃានិន្ទ្រិយ; អណ្ដាត ហៅ ជីវ្ហិន្ទ្រិយ; កាយ ហៅ កាយិន្ទ្រិយ; មនោ ឬ ចិត្ត ហៅ មនិន្ទ្រិយ (ព្រោះអាយតនៈខាងក្នុងទាំង ៦ នេះជាធំក្នុងការទទួលអារម្មណ៍តាមនាទីរបស់ខ្លួន ជាជំនួសគ្នាពុំបាន) ។ ស្ត្រី ហៅ ឥត្ថិន្ទ្រិយ; បុរស ហៅ បុរិសិន្ទ្រិយ (ព្រោះជាធំដោយមានបែបភាពទីទៃពីគ្នា)។ ជីវិត ហៅ ជីវិតិន្ទ្រិយ (ព្រោះជីវិតជាធម្មជាតធំមួយយ៉ាងរបស់សត្វលោក) ។ សេចក្ដីសុខ ហៅ សុខិន្ទ្រិយ; សេចក្ដីទុក្ខ ហៅ ទុក្ខិន្ទ្រិយ; សោមនស្ស ហៅ សោមនស្សិន្ទ្រិយ; ទោមនស្ស ហៅ ទោមនស្សិន្ទ្រិយ; ឧបេក្ខា ហៅ ឧបេក្ខិន្ទ្រិយ (ព្រោះធម្មជាតទាំងនេះ សុទ្ធតែមាននាទីជាធំដោយឡែកពីគ្នា) ។ សទ្ធាហៅសទ្ធិន្ទ្រិយ; វីរិយៈ :ហៅ វីរិយិន្ទ្រិយ; សតិ ហៅ សតិន្ទ្រិយ; សមាធិ ហៅ សមាធិន្ទ្រិយ; បញ្ញា ហៅ បញ្ញិន្ទ្រិយ (ព្រោះធម៌ទាំងនេះសុទ្ធតែមាននាទីទីទៃពីគ្នា) ។*

ដួរមានរបៀប និងដេរដាសដោយផ្កាម្ទិះនានា, និងមានស្គរភ្លេងឮចេញអំពីវិមានល្វេងល្វើយទៅឮដ៏អាកាស សឹងមានទំនុកបទនោះប្លែក ៗ ជុំវិញមានស្ទឹងព័ទ្ធព័ទ្ធ ដែលមានទឹកថ្លាឈ្វេងឥតមន្ទិល ។ វិមាននេះជាលំនៅរបស់ទេវបុត្រអ្នកមានបុណ្យម្នាក់ ដែលកំពុងមានពពួកស្រីទេពអប្សរ[៦៨] ចោមរោម ។ ក្រោយពេលទតឃើញដូច្នោះ ព្រះបាទនេមិរាជត្រាស់សួរអំពីបុព្វកម្មរបស់ទេវបុត្រអង្គនោះថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតល្អនេះ រុងរឿងដោយជញ្ជាំងកែវផលិក

---

[៦៨] (ន.) (សំ.),(បា.) (អ័ប-ប្សរ) (អប្សរសិ, អប្សរា; អច្ឆរា "ស្ត្រីមានសម្បុរថ្លាស្រស់, ផូរផង់ ឬស្ត្រីមានមុខថ្លាស្រស់បំព្រង") ស្ត្រីសួគ៌ : ស្រីអប្សរ, ស្រីទេពអប្សរ, នាងអប្សរ ។ តាមសេចក្តីតំណាលក្នុងគម្ពីរព្រាហ្មណ៍ថា ស្ត្រីសួគ៌ពួកមួយដែលផុសឡើងអំពីទឹក ក្នុងកាលដែលកូរទឹកអម្ឫត (ប៉ុន្តែតាមការណ៍ពិត មិនមែនដូច្នោះទេ, ដែលហៅថា អប្សរ ឬ អប្សរា នោះមានសេចក្តីថា "ស្រីសួគ៌មានសម្បុរភ្លឺថ្លាផូរផង់ឬស្រីសួគ៌ឆើតឆោម") ។ ខ្មែរប្រើក្លាយជា អក្សរ ក៏មាន : ស្រីអក្សរ, ស្រីទេពអក្សរបរកញ្ញា (គួរលើកលែងប្រើត្រូវប្រើ អប្សរ ឬ អប្សរា, អច្ឆរា វិញ) ។ អប្សរទេពី ឬ --ទេវី (ព. ប្រ.) ទេពីឬទេវីមានលម្អដូចស្រីអប្សរ ឬក៏ដូចអប្សរា។

ដេរដាសដោយពួកនាងនារីដ៏ស្រស់ប្រិមប្រិយ កំពូលវិមានខ្ពស់ត្រដែត សម្បូរទឹកនិងភោជន មានកិរិយារាំនិងច្រៀង មានស្មឹងប្រកបដោយរុក្ខជាតិផ្កាផ្សេង ៗ ហូរព័ទ្ធជុំវិញ ។ ម្នាលទេពបម្រើខ្ញុំមានសេចក្តីត្រេកអរ ព្រោះមកបានឃើញដូច្នេះ តើទេវបុត្រនេះបានធ្វើនូវកុសលកម្មដូចម្តេច ទើបកើតនៅឋានសួគ៌ រីករាយក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជាអង្គនោះ ដែលមិនទ្រង់បានជ្រាបឲ្យជ្រាបថា ៖

"ទេវបុត្រដែលជាម្ចាស់វិមាននេះ ដើមឡើយ ជាគហបតី ជាសាមីដើមទានម្នាក់ ក្នុងក្រុងមិថិលា ក្នុងសម័យព្រះពុទ្ធនាម **កស្សប** ។ គាត់បានសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន ទាំងបានប្រតិបត្តិព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់ដោយគោរព។ គាត់បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យចំពោះព្រះអរហន្តអ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ គាត់បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី១៤ ផង តិថីទី១៥

ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង គាត់តែងបាន សង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ កើតនៅឋានសួគ៌ សោយទិព្វ សម្បត្តិ រីករាយក្នុងវិមានបែបនេះ" ។

## វិមានគហបតីទី២

ឯមាតលិ ក្រាបទូលស្តេចឲ្យទ្រង់ជ្រាបបុព្វកម្មដែលទេវបុត្រអង្គ នោះបានធ្វើយ៉ាងនេះហើយក៏បានបរវេជយន្តរថ[៦៩] ឆ្ពោះទៅមុខទៀត ហើយបង្ហាញឲ្យស្តេចទ្រង់ទតនូវវិមានមួយផ្សេងដោយឡែកទៀត ជា វិការៈនៃកែវផ្លេកដែរ។ វិមាននោះកំពូលខ្ពស់ត្រដែត ព្រៃក្រាស់ស្រស់ ខៀវខ្ចីនៅជុំវិញ រីឯឈើផ្កាផ្លែផ្សេង ៗ មានច្រើនជាងវិមានមុន ៗ ឆ្ងាយ មានដើមកែស ខ្វិត ស្វាយ សាលព្រឹក្ស ព្រីង ទន្លាប់ មាក់ប្រែនសុទ្ធសឹង ចេញផ្លែជានិច្ច ។ ពួកទេពអប្សរជាច្រើនកំពុងច្រៀងរាំថ្វាយទេវបុត្រ ។ នៅជុំវិញវិមាន មានស្នឹងទឹកថ្លាយង់អមដោយឈើផ្កាផ្សេង ៗ រីកស្រស់

[៦៩] (ន.) (បា.),(សំ.) (--ជៈយ័ន) (វេជយន្ត; វៃជ--) ឈ្មោះប្រាសាទឬរាជរថ កើត សម្រាប់ព្រះឥន្ទ្រ : ប្រាសាទពេជយ័ន្ត, រថពេជយ័ន្ត ។

ត្រសោល ។ ទតឃើញដូច្នោះ ព្រះបាទនេមិរាជ ត្រាស់សួរអំពីបុព្វកម្ម របស់ទេវបុត្រ អ្នកដល់ព្រមដោយសម្បត្តិនោះថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតល្អនេះ រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវផលិក សម្បូរកំពូលអាគារខ្ពស់ ៗ ប្រកបដោយទឹកនិងភោជន មានចម្រៀងនិងរបាំ ដេរដាសដោយពួកនារីដ៏ប្រសើរ ។ មានស្ទឹងអមដោយឈើផ្កាផ្សេង ៗ ហូរព័ទ្ធជុំវិញ ។ ឈើជាច្រើន មានដើមកែស ខិត ស្វាយ សាលព្រឹក្ស ព្រីង ទន្ទាប់ មាក់ប្រ៉ែន សុទ្ធសឹងមានផ្លែជានិច្ច ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរណាស់ ព្រោះមកបានឃើញដូច្នេះ ។ តើទេវបុត្រអង្គនេះបានធ្វើកុសលកម្មដូចម្ដេច ទើបកើតនៅឋានសួគ៌ រីករាយក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជានោះដែលទ្រង់មិនជ្រាប ឲ្យទ្រង់ជ្រាបថា ៖

"ទេវបុត្រនោះ ដើមឡើយ ជាគហបតី ជាម្ចាស់នៃទានម្នាក់ ក្នុងក្រុងមិថិលា ដែនវិទេហរដ្ឋ ក្នុងសម័យព្រះពុទ្ធនាមកស្សប ។ គាត់បានសាងសួនច្បារ ស្រះ អណ្ដូងទឹក បានប្រតិបត្តិចំពោះ

ព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ គហបតីនោះបានទាំងរក្សាឧបោសថប្រកបដោយអង្គ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ។ គាត់សង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ។ លុះធ្វើបុណ្យទាំងឡាយនោះ ៗ ហើយទើបគាត់បានមកសោយនូវទិព្វសម្បត្តិ នៅឋានសួគ៌ រីករាយក្នុងវិមានបែបនេះ" ។

## វិមានកែវពៃទូរ្យ

ក្រោយពេលមាតលិក្រាបទូលអំពីបុព្វកម្ម របស់ទេវបុត្រអង្គនោះយ៉ាងនេះហើយ ក៏បររថឆ្ពោះទៅមុខ បង្ហាញឲ្យទ្រង់ទស្សនានូវវិមានកែវពៃទូរ្យមួយទៀត ប្រាកដដូចមុន ។ ស្តេចនេមិរាជត្រាស់សួរអំពីបុព្វកម្មរបស់ទេវបុត្រអ្នកបានសោយទិព្វសម្បត្តិក្នុងទីនោះថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតនេះ រុងរឿងដោយជញ្ជាំងកែវពៃទូរ្យ មានភូមិភាគចែកវាស់ដោយចំណែក ។ ក្នុងវិមាននោះ មានសូរសព្ទជាទិព្វលាន់ឮ មានស្គរសម្ភោរ របាំចម្រៀងនិងការរាំ គួរស្ដាប់ និងជាទីរីករាយនៃចិត្ត ។ សំឡេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមកខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ឥឡូវទើបតែបានដឹង ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរណាស់ ព្រោះមកបានឃើញដូច្នេះ ។ តើទេវបុត្រអង្គនេះបានធ្វើកុសលកម្មដូចម្ដេច ទើបកើតនៅឋានសួគ៌ ហើយរីករាយក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី ដែលព្រះបាទនេមិរាជសួរហើយ ក៏ព្យាករនូវផលនៃផលបុញ្ញកម្មទាំងឡាយតាមដែលខ្លួនដឹង ទូលព្រះរាជាអង្គនោះ ដែលទ្រង់ មិនជ្រាបឲ្យទ្រង់ជ្រាបថា ៖

"ទេវបុត្រអង្គនេះ ដើមឡើយ ជាគហបតីជាសាមីទាន ក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្ដូងទឹក ស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យ ចំពោះព្រះ

អរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា ។ ទេវបុត្រនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបទេវបុត្រនោះ រីករាយក្នុងវិមាន" ។

**វិមានមាស**

បន្ទាប់មក មាតលិទេវសារថីបររថឆ្ពោះទៅមុខទៀត បង្ហាញឲ្យព្រះបាទនេមិរាជទ្រង់ទតនូវវិមានមាស ដូចព្រះអាទិត្យទើបរះថ្មី ៗ ។ ព្រះបាទនេមិរាជត្រាស់សួរអំពីសម្បត្តិទិព្វ របស់ទេវបុត្រអ្នកនៅក្នុងវិមាននោះថា ៖

"វិមាននេះ ជាវិការនៃមាសដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះអាទិត្យទើបរះឡើង មានពណ៌ក្រហមមានមណ្ឌលធំ ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរ ព្រោះមកបានឃើញដូច្នេះ តើទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី ទូលព្រះរាជាថា ៖

"ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងសាវត្ថី ក្នុងសម័យព្រះសម្ពុទ្ធ កស្សប ។ គាត់បានសាងសួនច្បារ ស្រះអណ្តូងនិងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រង់ដោយគោរព បានថ្វាយចីវរបិណ្ឌបាតសេនាសនៈ និងគិលានប្បច្ច័យ ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា ។ គហបតីនោះ បានរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយជាអ្នកចែកទាន ។ លុះបានធ្វើបុណ្យទាំងឡាយនោះ ៗ ហើយ ទើបគហបតីនោះ បានសម្រេចនូវសម្បត្តិបែបនេះ រីករាយក្នុងវិមាន" ។

**វិមានទេវហាស៍**

ក្នុងពេលមាតលិទូលអំពីវិមានទាំង ៨ នេះ ជាហូរហែយ៉ាងនេះ, សក្កទេវរាជគិតថា "មាតលិយឺតយូរម៉្លេះ" ទ្រង់ក៏បានបញ្ជូនទេវបុត្រអ្នកមានសន្ទុះខ្លាំងមួយរូបទៀតឲ្យទៅតាម ។ ទេវបុត្រនោះស្ទុះហោះបោះពួយមកប្រាប់មាតលិភ្លាម ឥតបង្អង់យូរឡើយ ។ ចំណែក

មាតលិព្ធពាក្យតឿនឲ្យប្រញាប់ របស់សក្កទេវរាជនោះហើយ គិតថា "ឥឡូវនេះ មិនអាចដំអក់នៅយូរទេ" ហើយក៏បង្ហាញឲ្យស្ដេចនេមិរាជទ្រង់ទតឃើញនូវវិមានជាច្រើន ក្នុងទិសទាំង ៤ ក្នុងពេលតែមួយព្រមគ្នា ។ វិមានទាំងឡាយនោះឋិតនៅឰដ៏វេហាស៍[៧០] ជួនកាលហៅថាវិមានអាកាស ។ វិមានទាំងនោះ រុងរឿងបីដូចផ្ទេកបន្ទោរភ្លឺក្នុងចន្លោះមេឃ ជាកន្លែងនៅរបស់ពួកទេវបុត្រ អ្នកធ្លាប់ជាសាវ័កនៃព្រះពុទ្ធ កស្សប ។ ព្រះបាទនេមិរាជ ត្រាស់សួរអំពីបុព្វកម្មរបស់ទេវបុត្រទាំងឡាយ អ្នកសោយសម្បត្តិក្នុងឋានសួគ៌នោះថា ៖

"វិមានទាំងឡាយនេះ ជាវិការៈនៃមាស មានប្រមាណច្រើន
ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺដ៏
រុងរឿង ដូចជាផ្ទេកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំង
ឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយ

---

[៧០] (ន.) (បា.),(សំ.) (--ហ៊ា) (វេហាស "ប្រទេសជាទីវីករាយនៃពួកបក្សី"; វិហ, វិហា, វិហាយស៑) អាកាស, មេឃ : កណ្ដាលវេហា, ឰដ៏វេហាស៍ (ច្រើនប្រើក្នុងកាព្យ) : អាកាសយាន ទើបតែកើតមាន សម័យជាន់ក្រោយ ហោះខ្ពស់អណ្ដែត ត្រសែតលឿនលយ ទទឹងបណ្ដោយ កណ្ដាលវេហា ។ វេហាសន្និន្នាទ (--ហា-សៈនិន-នាត) សូរសព្ទកងរំពងឬគគ្រុមគគ្រេងក្នុងអាកាស (សូរផ្គរឬសូររន្ទះ) ។ល។ វេហាស៍

គ្រឿងអាភរណៈគ្រប់បែប មានពួកនាងទេពអប្សរចោមរោម ប្រទក្សិណវិលវង់ជុំវិញ ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរ ព្រោះមកបានឃើញដូច្នេះ ។ តើពួកទេវបុត្រទាំងនេះបានធ្វើកុសលកម្មដូចម្ដេច ទើបកើតនៅឋានសួគ៌ រីករាយ ក្នុងវិមានបែបនេះ ?"

មាតលិទេវសារថី ទូលព្រះរាជាថា ៖

"ទេវបុត្រទាំងឡាយនោះ ដើមឡើយបានបួសក្នុងនិយ្យានិកសាសនារបស់ព្រះពុទ្ធនាមកស្សប ជាអ្នកមានសីលបរិសុទ្ធ ធ្វើនូវសមណធម៌ បានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ កាលមិនអាចញ៉ាំងអរហត្តផលឲ្យកើតឡើងធ្វើខ្លួនជាព្រះអរហន្តបាន ទើបកើតក្នុងវិមានមាសទាំងឡាយនេះបន្ទាប់ពីច្យុតចាកអត្តភាពមនុស្សនោះ ។ បពិត្រព្រះរាជា ទីឋានទាំងឡាយដែលទ្រង់ក្រឡេកឃើញនុ៎ះ គឺជាឋានរបស់ទេវបុត្រអ្នកធ្លាប់បួសសីលបរិសុទ្ធ កាលនៅជាមនុស្សលោក" ។

**ភ្នំសត្តបរិភណ្ឌ**

លុះបង្ហាញឲ្យស្ដេចទ្រង់ទតនូវវិមានអាកាសទាំងឡាយយ៉ាងនេះហើយ មាតលិបង្កើនល្បឿនយ៉ាងលឿនទៅកាន់សម្នាក់របស់សក្កទេវរាជ ព្រមទាំងបានក្រាបទូលព្រះបាទនេមិរាជបណ្ដើរថា ៖

"បពិត្រមហារាជ ឋានរបស់សត្វអ្នកមានបាបកម្ម និងទាំងឋានរបស់សត្វអ្នកមានកល្យាណកម្ម[៧១] ក៏ទ្រង់បានទតឃើញយ៉ាងប្រចក្សនិងបានជ្រាបសព្វគ្រប់ហើយ បពិត្រព្រះរាជា សូមទ្រង់ស្វែងរកកុសលធម៌ចុះ ។ ឥឡូវនេះសូម ទ្រង់ស្ដេចយាងទៅកាន់សម្នាក់របស់សក្កទេវរាជ ក្រាបទូល" ។

លុះក្រាបទូលយ៉ាងនេះហើយ មាតលិទេវសារថីបររថឆ្ពោះទៅមុខ បង្ហាញឲ្យស្ដេចទ្រង់ទតនូវភ្នំសត្តបរិភណ្ឌ ដែលឋិតជុំវិញភ្នំព្រះសុមេរុ ។ ព្រះបាទនេមិមហារាជ ទ្រង់ឋិតនៅលើទិព្វយាន ទឹមដោយសេះសិន្ធព ១.០០០ ដែលមានសន្ទុះល្បឿនយ៉ាងខ្លាំងនោះ ទ្រង់រំពៃ

---

[៧១] អំពើល្អ, កុសលកម្ម ។

ព្រះនេត្រទតតាមការចង្អុលបង្ហាញរបស់មាតលិ ទ្រង់បានក្រឡេក ឃើញភ្នំក្នុងចន្លោះមហាសមុទ្រសីទន្តរ[៧២] ក៏សួរទេវសារថី ៖

"តើភ្នំទាំងនោះ មានឈ្មោះអ្វីខ្លះ ?"

មាតលិទេវបុត្របានក្រាបទូលថា ៖

"ឈ្មោះភ្នំធំ ៗ ក្នុងចន្លោះមហាសមុទ្រសីទន្តរ គឺភ្នំសុទស្សនៈ១ ករវិក១ ឥសិន្ធរ១ យុគន្ធរ១ នេមិន្ធរ១ វិនតក១ អស្សកណ្ណ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា ។ បពិត្រមហារាជ ភ្នំដែលទ្រង់ក្រឡេកឃើញ សឹងជាលំនៅនៃមហារាជទាំង ៤ ។ ភ្នំសុទស្សនៈនៅខាងក្រៅគេ បន្ទាប់មក គឺភ្នំករវិក ៗ នោះ ខ្ពស់ជាងភ្នំសុទស្សនៈ ។ ក្នុងចន្លោះភ្នំទាំងពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ បន្ទាប់ពីករវិក គឺភ្នំឥសិន្ធរ ៗ នេះ ខ្ពស់ជាងភ្នំករវិក ។ ចន្លោះភ្នំទាំងពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ បន្ទាប់ពីភ្នំឥសិន្ធរ គឺភ្នំយុគន្ធរ ៗ នេះខ្ពស់ជាងភ្នំឥសិន្ធរ ។ ក្នុងចន្លោះភ្នំទាំងពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ បន្ទាប់ពី

[៧២] (ន.) (បា.) (--ទ័ន-ដ) សមុទ្រឥតសរសៃ, សមុទ្រទឹកកក ។

ភ្នំយុគន្ធរគឺភ្នំនេមិន្ធរ ៗ នេះ ខ្ពស់ជាងភ្នំយុគន្ធរ ។ ក្នុងចន្លោះភ្នំទាំងពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ បន្ទាប់ពីភ្នំនេមិន្ធរ គឺភ្នំវិនតក ៗ នេះ ខ្ពស់ជាងភ្នំនេមិន្ធរ ក្នុងចន្លោះភ្នំទាំងពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ បន្ទាប់ពីភ្នំ វិនតកៈ គឺភ្នំអស្សកណ្ណៈ ៗ នេះ ខ្ពស់ជាងភ្នំវិនតកៈ ។ ក្នុងចន្លោះភ្នំទាំង ពីរនោះ មានមហាសមុទ្រសីទន្តរមួយ ។ ភ្នំទាំង ៧ នេះ ខ្ពស់ឡើងតាមលំដាប់គ្នា ក្នុងមហាសមុទ្រ ប្រៀបដូចកាំជណ្តើរ ។ ភ្នំទាំងនេះ ជាលំនៅរបស់ស្តេចចតុលោកបាលទាំង ៤ ៗ

**ទេពនគរ**

លុះបង្ហាញឲ្យទ្រង់ទតនូវទេវលោកជាឋាននៅនៃមហារាជទាំង ៤ យ៉ាងនេះហើយ មាតលិបានបររថឆ្ពោះទៅមុខ បង្ហាញឲ្យទ្រង់ទតនូវរូបសំណាក[៧៣]របស់ព្រះឥន្ទ ដែលឋិតនៅជុំវិញខ្លោងទ្វារចិត្តកូដនៃភពតាវត្តិង្ស ។ ទតឃើញដូច្នោះ ព្រះរាជាត្រាស់សួរថា ៖

[៧៣] (ន.) បែបដែលសាក : មានសំណាកទុក ។ គុ. ដែលសាកយកភាពពីបែបដើម : រូបសំណាក ។

"ទ្វារមានរូបជាអនេក ដ៏រុងរឿងវិចិត្រដោយរតនវត្ថុផ្សេង ៗ ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជាព្រៃធំដែលពួកខ្លាធំចាំនៅរក្សា ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរណាស់ ព្រោះមកបានឃើញដូច្នេះ តើទ្វារនេះ ឈ្មោះអ្វី បានជាធ្វើឲ្យចិត្តរីករាយអំពីចម្ងាយ ?"

មាតលិទេវសារថី ក្រាបទូលថា ៖

"ទ្វារនេះឈ្មោះចិត្តកូដ ជាទីចេញចូលនៃទេវរាជ ក្នុងទេពនគរដែលមានទំហំ ១០.០០០ យោជន៍ តាំងនៅលើកំពូលភ្នំព្រះសុមេរុ ជាភ្នំគួរឲ្យចង់មើល ។ ទ្វារនេះមានរូបសំណាកជាអនេករុងរឿងវិចិត្រដោយរតនវត្ថុផ្សេង ៗ ជាទ្វារដេរដាសដោយរូបសំណាកព្រះឥន្ទ្រ បីដូចជាព្រៃធំដែលពួកខ្លាយាមរក្សា ។ បពិត្រព្រះរាជា សូមទ្រង់ស្វែងរកគុណធម៌ សូមទ្រង់យាងចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វ គឺដី មាស ប្រាក់ កែវមណី ដ៏ឥតល្អងធូលីប្រឡាក់ មានតែដេរដាសដោយបុប្ផានានា រាបស្មើល្អ ក្រាបទូល" ។

**សុធម្មាទេវសភា**

លុះពោលយ៉ាងនេះហើយ មាតលិបានបររថដឹកព្រះបាទនេមិរាជចូលទៅកាន់ទេពនគរ ។ ព្រះបាទនេមិមហារាជ ទ្រង់បិតនៅលើទិព្វយានមានសេះជាពាហនៈ[៧៤] ទឹមដោយសេះសិន្ធព ១.០០០ ទ្រង់យាងទៅបាន ទតឃើញទេវសភា ទ្រង់ត្រាស់សួរថា ៖

"វិមានដែលបុញ្ញកម្មនិម្មិតនេះមានជញ្ជាំងជាវិការៈនៃកែវពៃទូរ្យ ឃើញច្បាស់ដូចអាកាសមានពន្លឺពណ៌ខៀវ ក្នុងសរទរដូវ[៧៥] ។ ម្នាលទេពបម្រើ ខ្ញុំត្រេកអរណាស់ ព្រោះមកបានឃើញដូច្នេះ តើវិមាននុ៎ះ ឈ្មោះអ្វី ?"

មាតលិទេវសារថី ទូលព្រះរាជាថា ៖

---

[៧៤] (ន.) (សំ.),(បា.) (--ហៈនៈ) (វាហន) គ្រឿងដឹកនាំ, យាន, ជំនិះ, យានជំនិះ ។ គ្រឿងប្រើប្រាស់ជិះ, សម្រាប់ផ្ទុកដឹកនាំ ដូចយ៉ាងរថ, រទេះ, ទូក ជាដើម ហៅថា យាន ឬ យានពាហនៈ, យានវាហនៈ; សត្វបម្រើសម្រាប់ជិះ, ទឹម ដូចយ៉ាងសេះ, ដំរី, គោ, ក្របី ជាដើម ហៅថា សត្វពាហនៈ, សត្វវាហនៈ ឬ ពាហនសត្វ, វាហនសត្វ ។

[៧៥] (ន.) (បា.),(សំ.) (សៈរ៉ៈទៈ) (សរទ; គរទ៑) រដូវចុះអ័ព្ទឬរដូវមានខ្យល់, ភ្លៀង, ទឹកសន្សើមខ្វះ; ហៅ សរទកាល ឬ សរទរដូវ; ក៏បាន (ម. ព. រតូវ ឬ រដូវ ត្រង់ រដូវទី ៣ ដែលនិយាយពីរដូវ ៤ និងត្រង់រដូវទី ៦ ដែលនិយាយពីរដូវ ៦) ។

"ទេវសភា ដែលព្រះអង្គទតឃើញនុ៎ះ ហៅថា **សុធម្មាទេវសភា** រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រ ដែលបុញ្ញានុភាពនិម្មិតដោយប្រពៃ មានសសរជ្រុង ៨ ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការៈនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តិង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នាគិតគូរសេចក្តីចម្រើនរបស់ទេវតានិងមនុស្សទាំងឡាយ បពិត្រព្រះរាជាទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអបអរសាទរ របស់ទេវតាទាំងឡាយ តាមទ្វារនេះ ក្រាបទូល" ។

ចំណែកទេវតាទាំងឡាយ ដែលកំពុងតែអង្គុយរង់ចាំការយាងមករបស់ព្រះបាទនេមិរាជ គ្រាន់តែបានឮដំណឹងថា "ព្រះបាទនេមិរាជយាងមកដល់" ក៏នាំគ្នាទៅទទួលដល់ខ្លោងទ្វារចិត្តកូដ ទាំងមួយអង្គ ៗ មានដៃកាន់នូវគ្រឿងក្រអូប គ្រឿងអប់ និងបុប្ផាជាទិព្វ ។ កាលបានបូជាព្រះមហាសត្តដោយគ្រឿងក្រអូបនិងផ្កាកម្រងជាទិព្វជាដើមហើយ បាននាំទ្រង់យាងទៅកាន់សុធម្មាទេវសភា ។ ព្រះបាទនេមិរាជ ស្តេចទ្រង់ចុះចាកវេជយន្តរថ ចូលទៅកាន់ទេវសភា ។ ពួកទេព្តាទាំងឡាយ បានអញ្ជើញព្រះអង្គ ដោយអាសនៈ ។ សូម្បីសក្កទេវរាជ ក៏អញ្ជើញព្រះ

អង្គដោយអាសនៈផង ដោយកាមទាំងឡាយផង ។ ពួកទេពនិករបាន ឃើញព្រះរាជាស្តេចយាងមកដល់ មានសេចក្តីត្រេកអរក្រាបទូលថា ៖

ស្វាគតំ តេ មហារាជ, អថោ តេ អទុរាគតំ;
និសីទ ទានិ រាជីសិ, ទេវរាជស្ស សន្តិកេ។

"បពិត្រមហារាជ ដំណើរដែលព្រះអង្គយាងមកនេះប្រពៃណាស់ មិនមែនអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះសូមព្រះអង្គគង់ជិតទេវរាជចុះ" ។

ឯសក្កទេវរាជទ្រង់ត្រេកអរទទួលស្វាគមន៍ព្រះបាទនេមិរាជស្តេចក្រុង មិថិលាអញ្ជើញព្រះអង្គថា ៖

"សាធុ ខោសិ អនុប្បត្តោ, អាវាសំ វសវត្តិនំ;
វស ទេវេសុ រាជីសិ, សព្វកាមសមិទ្ធិសុ;
តាវតឹសេសុ ទេវេសុ, ភុញ្ជ កាមេ អមានុសេ"

"ព្រះអង្គមកដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃ ណាស់ ។ សូមព្រះអង្គគង់នៅក្នុងទេវលោក ជាទីញ៉ាំងសេចក្តី

ប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយដែលមិនមែនជារបស់មនុស្ស ក្នុងតាវត្តិង្សទេវលោកនេះចុះ" ។ ក្រោយពេលសក្កទេវរាជ អញ្ជើញដោយកាមជាទិព្វផងដោយអាសនៈផងយ៉ាងនេះ ព្រះបាទនេមិរាជទ្រង់បដិសេធថា ៖

"យថា យាចិតកំ យានំ, យថា យាចិតកំ ធនំ;
ឯវំ សម្បទមេវេតំ, យំ បរតោ ទានបច្ចយា។

"ន ចាហមេតមិច្ឆាមិ, យំ បរតោ ទានបច្ចយា;
សយំកតានិ បុញ្ញានិ, តំ មេ អាវេណិកំ ធនំ។

"សោហំ គន្ត្វា មនុស្សេសុ, កាហាមិ កុសលំ ពហុំ;
ទានេន សមចរិយាយ, សំយមេន ទមេន ច;
យំ កត្វា សុខិតោ ហោតិ, ន ច បច្ឆានុតប្បតិ" ។

"វត្ថុណាដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចយានជារបស់សុំគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនោះក៏មានឧបមេយ្យយ៉ាងនេះឯង ។ ទូលបង្គំជាខ្ញុំ ឥតចង់បានវត្ថុដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យទេ បុណ្យទាំងឡាយដែលទូលបង្គំបាន

ធ្វើដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ទូលបង្គំ ។ ទូលបង្គំនឹងត្រឡប់ទៅធ្វើកុសលដែលបុគ្គលធ្វើហើយ រមែងដល់សេចក្ដីសុខ មិនក្ដៅក្រហាយខាងក្រោយឲ្យមានប្រមាណ ដោយការឲ្យផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស" ។

ព្រះមហាសត្វ បានសម្ដែងនូវធម៌ដោយសំឡេងដ៏ពីរោះ ដល់ទេវតាទាំងឡាយ ក្នុងទេវលោកអស់ ៧ ថ្ងៃ តាមការគណនារបស់មនុស្ស ។ កាលទ្រង់ញ៉ាំងពពួកទេវតាឲ្យត្រេកអរហើយ ទ្រង់បានក្រោកឈរនៅកណ្ដាលពពួកទេវតា ពណ៌នាគុណរបស់មាតលិទេវសារថីថា ៖

"មាតលិទេវសារថី ជាអ្នកមានឧបការៈច្រើនដល់ទូលបង្គំជាខ្ញុំ ព្រោះគេបានជូនដំណើរទស្សនកិច្ចរបស់ទូលបង្គំ ដើម្បីបានឃើញលំនៅឋាននៃសត្វអ្នកមានបុញ្ញកម្ម និងលំនៅឋាននៃសត្វអ្នកមានបាបកម្ម គ្រប់សព្វដោយសុវត្ថិភាព" ។

**ព្រះបាទនេមិរាជត្រឡប់មកមនុស្សលោកវិញ**

គ្រានោះ ព្រះបាទនេមិរាជទូលសក្កទេវរាជថា ៖

"បពិត្រមហារាជ ខ្ញុំចង់ទៅកាន់មនុស្សលោកវិញ" ។

"នែមាតលិសម្លាញ់ បើដូច្នោះ ឯងចូរនាំព្រះបាទនេមិរាជទៅកាន់ក្រុងមិថិលានៅមនុស្សលោកវិញចុះ" សក្កទេវរាជត្រាស់ ។ មាតលិ ទទួលរាជបញ្ជាបានរៀបចំត្រៀមរាជរថ ។ ព្រះបាទនេមិរាជបានសំណេះសំណាលជាមួយនឹងពពួកទេវតា ប្រាប់ពពួកទេវតាឲ្យត្រឡប់វិញ ទើបទ្រង់យាងឡើងកាន់រថ ។ រីឯមាតលិបានបររថចុះមកកាន់ក្រុងមិថិលា តាមទិសភាគខាងកើត ។ មនុស្សម្នានៅឋានមនុស្សលោក គ្រាន់តែក្រឡេកឃើញរថទិព្វបរចុះមក ម្នាក់ ៗ រីករាយស្រស់ស្រាយថា "ស្តេចយើង មកវិញហើយ ៗ" ។ មាតលិបានប្រទក្សិណក្រុងមិថិលា យាងព្រះមហាក្សត្រឲ្យចុះត្រង់សីហបញ្ជរដដែលនោះ ហើយក្រាបទូលលាព្រះបាទនេមិរាជ ត្រឡប់ទៅកាន់ឋានរបស់ខ្លួនវិញ ។

ចំណែកមហាជនបានមកចោមរោមព្រះបាទនេមិរាជយ៉ាងអ៊ឹកអធឹក[៧៦] ម្នាក់ ៗ ក្រាបទូលសួរថា ៖

---

៧៦ ហ៊ឹកហ៊ាក, គគ្រឹកគគ្រេង, រុងរឿង ដោយមានមនុស្សច្រើននិងគ្រឿងតុបតែងដ៏ល្អព្រមទាំងភ្លេងតន្ត្រីផង ។

"បពិត្រព្រះសម្មតិទេព ទេវលោកប្រាកដដូចម្ដេច?" ព្រះរាជាបានពណ៌នានូវសម្បត្តិរបស់ទេវតាទាំងឡាយផង របស់សក្កទេវរាជផង ហើយទ្រង់សម្ដែងធម៌ប្រាប់ដល់មហាជនថា ៖

"សូមអ្នកទាំងឡាយ ចូរខំធ្វើបុណ្យទាំងឡាយមានទានជាដើម,

កាលបើធ្វើយ៉ាងនេះ ពួកអ្នកនឹងកើតក្នុងទេវលោកនោះដែរ" ។

ចំណេរកាលតមក សក់ស្កូវមួយដើមដុះនៅលើព្រះសីសៈរបស់ព្រះបាទនេមិរាជ ស្ដេចទ្រង់ប្រើនាយខ្មាន់ព្រះកេសដែលទូលថាទ្រង់មានស្កូវនោះ ឲ្យដកមកដាក់លើព្រះហស្ដទ្រង់ ដោយចន្ទាសមាស ។ ស្ដេចបានព្រះរាជទានស្រុកសួយមួយ ដល់ខ្មាន់ព្រះកេស ទ្រង់សព្វព្រះរាជហឫទ័យក្នុងផ្នួស ក៏បានផ្ទេររាជសម្បត្តិឲ្យរាជបុត្រគ្រង់ស្នង ។ រាជបុត្រទូលសួរថា ៖

"បពិត្រព្រះសម្មតិទេព ទ្រង់នឹងសាងផ្នួស ព្រោះហេតុអ្វី?" ព្រះបាទនេមិរាជតបថា ៖

"ឧត្តមង្គរុហា មយ្ហំ, ឥមេ ជាតា វយោហរា;
បាតុភូតា ទេវទូតា, បព្វជ្ជាសមយោ មម" ។

"អាយុសង្ខារៈដ៏ឧត្តមរបស់យើង ចាស់ទ្រុឌទ្រោមហើយ ទេវទូត
កើតប្រាកដហើយ នេះដល់ពេលដែលយើងត្រូវសាងផ្នួស" ។

លុះពោលគាថាដូច្នេះហើយ ទ្រង់បានធ្វើមហាទាន ហើយស្រេចកាល ណា រួចទ្រង់ក៏ចេញសាងផ្នួសដូចស្តេចមុន ៗ ស្នាក់នៅក្នុងព្រៃស្វាយ នោះឯង ទ្រង់សង្រួមក្នុងបព្វជ្ជា ចម្រើនព្រហ្មវិហារធម៌ ៤ ក្រោយអស់ ព្រះជន្មទ្រង់បានកើតក្នុងព្រហ្មលោក ។ រីឯរាជបុត្ររបស់ព្រះអង្គ ព្រះ នាមថា **កាឡារជនក** បានផ្តាច់តំណវង្សផ្នួសនោះ តាំងពីរជ្ជកាលខ្លួន ឡើងសោយរាជ្យមក ។

**ព្រះសាស្តាប្រជុំជាតក**

លុះនាំធម្មទេសនានេះមកបរិយាយហើយ ព្រះសាស្តាទ្រង់បញ្ជាក់ថា ៖

"ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែឥឡូវនេះទេ, សូម្បីពីអតីតជាតិ ក៏តថាគតធ្លាប់ចេញសាងមហាភិនេស្រ្កមណ៍ដែរ"

រួចទ្រង់ប្រជុំជាតកថា ៖

"តទា សក្កោ អនុរុទ្ធោ អហោសិ, មាតលិ អានន្ទោ,
ចតុរាសីតិ ខត្តិយសហស្សានិ ពុទ្ធបរិសា,
និមិរាជា បន អហមេវ សម្មាសម្ពុទ្ធោ អហោសិ"។

- សក្កទេវរាជ ក្នុងគ្រានោះ បានមកជាព្រះអនុរុទ្ធ
- មាតលិទេវសាថី បានមកជាព្រះអានន្ទ
- ក្សត្រ ៨៤.០០០ អង្គ បានមកជាពុទ្ធបរិស័ទ
- ព្រះបាទនេមិរាជបានមកជាអញតថាគតសម្មាសម្ពុទ្ធនេះឯង ។

នេមិរាជជាតកពិស្តារ ចប់តែប៉ុណ្ណេះ ។



នេះកាលព្រះបាទនេមិរាជយាង៍ទតឋាននរក

ISBN 9789996341069

PUC Press